**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ**

**ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកត្រាំកក់**

**វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អង្គតាសោម**

**ចូលរួមអបអរទិវាអំណាន លើកទី៨**

**លើប្រធានបទ៖**

# «គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល»។

**ព.ស. ២៥៦៦**

**គ.ស. ២០២៣**

| | |
|---|---|
| -ឈ្មោះ | ៖ **ទឹម សុខហួយ** |
| -ភេទ | ៖ ប្រុស |
| -ថ្ងៃខែឆ្នាំកំណើត | ៖ ០៩ មីនា ១៩៨៩ |
| -មុខរបរ | ៖ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ |
| -អង្គភាពបម្រើការងារ | ៖ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អង្គតាសោម (ខេត្តតាកែវ) |
| -លេខទូរសព្ទ | ៖ 086 96 77 27 / 088 855 53 53 |

# មាតិកា


១. សេចក្ដីផ្ដើម..........៣

២. សិក្សាបញ្ញត្តិ

២.១. បញ្ញត្តិគុណតម្លៃមនុស្ស..........៤

២.២. បញ្ញត្តិយុគសម័យឌីជីថល..........៥

៣. បរិវត្តកម្មឌីជីថល

៣.១. បរិវត្តកម្មឌីជីថលនៃការអប់រំ..........៥

៣.២. បំណិនសតវត្សទី២១ ក្នុងយុគឌីជីថល..........៩

៤. គុណសម្បទា និងគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល

៤.១. គុណតម្លៃស្វ័យសិក្សាក្នុងបរិបទទំនើប..........១១

៤.២. គុណតម្លៃមនុស្ស..........១១

៤.៣. គុណតម្លៃមនុស្សក្នុងសង្គមឌីជីថល..........១៣

៥. គុណតម្លៃគ្រូបង្រៀនក្នុងយុគសម័យឌីជីថល..........១៦

៥.១. គោលនយោបាយនៃការសិក្សាបែបឌីជីថល..........១៦

៥.១.១. យុទ្ធសាស្រ្តចតុកោណ..........១៦

៥.១.២. ការសិក្សាពេញមួយជីវិត..........១៧

៥.១.៣. ការបញ្ចូលជំនាញសតវត្សរ៍ទី២១..........១៨

៥.២. គុណតម្លៃគ្រូបង្រៀនឌីជីថល..........១៩

៥.២.១. ស្ដង់ដារវិជ្ជាជីវៈគ្រូបង្រៀន..........១៩

៥.២.២. ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន..........២០

៥.២.៣. គុណតម្លៃនៃការស្គាល់វិធីសាស្រ្តបង្រៀន..........២២

៥.៣. គុណតម្លៃគ្រូបង្រៀនអក្សរសាស្រ្តខ្មែរ..........២៧

៥.៣.១. ការអភិវឌ្ឍខ្លឹមសារមេរៀនសៀវភៅសិក្សាគោល..........២៧

៥.៣.២. កំណែទម្រង់កម្មវិធីសិក្សា..........២៧

៥.៣.៣. ការសិក្សាស្នាដៃអក្សរសិល្ប៍..........២៩

៥.៣.៤. គុណតម្លៃច្នៃប្រឌិតខ្លឹមសារមេរៀន..........៣១

៥.៣.៥. គុណតម្លៃក្នុងការផ្លាស់ប្ដូរវិធីសាស្រ្តបង្រៀន..........៤០

៥.៣.៦. ការបង្កើតឯកសារបង្រៀនដើម្បីពង្រឹងពុទ្ធិ..........៤១

៥.៣.៧. ការចងក្រងមេរៀនជាស្លាយ..........៤២

៥.៣.៨. ការប្រើវិធីសាស្រ្តបង្រៀនបែបផែនទីគំនិតក្នុងមុខវិជ្ជាអក្សរសាស្រ្តខ្មែរ..........៤៣

៦. សេចក្ដីសន្និដ្ឋាន..........៤៤

កំណាព្យអំពីគ្រូបង្រៀនសម័យឌីជីថល..........៤៥

ឯកសារយោង..........៤៩

ប្រធានបទ៖«**គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល**»។

## ១. សេចក្តីផ្តើម

កង់នៃការអភិវឌ្ឍរបស់ពិភពលោក មានការប្រែប្រួលទៅមុខឥតឈប់ឈរ និងឈានទៅរកវឌ្ឍនភាពនៃសកលភាវូបនីយកម្មយ៉ាងសម្បូរបែប។ ចរន្តនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤កំពុងជះឥទ្ធិពលយ៉ាងខ្លាំងលើវិស័យសេដ្ឋកិច្ច និងសង្គម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ការវិភាគទិន្នន័យ និងអ៊ីនធឺណិតនៃវត្ថុ។ល។ បច្ចេកវិទ្យាឌីជីថលទាំងនេះ បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងលឿន ដែលមិនធ្លាប់មានពីមុនមក ទាំងក្នុងវិស័យអប់រំ វិស័យសុខាភិបាល ទីផ្សារការងារ ធុរកិច្ច រដ្ឋបាលសាធារណៈជាដើម។ ការបន្តធ្វើទំនើបកម្ម និងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី ដែលគាំទ្រដល់ការស្រាវជ្រាវ និងនវានុវត្តន៍ ព្រមទាំងការកសាងសមត្ថភាពមន្ត្រីរាជការតាមបច្ចេកវិទ្យាឌីជីថល ជាយុទ្ធសាស្ត្រចាំបាច់ ដែលរាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងអនុវត្តនាពេលបច្ចុប្បន្ននេះ ដើម្បីកសាងគុណតម្លៃមនុស្សក្នុងសង្គមឌីជីថល។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ នឹងនាំមកនូវបញ្ហាប្រឈមមួយចំនួន ជាអាទិ៍បទល្មើសពាក់ព័ន្ធនឹងសន្តិសុខឌីជីថល ការការពារទិន្នន័យបុគ្គល សន្តិសុខទិន្នន័យ ឧក្រិដ្ឋកម្មឆ្លងដែន និងការកេងប្រវ័ញ្ច រំលោភបំពានផ្លូវភេទលើកុមារ និងស្ត្រីតាមអនឡាញ។ ដូចនេះ ការចាំបាច់គឺសំដៅជានាប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលមានភាពរឹងមាំធន់នឹងវិបត្តិផ្សេងៗ ព្រមទាំងឆ្លើយតបទាន់ពេលវេលានឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល។

នៅពេលនិន្នាការបរិវត្តកម្មឌីជីថល និងនវានុវត្តន៍នៃបច្ចេកវិទ្យាឌីជីថលក្នុងពិភពលោកបន្តល្បឿនទៅមុខយ៉ាងឆាប់រហ័ស ប្រទេសកម្ពុជាយើងត្រូវរៀបចំខ្លួនជាស្រេចសម្រាប់ឆ្លើយតបនឹងការវិវត្តនេះ ឱ្យទាន់ពេលវេលា ដើម្បីទាញយកប្រយោជន៍ឱ្យអស់លទ្ធភាពពីការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជាបាន និងកំពុងជួបបញ្ហាប្រឈមជាច្រើន រួមមាន ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថលនៅមិនទាន់គ្របដណ្តប់ពេញផ្ទៃប្រទេស បញ្ហាគុណភាពសេវា លទ្ធភាពធនធានហិរញ្ញវត្ថុ ប្រព័ន្ធឌីជីថលនៅតាមក្រសួង ស្ថាប័នបង្កើតតាមតម្រូវការរៀងៗខ្លួន និងត្រួតគ្នា និងពុំមានប្រើប្រាស់ថ្នាលជាតិរួម។ ចំណុចខ្សោយផ្សេងទៀត មជ្ឈមណ្ឌលទិន្នន័យជាតិសម្រាប់ផ្ទុកទិន្នន័យរួមនិងផ្តល់ ធនធានគណនាពុំទាន់មាននៅឡើយ ចំណែកក្រសួង ស្ថាប័នទាំងអស់ស្ទើរតែគ្មានហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាព ផ្នែកបច្ចេកទេសសន្តិសុខឌីជីថល។

ក្នុងដំណើរការនៃការធ្វើបរិវត្តកម្មឌីជីថល កាលានុវត្តភាពជាកត្តាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា មានចំនួនយុវជនច្រើនធៀបនឹងប្រជាពលរដ្ឋទូទៅ ដែលងាយទទួលយកបច្ចេកវិទ្យាឌីជីថលបានឆាប់រហ័ស និងសន្ទុះកំណើន នៃអ្នកប្រើប្រាស់អ៊ីនធឺណិត អាជីវកម្មប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងក្រុមហ៊ុនសេវាបច្ចេកវិទ្យាឌីជីថល។ ចក្ខុវិស័យនៃគោលនយោបាយនេះគឺ កសាងរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្ត ប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ។

ប្រទេសកម្ពុជា បានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ដើម្បីឆ្លើយតបនឹងបរិបទតំបន់ សកលលោក ដែលមានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើ គ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេសស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមាន ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និង សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែក លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាម

រយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតជាសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំ បច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាព ការងារ ស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម។

## ២. ការសិក្សាបញ្ញត្តិ

### ២.១. បញ្ញត្តិគុណតម្លៃមនុស្ស

- *យោងតាមវចនានុក្រមខ្មែរថ្មី ដែលរៀបចំឡើងដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ*(២០២២) បានពន្យល់ពាក្យ« **គុណតម្លៃ**» ថាគុណភាពនៃអ្វីដែលមានប្រយោជន៍ឬ សំខាន់, សារៈសំខាន់ ឬតម្លៃនៃអ្វីមួយ (សម្រាប់ អ្នកណាម្នាក់), ភាពបរិបូណ៌ដោយសេចក្តីល្អនិង ប្រយោជន៍ដែលមិនអាចកាត់ថ្លៃបាន : គុណតម្លៃនៃជីវិត, គុណតម្លៃជាប្រវត្តិសាស្ត្រនៃប្រាសាទព្រះវិហារ។
- **គុណតម្លៃ** ជាសីលតម្លៃ ជាគោលដៅរបស់សីលញាណ ហើយទាក់ទងផ្ទាល់ ទៅនឹងអំពើ សកម្មភាព ឬចរិយារបស់មនុស្ស។ សីលតម្លៃនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសុជីវធម៌ សីលធម៌ គុណធម៌ ឧត្តមគតិ និងគតិវិញ្ញូ ។ ដើម្បីឱ្យមានសីលតម្លៃសម្រាប់ខ្លួនឯង មនុស្សគ្រប់រូបត្រូវតែស្គាល់ថាអ្វីទៅជាតម្លៃរបស់ខ្លួនជាមុន។ ខាងក្រោមនេះគឺជាតម្លៃទាំង៨ [1]យ៉ាងដែលមនុស្សគ្រប់រូបត្រូវស្គាល់ ត្រូវដឹង៖
  - តម្លៃជីវសាស្ត្រ៖ តម្លៃនេះគឺមានជាប់ខ្លួនមនុស្សតាំងពីកំណើត មានន័យថាមនុស្សមានតម្លៃខាងរូបរាង ពណ៌សម្បុរ សាច់ឈាម កម្លាំង សុខភាព។
  - តម្លៃសេដ្ឋកិច្ច៖ជាតម្លៃខាងសម្ភារៈទ្រព្យសម្បត្តិ។ ទ្រព្យសម្បត្តិក៏ជាកត្តាដែលបានកំណត់តម្លៃរបស់មនុស្សដែរ។ ទោះបីជារបស់ក្រៅខ្លួន ប៉ុន្តែអ្នកដែលអាចធ្វើឱ្យខ្លួនឯងមានសេដ្ឋកិច្ចល្អ ទ្រព្យសម្បត្តិច្រើន នោះចាត់ទុកថា បុគ្គលនោះមានតម្លៃបានដែរ។
  - តម្លៃអារម្មណ៍៖ ជាតម្លៃខាងសតិស្មារតី និងចិត្តសុខស្ងប់ជាដើម។ បុគ្គលណាដែលអាចធ្វើឱ្យខ្លួនឯងមានអារម្មណ៍ស្ងប់សុខ មានចិត្តមិនរវើរវាយចាត់ទុកថាជាបុគ្គលដែលមានតម្លៃបាន។
  - តម្លៃសង្គម៖ ជាតម្លៃនៃការចូលរួមចំណែក និង តម្លៃទទួលបានពីសង្គមនូវមុខងារតួនាទី ភារកិច្ច កាតព្វកិច្ច សិទ្ធិអំណាច សេរីភាព ក្នុងវិស័យនយោបាយ, អរិយធម៌, សន្តិសុខ យុត្តិធម៌ វឌ្ឍនធម៌សង្គមជាដើម។
  - តម្លៃបញ្ញា៖ ជាតម្លៃដែលកើតចេញពីគំនិតប្រាជ្ញាក្នុងការប្រើប្រាស់ចំណេះដឹងទូទៅនិងការសម្រេចចិត្តធ្វើអំពើ សកម្មភាព ដើម្បីដោះស្រាយបញ្ហានានា ដើម្បីឈានទៅដល់កំរិតពុទ្ធិសច្ច ពុទ្ធិត្រូវ។
  - តម្លៃសោភ័ណវិជ្ជា៖ជាតម្លៃខាងសិល្បៈតុបតែងច្នៃប្រឌិត និងសោភ័ណភាព។ តម្លៃនៃសោភ័ណវិជ្ជា កន្លែងនេះមិនមែនសំដៅទៅលើភាពស្រស់ស្អាតនៃរាងកាយនោះទេ ប៉ុន្តែជាតម្លៃបង្ហាញពីគុណភាពបញ្ជាក់ន័យឱ្យគុណភាពនៃវត្ថុ ឥរិយាបថ អាកប្បកិរិយា របស់មនុស្ស។ តម្លៃគុណភាពផ្នែកខាងក្នុងរបស់បុគ្គល។
  - សីលតម្លៃ៖ ជាតម្លៃទទួលបានពីការស្គាល់ និង ប្រតិបត្តិអំពើល្អ បុណ្យកុសល។
  - តម្លៃសាសនា៖ជាតម្លៃនៃចិត្តស្នេហាមោះមុត លើស្មារតីនៃគោលគំនិត ទស្សនៈទ្រឹស្តីអប់រំទូន្មានត្រឹមត្រូវ។

[1] ដកស្រង់ពី៖ (ទ្រឹស្តីសីលធម៌, សាស្ត្រាចារ្យ ញឹម បាក់ងន) មេរៀនសម្រាប់និស្សិតទស្សនវិជ្ជា

### ២.២. បញ្ញត្តិយុគសម័យឌីជីថល

- ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលគឺ "**សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) ទៅក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច និងសង្គម តាមរយៈការប្រើប្រាស់ និងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញកំណើន និង លើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ជាមួយនឹងការកសាងសង្គម ស៊ីវិល័យ ដែលឈរលើមូលដ្ឋានពលរដ្ឋឌីជីថល (Digital Citizen) ដែលទទួលបាននូវការប្រើប្រាស់សេវាឌីជីថល ប្រកបដោយ បរិយាបន្នកម្ម, ជំនឿទុកចិត្ត និង សុវត្ថិភាពខ្ពស់ទន្ទឹមនឹងការរក្សាបាននូវអត្តសញ្ញាណ និងវប្បធម៌ជាតិ**"[2] ។ ការសម្រេចបាននូវការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើទំនើបកម្មវិស័យនានាក្នុងសេដ្ឋកិច្ច និង សង្គម នឹងនាំឱ្យកម្ពុជាឈានឆ្ពោះទៅរកបដិវត្តន៍ឧស្សាហកម្មទី៤។

## ៣. បរិវត្តកម្មឌីជីថល

### ៣.១. បរិវត្តកម្មឌីជីថលនៃការអប់រំ

ពិតណាស់ ដើម្បីឱ្យទទួលបាននូវសេដ្ឋកិច្ចបែបឌីជីថល លុះត្រាតែមានការអប់រំបែបឌីជីថល។ ដូចនេះ ការអប់រំឌីជីថលក្នុងបរិបទឧស្សាហកម្ម៤.០ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា ក្នុងការបោះជំហានឱ្យក្លាយជា ប្រទេសដែលមានសេដ្ឋកិច្ចបែបឌីជីថល និងរដ្ឋាភិបាលឌីជីថល ព្រោះផ្នែក ទាំងអស់នេះត្រូវការអ្នកជំនាញជាច្រើនដើម្បីបំពេញការងារ និងគ្រប់គ្រង ប្រព័ន្ធវៃឆ្លាតទាំងអស់នោះ។

### ៣.១.១. បរិស្ថានសម្រាប់ការអប់រំឌីជីថល

នៅក្នុងយុគសម័យឌីជីថល បច្ចេកវិទ្យាមានតួនាទីយ៉ាងសំខាន់ក្នុង ការសិក្សា។ គ្រូបង្រៀន និងសិស្សអាចប្រើកុំព្យូទ័រ ទូរស័ព្ទដៃ ឧបករណ៍ អេឡិចត្រូនិកផ្សេងទៀត ប្រព័ន្ធបណ្តាញសង្គម ដូចជា Facebook, YouTube, WhatsApp, Telegram, Apps, Google, Microsoft Team ដើម្បីបង្កើតជាប្រព័ន្ធសិក្សាអេឡិចត្រូនិក និងវេទិកាឌីជីថល ដើម្បីសម្រួលដល់ការសិក្សា។ ការរៀបចំបរិស្ថានសម្រាប់ការសិក្សាក្នុងយុគសម័យឌីជីថល គឺជាកត្តាគន្លឹះនៃការអប់រំឌីជីថល។

**បរិស្ថានសម្រាប់ការសិក្សានៅក្នុងយុគសម័យឌីជីថលរួម មាន៖**




[2] ក្របខណ្ឌគោលនយោបាយសង្គមកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ បោះពុម្ព២០២១

**ក. ប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System-L.MS)៖**

- ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្តល់ការអប់រំអេឡិចត្រូនិក តាមរយៈការប្រើប្រាស់ កម្មវិធី Apps ដូចជា Google suit, Moodle, BlackBoard ដែលជាប្រព័ន្ធធំ និង ស្មុគស្មាញ ដើម្បីគ្រប់គ្រងការរៀន និងបង្រៀនពីចម្ងាយតាមបែប អេឡិចត្រូនិក ដោយគ្រូបង្រៀនផ្សាយពីចម្ងាយដោយប្រើប្រាស់បទបង្ហាញ Power- Point, ហើយ សិស្សចូល រៀននៅក្នុងបន្ទប់រៀនសិប្បនិម្មិត(Virtual) និងមានបន្ទប់ពិភាក្សាដំណភ្ជាប់វេបសាយ(Weblink) បណ្ណាល័យ ប្រតិទិន និង ធនធានសិក្សាផ្សេងទៀត។
- ប្រព័ន្ធគ្រប់គ្រងការសិក្សាខ្លះមានលក្ខណៈជាវេបសាយ ដែលសិស្ស អាចចុះឈ្មោះចូលរៀនតាមមុខវិជ្ជា និង តាមកម្រិតថ្នាក់ ដោយគ្មានគ្រូបង្រៀន ហើយមានការធ្វើតេស្តជាស្វ័យប្រវត្តិតាមម៉ូឌុលមុននឹងអាចឡើង ថ្នាក់ រៀនក្នុងកម្រិតខ្ពស់ជាងមុន។ ប្រព័ន្ធនេះជួយសម្រួលឱ្យសិស្សអាចចូលរៀនពេលណាក៏បានពីទីណាក៏បាន ជា ពិសេសងាយស្រួលរៀនសម្រាប់សិស្សដែលនៅក្រៅសាលារៀនដូចជាកម្មវិធីសមមូលអប់រំមូលដ្ឋាន (BEEP)
- ក្រុមហ៊ុនឯកជនមួយចំនួន បានបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា សម្រាប់សាលារៀនមួយៗ ដោយមានប្រព័ន្ធ គ្រប់គ្រងវត្តមានសិស្សប្រព័ន្ធ គ្រប់គ្រងការរៀននិងបង្រៀន ប្រព័ន្ធគ្រប់គ្រងធនធានសិក្សា និងប្រព័ន្ធទំនាក់ ទំនងជាមួយមាតាបិតាផង។
- គេអាចបង្កើតកម្មវិធីកុំព្យូទ័របែប Apps ដែលផ្ទុកនូវខ្លឹមសារឌីជីថល ជាវីដេអូមេរៀនគ្រប់មុខវិជ្ជា និងគ្រប់ កម្រិតថ្នាក់រៀន ដើម្បីជួយសិស្សក្នុងការទាញយក និងផ្ទុកក្នុងកុំព្យូទ័រផ្ទាល់ខ្លួន ឬទូរស័ព្ទដៃដើម្បីធ្វើការសិក្សា ជាលក្ខណៈឯកជន។

**ខ. ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្ទាល់ខ្លួន (Personal Learning System-PLS)៖**

- គឺជាឧបករណ៍គាំទ្រដល់ការសិក្សាផ្ទាល់ខ្លួន ដោយប្រើប្រាស់ឧបករណ៍ អេឡិចត្រូនិក។ សិស្សអាចទាញយក ខ្លឹមសារឌីជីថល ជាអត្ថបទ បទបង្ហាញPowerPoint ឬវីដេអូ ដើម្បីរក្សាទុកក្នុងឧបករណ៍អេឡិចត្រូនិកផ្ទាល់ ខ្លួនទុក សម្រាប់សិក្សានៅកន្លែងណា និងពេលណាដែលខ្លួនចង់រៀន។ សិស្ស និងគ្រូអាចចងក្រុមជា បណ្តាញ អ្នកសិក្សា ដោយប្រើប្រាស់កម្មវិធី Telegram, Messenger ឬ WhatsApp ដើម្បីផ្លាស់ប្តូរព័ត៌មាន ចែករំលែក ធនធានសិក្សា និងពិគ្រោះយោបល់។

**គ. ការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាស (Hipped Classroom)៖**

- នៅក្នុងការ បង្រៀនសិស្សតាមបែបប្រពៃណី គ្រូបង្រៀនមេរៀនដោយផ្ទាល់ និងផ្តល់បាឋកថានៅក្នុងថ្នាក់រៀន ចំណែកសិស្សត្រូវកត់មេរៀន និងស្តាប់គ្រូពន្យល់ ក្នុងថ្នាក់រៀន។
- នៅក្រៅថ្នាក់រៀន សិស្សត្រូវធ្វើកិច្ចការនៅផ្ទះសរសេរគម្រោង និងធ្វើការអនុវត្តលើមេរៀន។ នៅក្នុងបរិបទនៃ ការអប់រំឌីជីថល គេអាចអនុវត្តការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាស ដោយសិស្សអាចប្រើប្រាស់ ខ្លឹមសារមេរៀន បទ បង្ហាញដែលគ្រូបានថតជាវីដេអូ និងធនធានសិក្សា អេឡិចត្រូនិកដទៃទៀត ដែលទទួលបានតាមអ៊ីនធឺណិត និងយូធូប ដើម្បីសិក្សាស្រាវជ្រាវមេរៀននៅផ្ទះ ទៅតាមល្បឿនដែលខ្លួនចង់។ នៅក្នុងថ្នាក់ រៀន គ្រូមានតួនាទី ជាអ្នកសម្របសម្រួលការពិភាក្សា ការធ្វើពិសោធន៍ ផ្តល់ ការគាំទ្រ និងមតិត្រឡប់។ ការសិក្សាក្នុងថ្នាក់រៀន បញ្ច្រាស គឺប្រែក្លាយថ្នាក់រៀនទៅជាកន្លែងសិក្សាតាមបែបសហការប្រកបដោយជវភាព[3] និងលើកកម្ពស់អន្តរ សកម្មសង្គម ដែលជួយពង្រឹងគុណភាពនៃលទ្ធផលសិក្សា និងការចងចាំរបស់សិស្ស។

---

[3] ពាក្យ«**ជវភាព**»មានន័យថា ដំណើរនៃល្បឿនរហ័ស, រយៈពេលដែលស្ទុះពីកន្លែងមួយទៅកន្លែងមួយទៀត។ ពាក្យនេះ ប្រើសំដៅ លើល្បឿននៃចិត្ត ដែលមានន័យជវភាពរបស់ចិត្តអាចប្រព្រឹត្តទៅបានសព្វ។

### ៣.១.២. អក្ខរកម្មឌីជីថល

យុគសម័យឌីជីថលបានផ្លាស់ប្តូរអត្ថន័យអក្ខរកម្ម ពីអក្ខរកម្មតាមបែបប្រពៃណី ទៅរកអក្ខរកម្មឌីជីថល (Digital literacy)។ អក្ខរកម្មឌីជីថល គឺជាបំណិនដែលចាំបាច់សម្រាប់ការសិក្សាការរស់នៅ និងការបំពេញការងារនៅក្នុងសង្គមនៃសតវត្សទី២១ ដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដូចជា វេទិកាអ៊ីនធឺណិត បណ្តាញសង្គម និងឧបករណ៍អេឡិចត្រូនិកចល័ត។

អក្ខរកម្មឌីជីថលមានសមាសភាគ៣ ផ្នែកសំខាន់ៗ គឺ ៖ (១) 3Rs (២) 8Cs និង (៣) 2Ls។




### ៣.១.៣. ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា

ការអប់រំបែបឌីជីថល គឺជាការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យា ឌីជីថល ក្នុងការរៀន និងការបង្រៀន ក៏ដូចជាការគ្រប់គ្រងដែរ។ ចាប់តាំងពីដើមសប្តាហ៍ទី២ នៃខែមីនា ឆ្នាំ២០២០ បន្ទាប់ពីការរកឃើញករណីការ ឆ្លងជំងឺកូវីដ ១៩ នៅខេត្តសៀមរាប ក្រសួងអប់រំយុវជន និងកីឡា បានផ្អាក ដំណើរការគ្រឹះស្ថានសិក្សាជាបណ្តោះអាសន្ន និងបានរៀបចំការសិក្សាតាមបែបអេឡិចត្រូនិក ។

ការរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក និងការផ្តល់សេវារៀនពីចម្ងាយ ដោយបានដាក់ចេញវិធានការជា ៣ ដំណាក់កាល រួមមាន ៖

- ដំណាក់កាលបន្ទាន់៖ ការបង្កើតគណៈកម្មការពិសេសមួយ សម្រាប់ផលិតវីដេអូ បង្រៀនសម្រាប់មុខវិជ្ជាគោល និង សម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះ និងផ្សព្វផ្សាយ លើវេទិកា ឌីជីថលដែលមានស្រាប់
- ដំណាក់កាលមធ្យម ៖ ការកែលម្អវេទិកាឌីជីថលដែលមាន ស្រាប់របស់ក្រសួងអប់រំយុវជននិងកីឡាឱ្យបានកាន់តែប្រសើរ និងការផលិតវីដេអូបង្រៀនដែលចាំបាច់ បន្ថែមទៀត
- ដំណាក់កាលវែង ការរៀបចំកែលម្អ និងអភិវឌ្ឍវេទិកា ឌីជីថលសម្រាប់ផ្តល់សេវាអប់រំ តាមប្រព័ន្ធអេឡិចត្រូនិកដែល មានលក្ខណៈសមរម្យ និងគ្រប់ជ្រុងជ្រោយ។

ក្នុងអំឡុងពេលនៃវិស្សមកាលមុនពេលកំណត់ ដើម្បីជាជំនួយដល់ ការសិក្សារបស់សិស្សានុសិស្ស ទាំងអស់នៅថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ក្រសួងអប់រំយុវជន និងកីឡាបានរៀបចំ វិធានការមួយចំនួនជាបន្តបន្ទាប់ ដូចជាការបង្កើតកម្មវិធីសិក្សា «**ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក**» ដែលទទួលបានការគាំទ្រ

និងការចូលប្រើប្រាស់ ពីសំណាក់សិស្សានុសិស្សជាច្រើន ដោយមានការសហការ និងការចូលរួម ពីសំណាក់វិស័យឯកជន និងអ្នកជំនាញបច្ចេកវិទ្យាមួយចំនួន សិស្សានុសិស្សក៏អាចទទួលបានឱកាសពីការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះកាន់ តែសម្បូរបែប។

ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគណៈកម្មការតាមអនុវិស័យ និងបានជ្រើសរើសលោកគ្រូ អ្នកគ្រូដែលមានបទពិសោធន៍ក្នុងការបង្រៀន មកថតវីដេអូបង្រៀន និងបានជ្រើសរើសបន្ទប់សម្រាប់ថតបណ្ដោះអាសន្ន មួយចំនួនដូចជា៖ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នាយកដ្ឋាន បឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច។

ក្រសួងបានចេញសេចក្ដីណែនាំស្ដីពីការលើកកម្ពស់ការបង្រៀន និង រៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិកដល់គ្រឹះស្ថានសិក្សាចំណោះទូទៅ មាតាបិតា អាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមជំរុញការអនុវត្ត និងធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការបង្រៀននិង រៀន និងការវាយតម្លៃ។

សកម្មភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា សំខាន់ៗនៅក្នុងដំណាក់កាលបន្ទាន់រួមមាន៖




*ការអនុវត្តការអប់រំឌីជីថលនៅកម្ពុជា។*

## ៣.២. បំណិនសតវត្សរ៍ទី២១ ក្នុងយុគឌីជីថល

### ៣.២.១. ការបណ្ដុះបំណិនសតវត្សរ៍ទី២១

បរិវត្តកម្មឌីជីថលនេះទាមទារនូវការបណ្ដុះបណ្ដាលជំនាញថ្មី ដើម្បីឆ្លើយតបទៅនឹងនិន្នាការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា។ តាមការព្យាករណ៍របស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF), នៅក្នុងរយៈពេល១០ឆ្នាំ ខាងមុខ បំណិនចំនួន៣៥% ដែលចាំបាច់សម្រាប់ទីផ្សារការងារនឹងប្រែប្រួលខុសពីសព្វថ្ងៃ។ បរិវត្តកម្មឌីជីថលនេះនឹងធ្វើឱ្យមានការផ្លាស់ប្ដូរនៃតម្រូវការ ជំនាញ ដោយសារតែស្វ័យប្រវត្តិនីយកម្ម។

ដោយសារតែការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនេះ គេមិនអាចព្យាករណ៍បានថា សិស្សដែលកំពុងសិក្សានៅក្នុងសាលារៀននាពេលបច្ចុប្បន្ននេះ ត្រូវមាន«បំណិនបច្ចេកទេស»អ្វីខ្លះ ដើម្បីតម្រូវតាមទីផ្សារពលកម្មនាពេលអនាគត។ បំណិនសតវត្សរ៍ទី២១ សំដៅលើបំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារការងារដែលយុវជនកម្ពុជាត្រូវមាន។ បំណិនសតវត្សរ៍ទី២១ គឺជាជំនាញជួយពង្រឹង និងអភិវឌ្ឍសមត្ថភាពសិស្សានុសិស្ស ដើម្បីទទួលបានជោគជ័យក្នុងអាជីពការងារនាសម័យបច្ចេកវិទ្យាទំនើបនេះ។

ការច្នៃប្រឌិតថ្មី និងនវានុវត្តន៍ គឺជាបំណិនដែលជួយឱ្យសិស្សអាចប្រកួតប្រជែងបាន នៅក្នុងសតវត្សរ៍ទី២១។ សិស្សត្រូវមានបំណិនសតវត្សរ៍ទី២១ ដូចជាបំណិនត្រិះរិះពិចារណា សហការបង្កើតថ្មី ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហាសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងនយោបាយ។

**បំណិនសតវត្សរ៍ទី២១ ត្រូវបានបែងចែកជាសមាសភាគ៣ គឺ៖**




*ការបណ្ដុះបំណិនសតវត្សរ៍ទី២១*

យុវជនសតវត្សរ៍ទី២១ ត្រូវមានបំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈឱ្យបានច្បាស់លាស់។ បំណិនទន់ និងបំណិនបុរេវិជ្ជាជីវៈ សំដៅលើបំណិនដែលទាក់ទងនឹងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនមាន របៀបកសាងទំនាក់ទំនង ការធ្វើសហប្រតិបត្តិការ ការងារជាក្រុម និងការបង្កើតថ្មីជាដើម។

### ៣.២.២. កំណែទម្រង់វិស័យអប់រំ ដើម្បីលើកកម្ពស់បរិវត្តកម្មឌីជីថល

ដើម្បីអនុវត្តការអប់រំបែបឌីជីថលឱ្យបានកាន់តែប្រសើរ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំកម្មវិធីកំណែទម្រង់វិស័យអប់រំ ដើម្បីដាក់ទុនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ជាពិសេសការពង្រឹងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព(SBM) ការបង្កើតសាលាជំនាន់ថ្មី (NGS)ការធ្វើកំណែទម្រង់វិធីសាស្ត្របង្រៀន ការកែលម្អបរិស្ថានសិក្សា និងការលើកកម្ពស់ការសិក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា(STEM)ជាដើម។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សផ្នែកឌីជីថល ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឱ្យមានសាលាជំនាន់ថ្មី ដែលបញ្ចូលនូវកម្មវិធីសិក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងការបណ្តុះបណ្តាលការសរសេរកូដ រួមទាំងកម្មវិធីសិក្សា ដែលជាជំនាញទន់ជាច្រើនទៀត ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងសតវត្សទី២១។ លើសពីនេះទៅទៀត ក្រសួងក៏បានរៀបចំអប់រំចំណេះដឹងមូលដ្ឋានគ្រឹះ សម្រាប់ការអប់រំដោយឆ្លើយតបទៅនឹងយុគសម័យបច្ចេកវិទ្យា តាមរយៈការធ្វើកំណែទម្រង់សាលារៀន និងកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ ដោយធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់ផ្នែកបច្ចេកវិទ្យា មុននឹងចែករំលែកបន្តទៅដល់សិស្សានុសិស្ស ដែលជាធនធានមនុស្សជំនាន់ថ្មី ដើម្បីចូលរួមប្រកួតប្រជែងក្នុងទីផ្សារការងារ។ សិស្សានុសិស្ស ឬនិស្សិត ដែលជាយុវជនជំនាន់ក្រោយមានឱកាសកាន់តែច្រើនក្នុងការសិក្សាឱ្យបានកាន់តែទូលំទូលាយពីបច្ចេកវិទ្យា។ លក្ខខណ្ឌនេះ ជាឱកាសក្នុងការទាញយកចំណេះដឹង ដែលមានជុំវិញពិភពលោក ដើម្បីអភិវឌ្ឍសមត្ថភាពខ្លួនឯង។ ហេតុនេះ សិស្សនិស្សិតគួរចេះស្វែងរកប្រភពចំណេះដឹងមូលដ្ឋាន សម្រាប់អភិវឌ្ឍសមត្ថភាពក្នុងយុគសម័យឌីជីថល។

ដើម្បីអនុវត្តចក្ខុវិស័យនេះ ក្នុងបំណងផ្តល់ការអប់រំប្រកបដោយគុណភាព និងសាលារៀនសម្រាប់អនាគត ក្រសួងបានបង្កើតសាលារៀនជំនាន់ថ្មីចំនួន១១កន្លែង ដើម្បីសាកល្បងកំណែទម្រង់ការអប់រំជាប្រព័ន្ធ។ យើងមើលឃើញគុណភាពអប់រំមានភាពល្អប្រសើរជាងមុន ហើយសិស្សានុសិស្សត្រូវបានបំពាក់ដោយជំនាញរឹង និងជំនាញទន់ ជាពិសេសគំនិតផ្តួចផ្តើមថ្មី ការគិតត្រិះរិះ និងការដោះស្រាយបញ្ហា។ ក្រសួងទើបតែបានជ្រើសរើសសាលារៀនចំនួន ១០០បន្ថែមទៀត ដើម្បីបង្កើតសាលារៀនគំរូកម្រិតទី២ ដែលយើងអនុវត្តក្នុងគម្រោង«ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព(SEIP)»។ ទន្ទឹមនឹងនេះ យើងក៏បានដាក់ចេញគោលដៅប្រែក្លាយសាលាធនធានចំនួន៥០ ឱ្យក្លាយជាសាលាគំរូដែរ។ គោលដៅរបស់យើង គឺការបង្កើត «**សាលារៀនឆ្លាតវៃ**» សម្រាប់យុគសម័យឌីជីថល។

ការលើកកម្ពស់ការអប់រំឌីជីថល ទាមទារនូវបរិវត្តកម្មប្រព័ន្ធអេកូឡូស៊ីនៃការអប់រំឌីជីថល ដូចជាការបង្កើតទំនាក់ទំនងរវាងការអប់រំឌីជីថល នៅក្នុងសាលារៀន (សិស្ស គ្រូ សកម្មភាពថ្នាក់រៀន និងកម្មវិធីសិក្សា) ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាសារៀនដោយប្រើប្រាស់បច្ចេកវិទ្យា ការរៀបចំការប្រកួតមនុស្សយន្ត ការតស៊ូមតិ ពិព័រណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការតម្រង់ទិសវិជ្ជាជីវៈ ការផ្សារភ្ជាប់ទៅនឹងអនុវិស័យឧត្តមសិក្សា និងការហាត់ការនៅក្នុងក្រុមហ៊ុនឯកជន។ តាមបទពិសោធន៍ គម្រោងដែលអនុវត្តកន្លងមកឃើញថា ការអប់រំបែបឌីជីថលនេះទាមទារនូវបុគ្គលិកលក្ខណៈខ្លាំង ដូចជាការចេះធ្វើការជាក្រុម ចំណេះដឹងខាងផ្នែកឧបករណ៍ឌីជីថល។

ដូចនេះកំណែទម្រង់បានជោគជ័យអាស្រ័យដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពិសេសភាគីក្នុងសាលារៀនផ្ទាល់ ដែលត្រូវតែមានស្មារតីចូលរួមពិតប្រាកដ និងមនសិការការងារច្បាស់លាស់ ប្រឹងប្រែងដើរតាមមាគ៌ាដែលក្រសួងបានត្រួសត្រាយ ពិសេសទទួលយកការស្វ័យសិក្សាឌីជីថល ទើបអាចសម្រេចនូវគោលដៅដែលបានកំណត់។ គុណតម្លៃមនុស្សក្នុងយុគឌីជីថលនេះ ចាំបាច់ណាស់ត្រូវការបុគ្គលិកវៃឆ្លាត រហ័សតាមទាន់ការវិវឌ្ឍរបស់សកលលោក និងដុតដៃដុតជើង ដោយទឹកចិត្តចង់ឱ្យសង្គមមានការអភិវឌ្ឍពិតប្រាកដ។

## ៤. គុណសម្បទា និងគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល

### ៤.១. គុណតម្លៃស្វ័យសិក្សាក្នុងបរិបទទំនើប

មនុស្សពូកែខាងនវកម្មគំនិត និងគំនិតច្នៃប្រឌិត គឺមានវិជ្ជាគិតកម្រិតខ្ពស់ គិតច្រើនទិស និងមានវិសាលភាពនៃគំនិត។ បុគ្គលគ្រប់រូប គ្រប់វ័យ គ្រប់ភេទ និងគ្រប់អាជីព ត្រូវយកវិជ្ជាគិតទៅប្រើការគ្រប់កាល និងបរិបទ។ បុគ្គលពូកែយកវិជ្ជាគិតកម្រិតខ្ពស់ ទៅផ្លាស់ប្តូរបំណង លទ្ធផល ដំណើរការ និងប្តូរខ្លួនឯង ទៅរកប្រយោជន៍មនុស្សជាតិ។

ហេតុនៃបរាជ័យធំក្នុងមុខរបរ ដោះស្រាយបញ្ហា និងជីវិតរបស់មនុស្សភាគច្រើន គឺ១. ធ្វើដោយពុំបានគិត និង ២.គិតជាហូរហែតែពុំចាប់ផ្តើមធ្វើ។ បុរាណពោលថា "**ចង់បានផលកុំត្រឹមគិត ត្រូវចាប់ផ្តើមធ្វើកុំបង្អង់**"។ ការគិតក្នុងពាក្យទូន្មាននេះ ប្រហែលជាសំដៅដល់ការគិត ដែលខ្វះរចនាសម្ព័ន្ធនៃគំនិត។ នវកម្មគំនិត សំដៅដល់ការបង្កើតរចនាសម្ព័ន្ធនៃគំនិត។ នវកម្មគំនិតកើតចេញពីការឆ្ងល់ គិត បង្កើតសំណួរ សួរ និងរកការពន្យល់។ ការឆ្ងល់ គិត បង្កើតសំណួរ និងសួរសំណួរ ជាចំណុចចាប់ផ្តើមនៃការផ្លាស់ប្តូរ និងបើកផ្លូវគិតទៅរកការបង្កើតថ្មី។ នវកម្មគំនិតបើកផ្លូវនៃការគិត និងពង្រីកវិសាលភាពនៃគំនិតទៅ **រកបដិវត្តន៍ឧស្សាហកម្ម៥.០**បន្តទៀត។[4]

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៤.៤ (SDG Target 4.4) សំដៅបង្កើនចំនួនមនុស្សពេញវ័យ និងយុវវ័យឱ្យមានវិជ្ជាឌីជីថល។ អង្គការUNESCO បានចងក្រងក្របខ័ណ្ឌអនុវត្តកម្មវិធីអភិវឌ្ឍន៍វិជ្ជា និងគុណតម្លៃឌីជីថលក្នុងឆ្នាំ ២០១៨ (United Nations Educational, Scientific and Cultural Organization, 2018)។ គ្រូបង្រៀនកម្ពុជាក៏ត្រូវអភិវឌ្ឍវិជ្ជា និងគុណតម្លៃឌីជីថលជាចាំបាច់ ដើម្បីបំពេញតម្រូវការរៀនបន្ត និងដឹកនាំសិស្សរៀនឱ្យដល់កម្រិតវិជ្ជា។ កម្រិតវិជ្ជាសំដៅដល់សមត្ថភាពប្រើឌីជីថលក្នុងវិជ្ជាជីវៈ និងគ្រប់បរិបទ។

គ្រូបង្រៀន និងសិស្សអភិវឌ្ឍវិជ្ជា និងគុណតម្លៃឌីជីថល គឺមានសមត្ថភាពរក និងប្រើឯកសារពីអន្តរបណ្តាញអ៊ីនធឺណែត ប្រកបដោយការទទួលខុសត្រូវ និងក្រមសីលធម៌។ ស្វ័យសិក្សាក្នុងបរិបទឌីជីថលនេះ គឺត្រូវតែប្រឹងប្រែងខ្លាំងបំផុត ដើម្បីឱ្យចេះប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកក្នុងការស្វែងរកចំណេះដឹង ស្រាយចម្ងល់ ដូចជាការប្រើប្រាស់បណ្តាញសង្គមFacebook ការបើកYouTube ដើម្បីរកមើលវីដេអូ និងប្រើGoogleរកឯកសារ ការមានកុំព្យូទ័រយួរដៃស្ទាត់ជំនាញ ប្រើកុំព្យូទ័រ វាយអត្ថបទបានលឿន ប្រើកម្មវិធីច្រើនបែបច្រើនយ៉ាងទៀត។

### ៤.២. គុណតម្លៃមនុស្ស

មនុស្សខ្ពង់ខ្ពស់ពោរពេញដោយគុណតម្លៃមនុស្ស គឺ រស់នៅប្រាស្រ័យ មនុស្សធ្វើការ និងរៀនសូត្រប្រកបដោយធម៌។ គុណតម្លៃបុគ្គលពុំអាចសាបសូន្យ ក្នុងជាតិនេះ និងជាតិមុខ (Khmer Buddhism Institute, 1931)។ បុគ្គលខ្ពង់ខ្ពស់ប្រកបដោយធម៌ តែងនាំមនុស្សទូទៅឱ្យចម្រុងចម្រើន ព្រោះតែងផ្តល់ទានដល់មនុស្សទូទៅ គឺទានជាទ្រព្យ (អាមិសទាន) និងទានជាបញ្ញា(ធម្មទាន)។ មនុស្សខ្ពង់ខ្ពស់ពោរពេញដោយគុណតម្លៃ គឺតែងប្រព្រឹត្តសេចក្តីល្អ និងសេចក្តីពិតជាប្រចាំ។ បុគ្គលប្រព្រឹត្តសេចក្តីល្អ សេចក្តីពិត និងការពារសុចរិតភាព គឺពោរពេញដោយសុជីវធម៌ សីលធម៌ និងគុណធម៌ ។ បុគ្គលពោរពេញដោយសុជីវធម៌ សីលធម៌ និងគុណធម៌ តែងរុងរឿងគ្រប់កាល។ ពាក្យថា "សុជីវធម៌ សីលធម៌ និងគុណធម៌" ជាបញ្ញត្តិអប់រំតម្លៃផ្ទាល់ខ្លួនកើតចេញពីចិត្ត និងទង្វើរបស់មនុស្សគ្រប់រូបនៅក្នុងសង្គម។ នៅក្នុងសង្គមខ្មែរ ធម៌ទាំងបីនេះ មានគុណតម្លៃប្រហាក់ប្រហែលគ្នា ហើយត្រូវបានចាត់ទុកថាជាសេចក្តីល្អក្នុងដំណើរជីវិត ប្រសិនបើបុគ្គលប្រព្រឹត្ត ឬប្រកាន់ខ្ជាប់ខ្លួនតាមអត្ថន័យពិតប្រាកដ។ សុជីវធម៌ សីលធម៌ និងគុណធម៌ កើតចេញពីមូលដ្ឋាននៃបញ្ញត្តិសុភាវធម៌។ សុភាវធម៌ ជាក្រឹត្យក្រមអប់រំមនុស្សឱ្យមានដំណើរជីវិតរស់នៅល្អប្រពៃ។

[4] ខៀវ វិជ្ជានន្ទ និងបណ្ឌិត យួន វិច្ឆិកា សិក្សាបញ្ញត្តិដើម្បីអភិវឌ្ឍគុណសម្បទាសតវត្សទី២១ , ២០២១

### ក. គុណតម្លៃសុជីវធម៌

សុជីវធម៌ គឺសំដៅដល់អាកប្បកិរិយា ឬឥរិយាបថនៃការដេក ដើរ ឈរ អង្គុយប្រកបដោយសេចក្តីល្អ តាមរយៈការសម្តែងការគោរពគួរសម។ សុជីវធម៌ ជាគុណតម្លៃមួយរបស់បុគ្គលខ្ពង់ខ្ពស់ និងសម្រាប់យកទៅប្រាស្រ័យជាមួយមនុស្សក្នុងការងារ រៀន និងរស់នៅដោយសេចក្តីល្អ និងសេចក្តីពិត (Khmer Buddhism Institute, 1931)។ បុគ្គលប្រតិបត្តិសុជីវធម៌ជាប្រចាំតែងយល់ និងស្គាល់ប្រមាណអំពីសេចក្តីអាក្រក់ និងល្អ ភាពសមរម្យនិងពុំសមរម្យ ក្នុងគ្រប់បរិបទសង្គម ជីវភាពប្រចាំថ្ងៃ ការងារ និងការរៀនសូត្រ ។ នៅក្នុងវចនានុក្រមខ្មែរ បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានពន្យល់ពាក្យទាំងនេះថា សុជីវធម៌ សម្តៅដល់ការរស់នៅដោយល្អ គឺចំណេះ, មានសណ្តាប់ធ្នាប់, ការដឹងប្រមាណគួរសមក្នុងកិច្ចការប្រាស្រ័យជាមួយនឹងអ្នកដទៃ។ សុជីវធម៌ សម្តៅលើឥរិយាបថរបស់សុភាពរាបសារ កាយវិការសមរម្យ ស្គាល់កាលវេលា ចេះគួរសមឱនលំទោនគោរពចាស់ទុំ មានវាចាផ្អែមពីរោះ រស់នៅសង្គមទទួលស្គាល់និងផ្តល់តម្លៃ ព្រមទាំងមានឥរិយាបថគាប់ភ្នែកអ្នកផង មិនប្រើសម្តីគំរោះគំរើយ ឬស្តាប់ទៅមិនស្រួលត្រចៀក។

ស្ថិតក្នុងបរិវត្តកម្មវិស័យអប់រំនេះ សុជីវធម៌ដើរតួយ៉ាងសំខាន់ក្នុងការនាំផ្លូវមនុស្សជាប្រចាំឱ្យប្រតិបត្តិល្អ ចេះគោរពឱនលំទោន និងមានចិត្តធំទូលាយ ស្តាប់សម្តីនៃអ្នកផ្សេង ដោយយកចិត្តទុកដាក់ និងស្ងៀមស្ងាត់ និយាយសម្តីនិងឆ្លើយតប ដោយមេត្រីភាព និងក្តីស្រឡាញ់។

### ខ. គុណតម្លៃសីលធម៌

សីលធម៌គឺសំដៅដល់ធម្មជាតិនៃសេចក្តីល្អ សម្គាល់ដោយមនុស្សដែលមានសេចក្តីល្អ ស្អាតផូរផង់ចេញពីក្នុងជម្រៅចិត្ត។ សីលធម៌ជាធាតុមិនអាចខ្វះបានសម្រាប់បុគ្គលគ្រប់រូប របកគំហើញ នៃការស្រាវជ្រាវអំពីការអប់រំ។ ប្រព័ន្ធអប់រំទាំងអស់បង្កើតមុខវិជ្ជារៀនក្នុងសាលា ហៅថា អប់រំសីលធម៌។ កម្មវិធីសិក្សារបស់កម្ពុជា មានមុខ វិជ្ជាមួយគឺ សីលធម៌ ពលរដ្ឋវិជ្ជា ។ ការបង្កើតសាលារៀន និងការផ្តល់មុខងារជា គ្រូបង្រៀន សំដៅបំពាក់សីលធម៌ឱ្យសិស្សដើម្បីយកទៅបម្រើការក្នុងសង្គម។ មាតាបិតាបញ្ជូនកូនទៅសាលារៀន ក៏មានចេតនាឱ្យកូនរៀនចេះដឹង មានវិជ្ជា និងសីលធម៌ជាបុគ្គលខ្ពង់ខ្ពស់ដែរ។ គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា (Khmer Buddhism Institute, 1931) ពន្យល់ថា បុគ្គលពោរពេញដោយសីលធម៌តែង៖ មានសម្តីពីរោះ ឬនិយាយពាក្យពីរោះ ពោលពាក្យទន់ភ្លន់ ផ្អែមល្ហែម ពោលវាចាចាកទោស ដូចជាពុំនិយាយខុសការពិត ពុំនិយាយឱ្យអ្នកផងព្រួយចិត្ត មានសម្តីញ៉ាំងអ្នកស្តាប់ឱ្យចូលចិត្តជាក់លាក់។ល។

សីលធម៌ ឬសីលធម្ម មានន័យថា កិរិយាមារយាទ, សណ្តាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ប្រព្រឹត្តតែអំពើល្អប្រកបដោយសីលធម៌។ សីលធម៌ សម្តៅទៅលើភាពត្រឹមត្រូវរបស់មនុស្សដែលប្រកាន់ខ្ជាប់ក្នុងចិត្ត ទោះជាមានអ្នកដទៃដឹង ឬមិនដឹងក៏ដោយ។ ជាក់ស្តែងដូចជាការតាំងចិត្តមិនធ្វើអំពើអាក្រក់ ឬមិនប្រព្រឹត្តទង្វើមិនគប្បីណាមួយទាំងកាយ វាចា និងចិត្ត ដែលបង្កការឈឺចាប់ដល់អ្នកដទៃ។

### គ. គុណតម្លៃគុណធម៌

គុណធម៌ជាសម្បត្តិនៃបុគ្គលខ្ពង់ខ្ពស់ បុគ្គលខ្ពង់ខ្ពស់រមែងមានរូបល្អ និងអាស្រ័យផលនៃវាចា និងការប្រព្រឹត្តិសុចរិត ដោយអង្គនៃសុជីវធម៌ សីលធម៌ និងបញ្ញាបុគ្គលពោរពេញដោយគុណធម៌ រមែងជាបុគ្គលមានបេះដូងជាអ្នកឈឺឆ្អាលទើសនឹងភាពទុច្ចរិត និងជាអ្នកជួយ (Khmer Buddhism Institute, 1931) ប្រកាន់ចិត្តសន្តោស ស្រឡាញ់ និងសង្គ្រោះបំពេញកិច្ច ដោយអស់ពីចិត្ត និងឃ្នាតខ្មីនឹងការងារ ពុំខ្ជីខ្ជាគ្រប់កិច្ចការ តូចក្តី ធំក្តី ពុំប្រមាទចំពោះរាល់កិច្ច ពុំលះបង់ចោលក្តីសង្ឃឹម។ល។

បុគ្គលមានគុណធម៌ រមែងការគោរពដោយសន្តោសអត់ឱន មិនច្រណែន មិនព្យាបាទ មិនគុំគួន មិនធ្វើបាប ចេះយោគយល់អធ្យាស្រ័យដោយសេចក្តីមេត្តា ចេះលះបង់ និងចេះជួយគ្នាក្នុងគ្រាក្រលំបាក។

### ៤.៣. គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល

### ក. គុណតម្លៃសីលធម៌ក្នុងសង្គមឌីជីថល

មិនថាសង្គមរីកចម្រើនដល់ណាទេ មិនថាបដិវត្តឧស្សាហកម្ម៤.០នេះ ឬទៅមុខទៀតទេ តម្លៃមនុស្សមិនបានផ្តោតជាធំលើលោកសម្ភារៈខាងក្រៅខ្លួនឡើយ។ តម្លៃមនុស្សពិតប្រាកដ គឺអាចនិយាយបានថាត្រូវសម្លឹងចេញពីសុជីវធម៌ គុណធម៌ សីលធម៌ ជាមុន ហើយតម្លៃផ្នែកលោកសម្ភារៈដែលបម្រើឱ្យការរស់នៅនេះជារឿងបន្ទាប់។ វិទ្យាសាស្ត្របច្ចេកវិទ្យា ភាពទំនើបកម្ម ថ្វីបើយើងត្រូវសិក្សាឱ្យចេះប្រើប្រាស់តាមសម័យកាលនិយមក៏ពិតមែន តែគេមិនអាចបោះបង់សីលធម៌ ដែលនាំភាពរីកចម្រើននៃវិទ្យាសាស្ត្រទាំងនោះ ឱ្យទៅរកផ្លូវត្រឹមត្រូវឡើយ។ សង្គមកាន់តែទំនើប ការគិតគូរពីសីលធម៌កាន់តែត្រូវពង្រឹងបន្ថែមជាប្រចាំ។

ភាពជឿនលឿន បានរុញច្រានសង្គមឱ្យអភិវឌ្ឍ ឱ្យមានប្រព័ន្ធនៃការប្រកបរបរចិញ្ចឹមជីវិតក៏មានតាមប្រព័ន្ធអនឡាញផងដែរ។ ប្រព័ន្ធបណ្តាញសង្គមបានដើរតួយ៉ាងសំខាន់ក្នុងមាគ៌ាជីវិតមនុស្សម្នាក់ៗ វានៅជាប្រចាំជាប់ខ្លួនមនុស្សគ្រប់គ្នា ដូច្នេះវាបានជះឥទ្ធិពលរាល់វេលាទាំងល្អ ទាំងអាក្រក់។ ការប្រើប្រាស់បច្ចេកវិទ្យាដោយប្រុងប្រយ័ត្នជាគន្លឹះដែលមនុស្សក្នុងយុគឌីជីថលត្រូវតែបានដឹង និងស្វែងយល់។

សីលធម៌របស់សូក្រាត ទស្សនវិទូក្រិច សតវត្សទី៥ ( ៤៧០-៣៩៩ មុន គ.ស ) គឺស្ថិតនៅលើការកសាងកុសលដើម្បីឱ្យបានសម្រេចសុភមង្គល ប៉ុន្តែមិនត្រូវយល់ថាសុភមង្គលស្ថិតនៅលើទ្រព្យសម្បត្តិ អំណាច និងកិត្តិយស ជាដាច់ខាត។ ការសប្បាយតាមផ្លូវចិត្ត ប្រសើរជាងការសប្បាយនឹងទ្រព្យសម្បត្តិ។ នេះហើយជាគុណធម៌របស់ព្រលឹង ប៉ុន្តែដើម្បីឱ្យមានសីលធម៌ និងគុណធម៌ ជាបឋមមនុស្សត្រូវមានពុទ្ធិ ដើម្បីរៀបចំខ្លួនបានចេះដឹងសិន ព្រោះ អវិជ្ជា ឬភាពល្ងិតល្ងង់ពុំអាចឱ្យមនុស្សយល់តម្លៃសីលធម៌បានទេ ព្រមទាំងជាប្រភពនៃអំពើអាក្រក់ទៀតផង។ សូក្រាត បានអះអាងទៀត មនុស្សធ្វើអំពើអាក្រក់មកពីពុំយល់ ថាជាអំពើអាក្រក់ បន្ទាប់មកទៀតសូក្រាតអប់រំមនុស្សឱ្យតាំងជាម្ចាស់ចិត្តរបស់ខ្លួន ដូចជាពាក្យទូន្មានមួយរបស់សូក្រាតពោលថា ( Connais-toi toi méme ) មានន័យថា ត្រូវស្គាល់ខ្លួនជាមុនសិន។ ព្រះសម្មាសម្ពុទ្ធព្រះអង្គសម្តែងថា«**នត្ថិ សន្តិ បរំ សុខំ**» គ្មានសេចក្តីសុខណាស្មើនឹងសេចក្តីស្ងប់ឡើយ។ តាមន័យនេះសេចក្តីសុខពិតប្រាកដរបស់មនុស្សគឺការព្រមទទួល ស្ងប់ចិត្តមិនវង្វេងតាមតណ្ហា ដែលជាប្រភពនៃទុក្ខ។

### ខ. គុណតម្លៃរក្សាសន្តិភាពក្នុងសង្គមឌីជីថល

កាលណាសង្គមកាន់តែទំនើប ចិត្តមនុស្សកាន់តែលោភលន់ តណ្ហាមនុស្សកាន់តែកើនឡើង។ ព្រះសម្មាសម្ពុទ្ធព្រះអង្គសម្តែងថា«**តណ្ហាជាប្រភពនៃសេចក្តីទុក្ខ**» កាលណាវិទ្យាសាស្ត្រកាន់តែបំពេញតាមតណ្ហាមនុស្ស ដោយកាត់បន្ថយការយកចិត្តទុកដាក់លើសីលធម៌មនុស្សជាតិ ពិតណាស់សេចក្តីវិនាសនឹងកើតមាន។ សន្តិភាពមានតម្លៃមិនអាចកាត់ថ្លៃបាន។ មានសន្តិភាព ទើបមានការអភិវឌ្ឍលើគ្រប់វិស័យ ដែលអនុញ្ញាតិឱ្យយើងអាចរស់នៅដោយគ្មានការភ័យខ្លាច មានអាហារទទួលទានគ្រប់គ្រាន់ មានជម្រកស្នាក់នៅសមរម្យ មានឱកាសទទួលបានការអប់រំ មានសិទ្ធិប្រតិបត្តិជំនឿសាសនា មានលទ្ធភាពចូលរួមសកម្មភាពសង្គមផ្សេងៗ និងអាចធ្វើដំណើរកំសាន្តក្នុងឱកាសពិធីបុណ្យនានាទាំងក្នុងនិងក្រៅប្រទេស។

មហាត្មៈគន្ធី ( 1869-1948 ជាជនជាតិឥណ្ឌា) បាននិយាយថា«**ខ្ញុំស្តាយប្រទេសឥណ្ឌាជាងខ្ញុំស្តាយជីវិតខ្ញុំទៅទៀត បើប្រទេសឥណ្ឌាពុំបានសេរីភាព ឯករាជ្យ សន្តិភាពទេ**» ខ្ញុំនឹងពុំព្រមផ្លាស់វិចារណញាណ ដែលខ្ញុំបានសម្រេចថានឹងអនុវត្តនោះឡើយ។ ក្នុងការតស៊ូទាមទារឯករាជ្យពីពួកអាណានិគមនិយមអង់គ្លេស មហាត្មៈគន្ធីតែងតែព្យាយាមប្រើធម៌**អហិង្សា**ជានិច្ច។ មានន័យថាសន្តិភាពមានតម្លៃណាស់ មានតម្លៃស្មើជីវិតមនុស្ស។ សង្គមដែលគ្មានសន្តិភាព ជាសង្គមដែលស្លាប់បាត់ទៅហើយ។

បច្ចុប្បន្ននេះ វាពិតជាខុសគ្នាដាច់ស្រឡះពីអតីតកាល ហើយទៅអនាគត ក៏នឹងកាន់តែរីកចម្រើនថែមទៀត និងល្អៗជាងនេះថែមទៀត។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក៏បានលើកឡើងដែរថា «**ការរីកចម្រើនទាំងអស់នេះ មិនអាចកើតឡើងបានឡើយ បើប្រទេសយើងមិនមានសន្តិភាព។ ដូច្នេះ សន្តិភាព គឺជាតម្លៃដែលមិនអាចកាត់ថ្លៃបានឡើយ ហើយប្រជាពលរដ្ឋគ្រប់រូបត្រូវតែរួមគ្នាថែរក្សាការពារសន្តិភាពដើម្បីទទួលបានការអភិវឌ្ឍប្រទេសជាតិរបស់យើងអោយកាន់តែរីកចម្រើនខ្លាំងថែមទៀត**»។

ប្រទេសកម្ពុជាទទួលបាននូវសន្តិភាព និងការផ្សះផ្សារជាតិពេលញលេញ មានការឯកភាពជាតិមានរដ្ឋាភិបាលតែមួយដែលទទួលបានពីនយោបាយឈ្នះ-ឈ្នះ របស់នាយករដ្ឋមន្ត្រីកម្ពុជា **សម្តេចតេជោ ហ៊ុន សែន។** ការទទួលបានសន្តិភាពពេញលេញនេះហើយទើបធ្វើឱ្យរាជរដ្ឋាភិបាលមានឱកាសគ្រប់គ្រាន់ក្នុងការអភិវឌ្ឍប្រទេសបានរហូតមកដល់សព្វថ្ងៃ។ ជារឿយៗសម្តេចតេជោបានប្រកាសថា នឹងមិនឱ្យកម្ពុជាធ្លាក់ក្នុងស្ថានភាពសង្គ្រាមដូចមុននោះទេ ដោយ សម្តេចប្រកាសថា«**ទោះក្នុងតម្លៃណាក៏ដោយក៏ត្រូវរក្សាសន្តិភាពដែលបានដោយពិបាកនេះឱ្យខានតែបាន**»។

«សន្តិភាព អាចចាប់ផ្តើមពីខ្លួនយើងម្នាក់ៗ សន្តិភាពនៅក្នុងគ្រួសារ សន្តិភាពក្នុងសហគមន៍ ហើយសន្តិភាពក្នុងសង្គម» ។ លោក Nicolas ពោលថា យើងនឹងទទួលបានការស្រឡាញ់ និងឈ្នះចិត្តប្រជាជនកម្ពុជា ដោយតាមរយៈការជំរុញការជឿជាក់ និងក្តីសង្ឃឹម ក្នុងការរក្សាសន្តិភាព» ។

មកដល់ឆ្នាំ២០២៣នេះ ស្របពេលដែលកម្ពុជា ធ្វើជាម្ចាស់ផ្ទះកីឡាស៊ីហ្គេមលើកទី៣២ ចំណុចសំខាន់ដែលកម្ពុជាចង់បាននោះ គឺចង់បំផុសគំនិត ទេពកោសល្យ និងសមត្ថភាព ក្នុងការធ្វើជាម្ចាស់ផ្ទះស៊ីហ្គេម ដែលកម្ពុជាមិនធ្លាប់ធ្វើពីមុនមក។ តាមរយៈព្រឹត្តិការណ៍នេះ គឺជាការឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យឡើងដល់កម្រិតមធ្យម ហើយក៏ស្ថិតនៅក្នុងផែនការមួយឆ្ពោះទៅកីឡាយុវជនអាស៊ី ដែលកម្ពុជាទទួលសិទ្ធិធ្វើជាម្ចាស់ផ្ទះនាឆ្នាំ២០២៩ ដោយស្ថិតក្នុងទស្សនវិស័យ «**កីឡារស់ក្នុងសន្តិភាព**»។

កម្ពុជាបានដាក់បញ្ចូលគ្នានូវ Logo តំណាងឱ្យស៊ីហ្គេម អាស៊ានប៉ារ៉ាហ្គេមតែមួយ ដោយកម្ពុជា និងគណៈកម្មការរៀបចំ បានហៅថា កម្ពុជា២០២៣ (Cambodia 2023) ។ លោក Kwan Nicholas អ្នកជំនាញការ បានធ្វើបទបង្ហាញក្នុងកិច្ចប្រជុំសន្និបាតថា៖ពាក្យស្លោក«កីឡារស់ក្នុងសន្តិភាព» បានដាក់បញ្ចូលនូវគុណតម្លៃ៨យ៉ាង រួមមាន៖ **មោទកភាព សុចរិតភាព ឆន្ទៈដ៏រឹងមាំ ការងារក្រុមដ៏អស្ចារ្យ ការកំណត់ ការបញ្ចូលគ្នា ចំណេះដឹង និងសេរីភាព ។**

**សន្តិភាព គឺជាធាតុស្នូលដ៏សំខាន់ដែលអាចឱ្យកម្ពុជាធ្វើការអភិវឌ្ឍឆ្ពោះទៅរកអនាគត ដ៏ត្រចះត្រចង់មួយប្រកបដោយសុទិដ្ឋិនិយម។** ការអភិវឌ្ឍឆ្ពោះទៅរកការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ គឺអាស្រ័យកិច្ចប្រឹងប្រែង និងការចូលរួមយ៉ាងសស្រាក់ សស្រាំរបស់យើងទាំងអស់គ្នា ទាំងក្នុងការបង្កើនជីវភាពគ្រួសារ រក្សាសន្តិសុខសុវត្ថិភាព មូលដ្ឋាន កសាងធនធានមនុស្ស និងការអប់រំជាប្រចាំដល់អ្នកនៅជុំវិញខ្លួនឱ្យយល់ ពីគុណតម្លៃ នៃសន្តិភាព និងចូលរួម ជាប្រចាំ ក្នុងការថែរក្សាសន្តិភាពឱ្យបានជានិច្ចនិរន្តន៍។ នៅពេលប្រទេសជាតិមានសុខសន្តិភាពដូចជាសព្វថ្ងៃនេះ គឺកម្ពុជាមានឱកាស ធ្វើអ្វីៗបានទាំងអស់ ក្នុងនោះគឺលទ្ធភាពកសាងអភិវឌ្ឍន៍ប្រទេសជាតិលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឱ្យកាន់តែរីកចម្រើនបានយ៉ាងឆាប់រហ័ស។

ដូច្នេះសន្តិភាពពិតជាមានតម្លៃណាស់ក្នុងសង្គមណាក៏ដោយ ពិសេសសង្គមបច្ចុប្បន្ននេះ។ គុណតម្លៃមនុស្សក្នុងយុគឌីជីថលនេះ មិនអាចខ្វះបាននូវកិច្ចខិតខំប្រឹងប្រែងរួមគ្នារក្សានូវសន្តិភាព ដើម្បីដឹកនាំនាវាកម្ពុជាឆ្ពោះទៅប្រទេសអភិវឌ្ឍនាពេលខាងមុខ។ រួមគ្នារក្សាសន្តិភាព ទើបយើងមានឱកាសអភិវឌ្ឍបាន។ មានសន្តិភាព ទើបមានការអភិវឌ្ឍ មានការអភិវឌ្ឍទើបមានសង្គមឌីជីថល ការរក្សាសន្តិភាពគឺជាគុណតម្លៃមនុស្សក្នុងសង្គមឌីជីថលនេះ។

## គ. គុណតម្លៃពង្រឹងសមត្ថភាពក្នុងសង្គមឌីជីថល

ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មនៃសេដ្ឋកិច្ច និងសង្គមឌីជីថលផង និងបង្កើនភាពប្រកួតប្រជែងជាមួយនឹងប្រទេសក្នុងតំបន់ផង, រាជរដ្ឋាភិបាលនឹងផ្ដោតលើការអភិវឌ្ឍចំណេះដឹង និងជំនាញឌីជីថល ដោយផ្ដល់អាទិភាពលើមុខព្រួញជាក់លាក់ចំនួន៣ ដែលរួមមាន៖ ភាពជាអ្នកដឹកនាំឌីជីថល, បណ្ដុំធនធានមនុស្សដែលមានទេពកោសល្យ ឌីជីថល, និង ពលរដ្ឋឌីជីថល ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន និង ជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន ។

**ពលរដ្ឋឌីជីថល** គឺការចាប់យកបច្ចេកវិទ្យាឌីជីថល មកប្រើប្រាស់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់, ប្រជាពលរដ្ឋ គ្រប់រូបត្រូវមានចំណេះដឹង និងជំនាញទន់ចាំបាច់ ដើម្បីជំរុញឱ្យការធ្វើអន្តរកម្ម នៅក្នុងប្រព័ន្ធអេកូឡូស៊ី នៃសេដ្ឋកិច្ច និង សង្គមឌីជីថល កាន់តែមានសក្តិសិទ្ធភាព ដើម្បីជានានូវបរិយាបន្នកម្មឌីជីថល។ បច្ចុប្បន្នអក្ខរកម្មឌីជីថល ដែលជាសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល និងប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធ្វើការតភ្ជាប់ការគ្រប់គ្រង ការស្វែងយល់ ការទំនាក់ទំនង ការវាយតម្លៃ ឬការបង្កើននូវព័ត៌មាននានានៅក្នុងសេដ្ឋកិច្ច និងសង្គមឌីជីថលនៅមានកម្រិតនៅឡើយ។

**រដ្ឋាភិបាលឌីជីថល** ជាតួអង្គដែលត្រូវការជាចាំបាច់ក្នុងការរៀបចំសេដ្ឋកិច្ច និងសង្គមឌីជីថល ឬ ក៏មានន័យថារាជរដ្ឋាភិបាលត្រូវឈានមុខគេក្នុងការប្រើប្រាស់ឌីជីថល ម្យ៉ាងដើម្បីបង្កើតឱ្យមានតម្រូវការផ្ទាល់ទៅកាន់ធុរជន និងប្រជាពលរដ្ឋ ចាប់យកវិស័យឌីជីថល។ ដោយសារវិស័យសាធារណៈ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋ, ការធ្វើឌីជីថលូបនីយកម្មនៃសេវាសាធារណៈ និងការធ្វើបរិវត្តកម្មប្រព័ន្ធសេវាសាធារណៈត្រូវឈរលើមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋ។ សម្រាប់កម្ពុជា រាជរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធី និងគំនិតផ្ដួចផ្ដើមមួយចំនួន ក្នុងការធ្វើបរិវត្តកម្មឌីជីថលនូវប្រព័ន្ធរដ្ឋបាលសាធារណៈ និងសេវាសាធារណៈជាបន្តបន្ទាប់។

**ធុរកិច្ចឌីជីថល** ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសហគ្រាសនៅកម្ពុជា ធ្វើឡើងដោយប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងកម្រិតមួយតិចតួច តាមរយៈការប្រើប្រាស់គេហទំព័រ បណ្ដាញសង្គម ឬព័ត៌មានក្នុងផែនទីឌីជីថល ក្នុងការផ្សព្វផ្សាយផលិតផល ឬសេវារបស់ខ្លួន។ ដោយឡែក នៅមានបច្ចេកវិទ្យាឌីជីថលថ្មីៗមួយចំនួនទៀត ដែលសហគ្រាសភាគច្រើននៅមិនទាន់បានចាប់យក និងប្រើប្រាស់ជាអាទិ៍ ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងអាជីវកម្ម និងឧបករណ៍ប្រមូល និង វិភាគទិន្នន័យស្វ័យប្រវត្តិ។



## ៥. គុណតម្លៃគ្រូបង្រៀនក្នុងយុគសម័យឌីជីថល

### ៥.១. គោលនយោបាយនៃការសិក្សាបែបឌីជីថល

#### ៥.១.១. យុទ្ធសាស្ត្រចតុកោណ

ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ«**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤**» ដែលបានតម្រង់ទិសការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការពន្លឿនពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងភាពប្រកួតប្រជែង។ យុទ្ធសាស្ត្រនេះបានចង្អុលយ៉ាងច្បាស់អំពីភាពចាំបាច់ក្នុងការត្រៀមខ្លួនដើម្បីចាប់យកសេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹង«**បដិវត្តន៍ឧស្សាហកម្មទី៤**» សំដៅទាញយកប្រយោជន៍ពីភាពរីកចម្រើននៃបច្ចេកវិទ្យា។ ឱកាស និងប្រយោជន៍ ដែលផ្តល់ដោយបច្ចេកវិទ្យាឌីជីថល មិនបានកំណត់ត្រឹមវិស័យ ឬធុរកិច្ចដែលពឹងផ្អែកផ្ទាល់លើបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវតម្លៃបន្ថែមដល់គ្រប់វិស័យនៃសេដ្ឋកិច្ចទាំងមូល។ ជាក់ស្តែង ស្ទើរគ្រប់វិស័យសេដ្ឋកិច្ច និងសង្គម បាននិងកំពុងទទួលរងឥទ្ធិពលបច្ចេកវិទ្យា ពិសេសបច្ចេកវិទ្យាឌីជីថល ហើយបាននិងកំពុងកែប្រែរបៀបនៃការធ្វើធុរកិច្ច ការធ្វើការងារ និងការធ្វើឱ្យមានការផ្លាស់ប្តូរទម្លាប់នៃការរស់នៅផងដែរ។ ក្នុងបរិបទនេះ ឌីជីថលូបនីយកម្ម បានក្លាយជានិន្នាការដ៏មានឥទ្ធិពល និងជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ចតំបន់ និងសកលលោកក្នុងសតវត្សរ៍ទី២១នេះ។

ក្នុងទិសដៅ និង និន្នាការខាងលើ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រគល់ភារកិច្ចជូនឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិដឹកនាំសម្របសម្រួល និងរៀបចំក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា សម្រាប់ជាមគ្គុទេសក៍ក្នុងការអភិវឌ្ឍវិស័យនេះ តាមរយៈការធ្វើបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមកម្ពុជា ទាំងមូលឱ្យស្របតាមនិន្នាការតំបន់ និងពិភពលោក ។

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា បានកំណត់យកនូវចក្ខុវិស័យ«កសាងសេដ្ឋកិច្ចនិង សង្គមឌីជីថលរស់រវើក ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ផ្អែកលើប្រក្រតីភាពតាមគន្លងថ្មី»។ ចក្ខុវិស័យនេះត្រូវសម្រេចឱ្យបានក្នុងរយៈពេល១៥ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣៥ ហើយអនុលោមតាមគោលការណ៍ចំនួនបីគឺ៖ «ការកសាងមូលដ្ឋានគ្រឹះឌីជីថល ការចាប់យកឌីជីថល ការធ្វើបដិវត្តកម្មឌីជីថល» ដែលក្នុងនោះរាល់វិធានការ គោលនយោបាយ ត្រូវអនុវត្តដំណាលគ្នា ប៉ុន្តែផ្តល់អាទិភាព ទៅលើវិធានការដែលឆ្លើយតបទៅនឹងគោលការណ៍នីមួយៗ។



បរិវត្តកម្មឌីជីថលគឺជាគោលដៅចុងក្រោយ ដែលសំដៅសម្រេចបាននូវការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល ដោយពឹងផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល យ៉ាងទូលំទូលាយក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច និងគ្រប់សកម្មភាពសេដ្ឋកិច្ច ដែលផ្សារភ្ជាប់មានអន្តរទំនាក់ទំនងជាមួយគ្នា និង បំពេញបន្ថែមឱ្យគ្នា។ បន្ថែមលើនេះ ក្របខណ្ឌគោលនយោបាយនេះផ្តោតលើសមាសធាតុចំនួនប្រាំ ដែលចែកចេញជាគ្រឹះចំនួនពីររួមមាន៖ (១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង (២). ការកសាងទំនុកចិត្ត និង ភាពជឿជាក់ លើប្រព័ន្ធឌីជីថល និង សសរស្តម្ភចំនួនបីរួមមាន៖ (១). ការកសាងពលរដ្ឋឌីជីថល (២). ការកសាងរដ្ឋាភិបាលឌីជីថល និង (៣). ការជំរុញធុរកិច្ចឌីជីថល ។




### ៥.១.២. ការសិក្សាពេញមួយជីវិត

ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ សំដៅធានាសិទ្ធិសេរីភាព និងសុកមង្គល បុគ្គល គ្រួសារ និងសង្គម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ការសិក្សាពេញមួយជីវិតជាដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ តាំងពីការចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ឱ្យក្លាយជាពលរដ្ឋល្អនិងចេះរួមរស់ជាមួយគ្នាប្រកបដោយភាពសុខដុមនៅក្នុងសង្គម។ ស្ថិតក្នុងបរិការណ៍នៃសកលភាវូបនីយកម្មសតវត្សរ៍ទី២១ និងការប្រកួតប្រជែងទាំងក្នុងតំបន់ សកលលោក ផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម និងបច្ចេកវិទ្យា បុគ្គល គ្រប់រូបត្រូវទទួលបានការបណ្តុះបណ្តាលវប្បធម៌សិក្សាពេញមួយជីវិត។



### ៥.១.៣. ការបញ្ចូលជំនាញសតវត្សរ៍ទី២១

កំណែទម្រង់វិស័យអប់រំផ្តោតជាសំខាន់លើការបង្កើតចំណេះដឹង បំណិន និងសមត្ថភាពរបស់គ្រូបង្រៀន។ គ្រូបង្រៀន គឺជាអ្នកអនុវត្តកំណែទម្រង់នៅក្នុងថ្នាក់រៀន និងជា«**អ្នកដឹកនាំក្នុងថ្នាក់រៀន**»។ គ្រូបង្រៀន គឺជា «**ភ្នាក់ងារនៃការផ្លាស់ប្តូរ**»។







នៅក្នុងយុគសម័យឌីជីថល គ្រូត្រូវមានលក្ខណៈសម្បត្តិ៥យ៉ាងដែល មាននៅក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺ៖

- ទីមួយ៖ ចំណេះដឹងខ្លឹមសារមេរៀនរឹងមាំ និងមានវប្បធម៌ទូទៅទូលំទូលាយ (រួមទាំងចំណេះដឹងផ្នែកភាសាបរទេសដែរ)
- ទីពីរ៖ បំណិនវិជ្ជាជីវៈ ជាពិសេសចំណេះដឹងខាងផ្នែកចិត្តវិទ្យា និង គរុកោសល្យ រួមទាំងមានសមត្ថភាពក្នុងការស្រាវជ្រាវ
- ទីបី ៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីមានបទពិសោធន៍វិជ្ជាជីវៈកាន់តែខ្លាំងក្លាឡើង
- ទីបួន៖ សីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើតវប្បធម៌សាលារៀនវិជ្ជមាន និងផ្តល់ឱកាសឱ្យសិស្សបានសិក្សារៀនសូត្រដើម្បីសម្រេចបានសក្តានុពល
- ទីប្រាំ៖ បំណិនឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន ដើម្បីអប់រំសិស្សឱ្យមានបំណិនសតវត្សទី២១។

សរុបមក ដើម្បីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់សតវត្សរ៍ទី២១ គេត្រូវបណ្តុះបណ្តាលគ្រូ ឱ្យមានចំណេះដឹង បំណិន និងសមត្ថភាពសតវត្សទី២១។

### ៥.២. គុណតម្លៃគ្រូបង្រៀនឧីជីថល
### ៥.២.១. ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

គ្រូបង្រៀនមានសក្តានុពលឆ្លើយតបទៅនឹងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន អាចជួយអភិវឌ្ឍខ្លួន ជួយគ្រូបង្រៀនដទៃទៀតក្នុងសាលា ជាពិសេសជួយឱ្យសិស្សទទួលបានការសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងបង្កើនលទ្ធផលសិក្សារបស់សិស្ស។ ទន្ទឹមគ្នានេះ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ជាលក្ខណៈសម្បត្តិស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន។[5] លក្ខណៈសម្បត្តិគ្រូបង្រៀន ដែលមានស្តង់ដារវិជ្ជាជីវៈរួមមាន៖ ទី១. **មានចំណេះដឹងវិជ្ជាជីវៈ** គឺគ្រូបង្រៀនត្រូវដឹងអំពីសិស្ស មានចំណេះដឹងខ្លឹមសារមេរៀន ដឹងអំពីរបៀបរៀនរបស់សិស្ស ចំណេះដឹងភាសាបរទេស ព្រមទាំងចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា(ITC)។ ទី២.**ការប្រតិបត្តិវិជ្ជាជីវៈ** គឺគ្រូបង្រៀនត្រូវធ្វើផែនការ និងពិនិត្យតាមដានវាយតម្លៃលទ្ធផលសិក្សា ការគ្រប់គ្រងបរិស្ថានសិក្សា និងវិធីសាស្ត្របង្រៀន។ ទី៣. **ការសិក្សាវិជ្ជាជីវៈ** គឺគ្រូបង្រៀនត្រូវស្វ័យសិក្សា វាយតម្លៃការបង្រៀន អភិវឌ្ឍខ្លួនឯង និងរៀបចំផែនការស្វ័យសិក្សា និងការអភិវឌ្ឍចំណេះដឹងITC បម្រើឱ្យការបង្រៀន ចូលរួមកែលម្អការបង្រៀន ពង្រឹងបំណិនទាក់ទង សិក្សាស្រាវជ្រាវ និងពង្រឹងសកម្មភាពសិក្សាវិជ្ជាជីវៈ។ និងទី៤. **សីលធម៌វិជ្ជាជីវៈ** គឺគ្រូបង្រៀនយកចិត្តទុកដាក់ និងថែរក្សាសិស្សដើម្បីប្រយោជន៍សិស្ស និងសង្គម ប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន ដោយស្មារតីទទួលខុសត្រូវខ្ពស់។ លើសពីនេះ អាកប្បកិរិយាវិជ្ជមាន ជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងប្រកបដោយភាពសុខដុម ជាមួយសិស្ស និងសហគមន៍ មានយុត្តិធម៌ និងតម្លាភាព។




[5] ឯកឧត្តមបណ្ឌិត ចាន់ សុភា មានប្រសាសន៍ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២០-២០២១ និងលើកទិសដៅឆ្នាំសិក្សា២០២១-២០២២។

### ៥.២.២. ការអភិវឌ្ឍសមត្ថភាពបន្ថែមរបស់គ្រូ

ការអប់រំជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ការអប់រំប្រកបដោយនិរន្តរភាព គឺធ្វើឱ្យមនុស្សមានឱកាសអភិវឌ្ឍសមត្ថភាពរបស់គេ ធ្វើឱ្យអ្នកសិក្សាមានទំនុកចិត្ត និងឯករាជ្យភាព បង្កើតនូវសមភាព អាទិភាពសម្រាប់សកម្មភាពផ្ទាល់ខ្លួន ការគិតអំពីការអភិវឌ្ឍដទៃទៀត និងការអភិវឌ្ឍជាអចិន្ត្រៃយ៍។

ប្រវត្តិសាស្ត្រនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព(ESD) ចាក់ឫសនៅក្នុងប្រវត្តិសាស្ត្រ នៃអង្គការសហប្រជាជាតិនៅក្នុងចលនាបរិស្ថាន។ នាពាក់កណ្តាលឆ្នាំ១៩៨០ អង្គការសហប្រជាជាតិ ដាក់ចេញជាយុទ្ធសាស្ត្រធំៗ ដើម្បីដោះស្រាយពីតម្រូវការក្នុងសង្គមនិងបរិស្ថាន។ នៅឆ្នាំ១៩៨៧មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានរកឃើញគំនិតស្របគ្នានៃការអប់រំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ហើយឆ្នាំ២០០២ បានពង្រីកស៊ីជម្រៅ និងការប្តេជ្ញាចិត្តឆ្ពោះទៅរកការអភិវឌ្ឍ ប្រកបដោយនិរន្តរភាពនៅគ្រប់កម្រិតទាំងអស់ក្នុងស្រុក ដើម្បីឆ្ពោះទៅរកលក្ខណៈជាសកល។ ឆ្នាំ២០០៥ អង្គការ (UNESCO) បានដាក់ឱ្យអនុវត្តជាលក្ខណៈអន្តរជាតិ។ ធាតុសំខាន់នៃការអប់រំប្រកបដោយនិរន្តរភាព គឺបរិស្ថាន សង្គម និងសេដ្ឋកិច្ច។ របាយការណ៍គណៈកម្មការពិភពលោកអំពីបរិស្ថាន និងការអភិវឌ្ឍ ១៩៨៧ បានឱ្យនិយមន័យថា ការអភិវឌ្ឍប្រកបដោយនិរន្តរភាព គឺអនាគតដែលយើងចង់បាន(Our Common Future)។ ឆ្នាំ២០០៥-២០១៤ ជាទសវត្សសម្រាប់ការផ្លាស់ប្តូរ ឬជាទសវត្សសម្រាប់ការអប់រំប្រកបដោយនិរន្តរភាព ដោយផ្អែកលើអាទិភាពធំទាំងបួនគឺ **សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌**។




ការបង្ហាញនូវបរិបទបញ្ហាភាវូបនីយកម្ម គឺជាអាទិភាពក្នុងការកសាងសមត្ថភាពជនស៊ីវិលសម្រាប់សហគមន៍ ដោយផ្អែកលើការសម្រេចចិត្ត ការអត់ឱនគ្នាក្នុងសង្គម ការថែរក្សាបរិស្ថាន កម្លាំងពលកម្ម និងគុណភាពជីវិត។ ការបញ្ជ្រាប ESD តាមរយៈទម្រង់ផ្សេងៗនៃបច្ចេកទេសគរុកោសល្យដើម្បីលើកកម្ពស់ការសិក្សា និងការគិតកម្រិតខ្ពស់ (UNESCO, ២០០៥, Interrational Implerrientation Scheme)។ អង្គការ UNESCO បានកំណត់នូវមូលដ្ឋានគ្រឹះសម្រាប់ការអប់រំប្រកបដោយនិរន្តរភាពមាន៥ គឺ បញ្ចស្តម្ភនៃការអប់រំប្រកបដោយនិរន្តរភាព(Five Pillars of ESD)៖

**ក. រៀនដើម្បីយល់ដឹង** (learning to know)

ស្គាល់ពីធម្មជាតិ និងដំណើរវិវត្តន៍របស់វា ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការដែលមិនធ្លាប់មានក្នុង សង្គមដោយទទួលស្គាល់ពីតម្រូវការក្នុងស្រុក និងផលប៉ះពាល់ពីអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាជាសកល និងអាទិភាពក្នុងស្រុក ។

**ខ. រៀនដើម្បីធ្វើខ្លួនជាពលរដ្ឋល្អ** (Learning to be)

អភិវឌ្ឍន៍ខ្លួនផ្អែកលើគោលការណ៍និងតម្លៃនៃការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីដោះស្រាយបញ្ហាសុខុមាលភាព និងវិស័យទាំងបីនៃនិរន្តរភាព ដូចជាបរិស្ថាន សង្គម និងសេដ្ឋកិច្ច ព្រមទាំងរួមចំណែកអភិវឌ្ឍមនុស្សឱ្យបានពេញលេញទាំងស្មារតី និងរូបរាងកាយ ការប្រែប្រួល អាកាសធាតុ និងសាសនា ។

**គ. រៀនរស់នៅជាមួយគ្នា** (learning to live together)

កសាងសមត្ថភាពសម្រាប់ឱ្យមនុស្សចេះធ្វើការនៅតាមសហគមន៍ ចេះធ្វើការសម្រេចចិត្ត ចេះអត់ឱនក្នុងសង្គម ថែរក្សាបរិស្ថាន និងមានគុណភាពជីវិត។

**ឃ. រៀនដើម្បីមានជំនាញ** (Learning to do)

រួមចំណែកស្វែងរកការងារសម្រាប់ជីវភាពប្រចាំថ្ងៃ និងកសាងពិភពលោកមួយប្រកបដោយ និរន្តរភាព និងមានសុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នា។

**ង. រៀនដើម្បីផ្លាស់ប្តូរខ្លួនឯង និងសង្គម** (Learning to transform oneself and society)

ការសិក្សានេះរួមបញ្ចូលនូវតម្លៃមត៌កវប្បធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការសិក្សាផ្តល់អំណាចដល់ប្រជាជន ដើម្បីឱ្យមានការទទួលខុសត្រូវ លើការអភិវឌ្ឍប្រកបដោយនិរន្តរភាព នាពេលអនាគត។ អង្គការ(UNESCO)បានកំណត់យកESD ដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន សិស្ស អ្នកអភិវឌ្ឍកម្មវិធីសិក្សា អ្នកបង្កើតគោលនយោបាយអប់រំ អ្នកនិពន្ធសៀវភៅសិក្សា និងអ្នកផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន និងរៀន។




«**ការអប់រំបែបឌីជីថល**» មានគោលដៅប្រើប្រាស់បច្ចេកវិទ្យា ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច និងសង្គមក្នុង បរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងការបង្កើតក្រុងឆ្លាត(Smart city) និងអគារវៃឆ្លាតដែរ។

គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ ក្នុងបរិវត្តកម្មឌីជីថលក្នុងវិស័យអប់រំ។ ក្នុងយុគសម័យឌីជីថល គ្រូត្រូវប្រើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យ ដើម្បីធ្វើឱ្យការបង្រៀន និងរៀន កាន់តែមានប្រសិទ្ធភាព។ ដូច្នេះត្រូវអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀន និងរៀន ព្រមទាំងមានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវ បំពេញបន្ថែមទាំងចំណេះដឹងមូលដ្ឋាន ទាំងបច្ចេកទេសបង្រៀនថ្មីៗតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

### ៥.២.៣. គុណតម្លៃនៃការស្គាល់វិធីសាស្ត្របង្រៀន

គ្រូបង្រៀនដែលមិនដឹងពីវិធីបង្រៀន ប្រៀបដូចតែកុងដែលមិនចេះបើកឡាន។ ការស្គាល់វិធីសាស្ត្របង្រៀននីមួយៗច្បាស់ គឺជាដើមទុនដ៏សំខាន់ដើម្បីច្នៃប្រឌិតវិធីបង្ហាត់បង្រៀនបណ្តុះបណ្តាលទៅកាន់សិស្ស ស្របតាមស្ថានភាពជាក់ស្តែង និងសម័យកាលបរិវត្តកម្មឌីជីថលនេះ។ វិធីសាស្ត្របង្រៀនដែលយើងឃើញមានសំខាន់ៗគឺវិធីសាស្ត្របែបប្រពៃណី និងវិធីសាស្ត្របង្រៀនបែបស្ថាបនានិយម។

### ៥.២.៣.១. វិធីសាស្ត្របង្រៀនបែបប្រពៃណី

#### ក. វិធីសាស្ត្របង្រៀនបែបឧទ្ទេស

វិធីឧទ្ទេស ជាវិធីមួយដែលគ្រូប្រើសម្ដីមេរៀនថ្មី។ វិធីឧទ្ទេសជាវិធីដែលគ្រូយកមកប្រើប្រាស់ ជាមធ្យោបាយ និងជាមូលដ្ឋាននៅក្នុងការអនុវត្តតាមលំនាំនៃការបង្រៀន ពោលវិធីនេះទាមទារឱ្យគ្រូបង្រៀនចេះប្រើប្រាស់វាចាយ៉ាងរស់រវើក សម្បូរទៅដោយរូបារម្មណ៍ដើម្បីទាក់ទាញទឹកចិត្តនិង ចំណង់ចំណូលចិត្តរបស់សិស្ស។

វិធីឧទ្ទេស វាគឺជាវិធីមួយដែលតម្រូវឱ្យគ្រូបង្រៀនធ្វើសកម្មភាពច្រើនជាងសកម្មភាពសិស្ស ហើយសិស្សអង្គុយចាំស្តាប់គ្រូពន្យល់ និងកាត់ត្រាសំណួរ ឬខ្លឹមសារមេរៀន ឬចំណុចសំខាន់ន មេរៀនទុក ហើយគ្រូត្រូវចេះបង្កើតសំណួរទៅកាន់សិស្ស ដើម្បីវាស់ស្ទង់សិស្សផង និងដើម្បីកុំឱ្យ ស្ងាត់ផង។ វិធីនេះត្រូវបានចែកជាវិធីជាក់ស្តែងដូចតទៅៈ ការធ្វើអត្ថាធិប្បាយ វិធីបំណកស្រាយ ពន្យល់ និងវិធីបែបពិពណ៌នា។ វិធីនេះស្ថិតក្នុងគោលវិធីគ្រូមជ្ឈមណ្ឌល។

#### ខ. វិធីសាស្ត្របង្រៀនបែបចង្អុលបង្ហាញ

វិធីសាស្ត្រចង្អុលបង្ហាញ គឺជាវិធីសាស្ត្របង្រៀន ដែលប្រើប្រាស់សម្រាប់ការទាក់ទង់គំនិត ជាមួយនឹងសម្ភារៈឧបទេសដូចជា Flip Charts, Posters, Powerpoint ជាដើម។ ការចង្អុលបង្ហាញ គឺជាដំណើរនៃការបង្រៀននរណាម្នាក់អំពីរបៀបធ្វើ ឬធ្វើអ្វីមួយជាជំហានៗ។ វិធីសាស្ត្របង្រៀនបែបចង្អុលបង្ហាញ គឺជាការធ្វើបទបង្ហាញបញ្ជាក់ដែលតម្រូវឱ្យអ្នកសិក្សា បង្ហាញទៅកាន់អ្នកចូលរួមអំពីរបៀបធ្វើអ្វីមួយ។ វាមើលឃើញនឹងភ្នែក បង្ហាញការអនុវត្តរួមជាមួយនឹងការពិភាក្សា។ វិធីសាស្ត្រនេះសមស្របសម្រាប់គោលបំណងទូលំទូលាយជាមួយនឹងទម្រង់ជាក់លាក់ ។

ប្រភេទនៃការចង្អុលបង្ហាញ មានដូចជាៈ(១) ការចង្អុលបង្ហាញសុទ្ធ ៖ មើលឃើញជាក់ស្តែងនៃការណែនាំ (២) ចង្អុលបង្ហាញជាមួយនឹងការអត្ថាធិប្បាយៈ មានទាំងការមើលឃើញរូបភាពដោយអមជាមួយនូវការអត្ថាធិប្បាយ (៣) ការចង្អុលបង្ហាញដោយមានការចូលរួមៈ អនុញ្ញាតឱ្យសិស្សចូលរួមធ្វើឡើងវិញនូវអ្វីដែលបានបង្ហាញដោយផ្នែក ឬទាំងមូលតែម្តង។

### ៥.២.៣.២. វិធីសាស្ត្របង្រៀនបែបស្ថាបនានិយម

#### ក. វិធីសាស្ត្របង្រៀនបែបវិធីវិទ្យាសាស្ត្រ

ជំហានទាំង៥របស់វិធីវិទ្យាសាស្ត(១)ការកំណត់បញ្ហា (២) ការបង្កើតសម្មតិកម្ម (៣) ការធ្វើតេស្តសម្មតិកម្ម (ពិសោធន៍) (៤) ការសង្កេត និងវាស់វែងលទ្ធផល (៥) ការវិភាគ និងទាញសេចក្តីសន្និដ្ឋានសម្មតិកម្មត្រូវបានគាំទ្រដោយពិសោធន៍ ។

១) ការកំណត់បញ្ហាៈ ការកំណត់បញ្ហា គឺជាការផ្តើមឡើងពីការសង្កេតបាតុភូតអ្វីមួយ ឬការ ជួបប្រទះបាតុភូតនោះដោយចៃដន្យ។ តាមរយៈការសង្កេតបាតុភូត ឬការជួបបាតុភូតដោយចៃដន្យ នេះអ្នកសង្កេតនឹងមានចម្ងល់ ហើយបានលើកជាសំណួរណាដែលមានចម្លើយឆ្លើយតបទៅនឹងវត្ថុបំណង គ្រូត្រូវលើកសំណួរនោះឡើងជាសំណួរគន្លឹះដើម្បីឱ្យសិស្សរៀបចំសកម្មភាពស្រាវជ្រាវ។

២) ការបង្កើតសម្មតិកម្ម៖ អ្នកវិទ្យាសាស្ត្រ កាលណាជួបនឹងចម្ងល់ ឬសំណួរហើយ តែងតែ ខិតខំត្រិះរិះពិចារណាដើម្បីរកចម្លើយដោយការស្មានទុក ដែលមានហេតុផលផ្អែកលើបទពិសោធ ចំណេះដឹងដែលមានស្រាប់ ។ ចម្លើយស្មានទុកនេះគឺជាសម្មតិកម្ម ។ ការព្យាយាមពន្យល់នូវចម្ងល់ ឬសំណួរដោយការស្មានទុកប្រកបដោយហេតុផលនេះហៅថា ការបង្កើតសម្មតិកម្ម ។ សម្មតិកម្មត្រូវ តែច្បាស់លាស់ ហើយអាចធ្វើតេស្តបាន ។

៣) ការធ្វើពិសោធ ដើម្បីធ្វើតេស្តសម្មតិកម្មនោះ អ្នកស្រាវជ្រាវតែងតែធ្វើពិសោធន៍ជាក់ ស្តែងដោយប្រើប្រាស់សម្ភារៈ និងដំណើរការពិសោធទៅតាមខ្លឹមសារនៃសម្មតិកម្ម។ ក្នុងថ្នាក់វិទ្យាសាស្ត្រវិញ ត្រង់ចំណុចនេះ គ្រូត្រូវពន្យល់ឡើងវិញឱ្យបានច្បាស់នូវរបៀបប្រើប្រាស់សម្ភារៈ ការដំឡើងឧបករណ៍ និងដំណើរការពិសោធរួមទាំងរបៀបកត់ត្រាទិន្នន័យ ដើម្បីគណនាលទ្ធផល ពិសោធន៍ជាមុន ទើបឱ្យសិស្សធ្វើពិសោធន៍ដោយខ្លួនឯង គ្រាន់តែតាមដានសកម្មភាពសិស្ស និង សម្រុះសម្រួលប៉ុណ្ណោះ ។

៤) ការវាស់វែង និងវិភាគលទ្ធផល៖ ក្រោយពីប្រមូលទិន្នន័យ លទ្ធផលត្រូវបានវាស់វែង ឬគណនា គេទទួលបានលទ្ធផលពិសោធជាក់លាក់មួយ។

៥. ការទាញសេចក្តីសន្និដ្ឋាន ៖ ក្រោយពីទទួលបានលទ្ធផល ឱ្យសិស្សវិភាគទៅលើលទ្ធផលនោះ គាំទ្រសម្មតិកម្មដែរឬទេ បើគេសន្និដ្ឋានថា សម្មតិកម្មនោះគាំទ្រដោយពិសោធន៍ ឬមិនត្រូវបានគាំទ្រដោយពិសោធន៍។

### ខ.វិធីសាស្ត្របង្រៀនបែបរិះរក

តើអ្វីជាការបង្រៀននិងរៀនតាមបែបរិះរក? "ការរិះរក" មានន័យថា "ការរកចំណេះដឹងតាមរយៈសំណួរ"។ ដូច្នេះការបង្រៀន និងការរៀនតាមបែបរិះរក គឺជាការបង្រៀនដែលលើកទឹកចិត្តសិស្សឱ្យធ្វើការជាមួយគ្នា ដើម្បីផ្តល់ចម្លើយទៅ នឹងសំណួររបស់គេ ជាជាងការបង្រៀនដោយផ្ទាល់ពីគ្រូ និងធ្វើអ្វីៗតាមតែគ្រូ។ ការងាររបស់គ្រូនៅក្នុងការបង្រៀន និងរៀនតាមវិធីបែបរិះរក គឺមិនមែនផ្តល់ចំណេះដឹងទៅឱ្យសិស្សនោះទេ ប៉ុន្តែត្រូវជួយសិស្សឱ្យរកបាននូវចំណេះដឹងណាមួយដោយខ្លួនគេផ្ទាល់។

ការរៀន និងការបង្រៀនតាមវិធីសាស្ត្ររិះរក តម្រូវឱ្យសិស្សចេះសង្កេត និងវិភាគអំពីបាតុភូតវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម ដើម្បីបង្កើតសំណួរ ធ្វើពិសោធន៍ ឬធ្វើការស្រាវជ្រាវ ដើម្បីឆ្លើយទៅនឹងសំណួររបស់ពួកគេ និងទាញចេញនូវសេចក្តីសន្និដ្ឋានសមស្របមួយតាមរយៈលទ្ធផលនៃការធ្វើពិសោធន៍ ឬការសិក្សាស្រាវជ្រាវនោះ។ នៅក្នុងដំណើរការនេះ សិស្សនឹងយល់ពីខ្លឹមសារបានកាន់តែស៊ីជម្រៅ ទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រយ៉ាងប្រាកដ។

នៅពេលដែលសិស្សរៀនវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គមនៅក្នុងថ្នាក់តាមបែបវិធីសាស្ត្ររិះរក គឺពួកគេក្លាយជា "**អ្នកវិទ្យាសាស្ត្រពាក់កណ្តាល**" ទៅហើយ ពីព្រោះពួកគេប្រើប្រាស់វិធីសាស្ត្រ ដូចគ្នានឹងអ្នកវិទ្យាសាស្ត្រប្រើនៅពេលពួកគេធ្វើការស្រាវជ្រាវដែរ។



**គ.វិធីសាស្ត្របង្រៀនបែបដោះស្រាយបញ្ហា**

វិធីសាស្ត្របង្រៀនតាមបែបដោះស្រាយបញ្ហា (Problem Solving) គឺជាគោលវិធីបង្រៀនបែបសិស្សមជ្ឈមណ្ឌលមួយបែប ដែលគេប្រើប្រាស់ជាជំហានៗ ដើម្បីឱ្យសិស្សរៀនស្វែងរកដំណោះស្រាយ នៃបញ្ហា និងឧបសគ្គនានានៅក្នុងបញ្ញត្តិ ឬខ្លឹមសារ ដែលបានចោទសួរ តាមរយៈការសាកល្បង ហើយសាកល្បងទៀតសោត គឺច្រើនលើកច្រើនសារ ដោយវិធីផ្សេងៗ រហូតពួកគេទទួលបានជោគជ័យ។ ជាការចាំបាច់ណាស់ឱ្យសិស្សទាំងអស់ចេះពីរបៀបដោះស្រាយបញ្ហានានា ឬគណនាលំហាត់នៅក្នុងចំណោទបញ្ហាណាមួយរបស់ខ្លឹមសារមេរៀន ដោយមិនចំពោះតែអ្នកសិក្សាលើមុខវិជ្ជាគណិតវិទ្យា ឬវិទ្យាសាស្ត្រទេ។

ហេតុអ្វីបានជាគ្រូត្រូវបង្រៀនវិធីសាស្ត្រដោះស្រាយបញ្ហា? វាជាការចាំបាច់ណាស់សម្រាប់ឱ្យសិស្សចេះរបៀបដោះស្រាយលំហាត់សំណួរ និងការវិភាគនៅពេលអនាគត មិនថានៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រពិត និងមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ឬនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃទេ។ លោក Posamentier and Stepelman (1999)បានបង្ហាញអំពីផលិតផលបន្ទាប់បន្សំនៃការដោះស្រាយចំណោទ ឬលំហាត់បាន លុះត្រាតែសិស្សធ្វើតាមសំណើទាំងបីដូចខាងក្រោម៖

១. សិស្សត្រូវរៀនអានចំណោទបញ្ហា ឬលំហាត់ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា។

២. សិស្សនឹងទទួលបាននូវការអភិវឌ្ឍគំនិតផ្ទាល់ខ្លួនរបស់ពួកគេ។

៣. សិស្សនឹងរៀនរកកំហុស និងវិភាគចំណោទបញ្ហាដែលដាក់ឱ្យពួកគេ។

**ឃ.វិធីសាស្ត្របង្រៀនបែបផែនទីគំនិត**

ការបង្រៀនបែបការបង្កើតផែនទីគំនិត មានបួនជំហានដូចខាងក្រោម៖

**១. ជ្រើសរើស៖** កំណត់អត្តសញ្ញាណគំនិតគន្លឹះ ដែលប្រើប្រាស់នៅក្នុងគំនិតចំណេះដឹង សំខាន់ៗ។ ការជ្រើសរើសសំណួរផ្តោតមួយ ការសរសេរចូលគ្រប់ប្រយោគគំនិត និងប្រយោគសំណើ ចេញពីអ្វីដែលអ្នកគិតថា វាមានទំនាក់ទំនង, ជាមួយនឹងសំណួរផ្តោត ឬប្រធានបទដែលបានរៀនរួច។ នៅក្នុងវិធីនេះ រាល់ចំណេះដឹងដែលអ្នកបានរៀនទាំងអស់ត្រូវតែយកមកប្រើ។ ជាទូទៅមាន គំនិតប្រហែលពី៥ទៅ២៥ (អាស្រ័យទៅនឹងខ្លឹមសារសំណួរផ្តោត)ជាការគ្រប់គ្រាន់ហើយ។

**២. តម្រៀប និងចុះបញ្ជី៖** ការតម្រៀបគំនិតទាំងអស់ ចាប់ពីអរូបីរហូតដល់រូបី។ នេះមានន័យថា ជាការតម្រៀបតាមលំដាប់លំដោយចាប់ពីគំនិតទូទៅ និងសំខាន់ជាងគេបំផុត ត្រូវតម្រៀបនៅខាងលើបំផុត បន្ទាប់មកគំនិតទូទៅ និងសំខាន់បន្ទាប់ត្រូវតម្រៀបនៅបន្តបន្ទាប់ រីឯគំនិតមិនទូទៅ និងមិនសំខាន់ជាងគេបំផុតត្រូវតម្រៀបនៅខាងក្រោមគេ។ ពេលនេះអ្នកអាចឃើញថា បញ្ជីគំនិត មានសភាពដូចជាប្រឡោះចំណត អ្នកអាចផ្លាស់គំនិតទាំងនេះចូលទៅក្នុងផែនទីគំនិត នៅពេលដែលអ្នកគិតថាគំនិតនោះសមស្រប និងត្រឹមត្រូវហើយ។ ប្រសិនបើអ្នកមើលឃើញថា គំនិតខ្លះមិនល្អគ្រប់គ្រាន់ដើម្បីភ្ជាប់ អ្នកអាចរក្សាទុកគំនិតខ្វះទាំងនោះនៅក្នុងប្រឡោះចំណតដដែលបាន នៅពេលដែលផែនទីត្រូវបានបំពេញរួចរាល់។

៣. **ការសង់៖** សំណង់ផែនទីគំនិតដែលគ្មានពាក្យ ឬឃ្លាសំណើ ត្រូវបានសង់ឡើងនៅដំណាក់នេះ ដែលអ្នកអាចសរសេរផែនទីគំនិតបែបនេះនៅលើក្រដាសព្រាង។

៤. **ទំនាក់ទំនង៖** នៅពេលផែនទីដំបូងត្រូវបានសង់រួច ការភ្ជាប់ខ្សែងត្រូវយកមកប្រើដើម្បីកំណត់ពាក្យ ឬឃ្លាសំណើ។ ទាំងអស់នេះ គឺជាការភ្ជាប់រវាងគំនិតនានានៅក្នុងចំណេះដឹងសំខាន់ ៗ នៅលើផែនទី ដែលជួយបង្ហាញរបៀបដែលចំណេះដឹងសំខាន់ៗទាំងនេះមានទំនាក់ទំនងជាមួយគ្នា។ ការភ្ជាប់ខ្សែងគឺមានសារៈសំខាន់ក្នុងការបង្ហាញថា អ្នករៀនឈ្វេងយល់ពីទំនាក់ទំនងរវាងគ្នានិងគ្នា។

### ខ.វិធីសាស្ត្របង្រៀនបែបតុក្កតាគំនិត

តុក្កតាគំនិត គឺរូបគំនូរងាយៗដែលបង្ហាញពីទស្សនៈវិទ្យាសាស្ត្រទាក់ទងនឹងស្ថានភាពជីវភាពប្រចាំថ្ងៃ។ វត្ថុបំណងសំខាន់របស់តុក្កតាគំនិត គឺការបណ្ដុះគំនិតសិស្សឱ្យចេះគិត ពិភាក្សាលើកសំណួរថ្មីៗ សង្កេត និងលើកហេតុផលជំទាស់។ តុក្កតាគំនិតមានលក្ខណៈលើសពីសំណួរពហុជ្រើសរើស។

វិធីសាស្ត្របង្រៀនបែបតុក្កតាគំនិត គឺជាឧបករណ៍ពញ្ញាក់សិស្សពាក់ព័ន្ធការគិត និងការរុករក។ ចម្លើយទាំងអស់គឺតំណាងឱ្យការយល់បញ្ញត្តិខុសជាញឹកញយដែលកើតឡើងចំពោះអ្នកសិក្សា និងត្រូវតែមានការប្រុងប្រយ័ត្នពេលរៀនក្នុងថ្នាក់។ អ្នកសិក្សាត្រូវព្យាយាមជ្រើសរើស និងកំណត់បញ្ញត្តិត្រឹមត្រូវបំផុតដែលទាក់ទងនឹងស្ថានភាព។ លំនាំនៃការប្រដែងរវាងគំនិតផ្សេងៗ គឺជាសណ្ឋានមួយដ៏សំខាន់ក្នុងការទទួលបាននូវចំណេះដឹងបែបវិទ្យាសាស្ត្រ។ ហេតុផលនេះសមស្របសម្រាប់ការបង្រៀនកសាង ចំណេះដឹងមូលដ្ឋាន។

តុក្កតាគំនិតអាចសម្រេចបាននូវវត្ថុបំណងផ្សេងៗពីគ្នា៖

- ធ្វើឱ្យគំនិតរបស់សិស្សមានភាពច្បាស់លាស់ (អាចដឹងពីការយល់បញ្ញត្តិខុស)
- ជំរុញ និងអភិវឌ្ឍគំនិតរបស់សិស្ស
- បណ្ដុះគំនិតពិភាក្សាបែបវិទ្យាសាស្ត្រ
- ផ្ដល់នូវចំណុចចាប់ផ្ដើមសម្រាប់ការអង្កេត (មើលវគ្គដំបូងនៃការរៀនដោយផ្អែកលើការរិះរក)
- បង្កើនការចូលរួមពាក់ព័ន្ធ និងការចាប់អារម្មណ៍
- បង្កើនការយល់បានស៊ីជម្រៅលើបញ្ញត្តិវិទ្យាសាស្ត្រ។

### ង.វិធីសាស្ត្របង្រៀនបែបពិភាក្សា

ការពិភាក្សា គឺជាការផ្លោះផ្លងប្ដូរយោបល់ តាមរយៈការសិក្សាយ៉ាងសកម្ម និងចូលរួមពីសិស្សគ្រប់ជំពូក និងគ្រប់ប្រភេទ។ គឺជារបៀបរៀនយ៉ាងសកម្មរវាងគ និងសិស្ស ឬ សិស្សនិងសិស្ស ។ បើតាមអ្នកស្រាវជ្រាវ ផ្នែកចិត្តសាស្ត្របានលើកឡើងថា ការប្រើវិធីពិភាក្សា គឺអាចឱ្យសិស្សមានការគិតដល់កម្រិតខ្ពស់បំផុត និងជាដំណើរការរៀនបែបប្រជាធិបតេយ្យ។

គោលបំណងនៃការពិភាក្សា គឺដើម្បី៖

- ឱ្យសិស្សចែករំលែកព័ត៌មាន ឬចំណេះដឹងក្នុងចំណោមមិត្តរួមថ្នាក់
- ឱ្យសិស្សរួមគ្នារកចម្លើយដើម្បីដោះស្រាយបញ្ហាអ្វីមួយ និងចេះធ្វើការងារជាក្រុម
- ឱ្យសិស្សអាចមានការជឿជាក់លើខ្លួនឯង និងចេះបំផុសគំនិតផ្ទាល់ខ្លួន

### ច.វិធីសាស្ត្របង្រៀនបែបសហការ

វិធីសាស្ត្របង្រៀនបែបសហការ ជាវិធីសាស្ត្រមួយដែលសិស្សធ្វើការជាមួយគ្នាក្នុងក្រុម ដែលមានសមត្ថភាពចម្រុះ។ វិធីសាស្ត្រនេះ ជំរុញឱ្យសិស្សសហការជាក្រុម មានគ្រូជាអ្នកសម្រុះសម្រួល។ វិធីនេះជួយពង្រីកការសិក្សារបស់សិស្សឱ្យបានច្រើន និងពង្រីកទំនាក់ទំនងរបស់ពួកគេ។ ជំហានសំខាន់ៗនៃការអនុវត្តវិធីនេះមានដូចជា៖

១. គ្រូពន្យល់មេរៀនទាំងអស់ទៅសិស្សទាំងអស់ មួយ ឬពីរដង

២. សិស្សរៀនតាមមួយ ឬពីរដង។ នៅពេលពិភាក្សាក្នុងក្រុម គ្រូឱ្យក្រដាសសំណួរ និងតារាងបំពេញចម្លើយទៅសិស្សតែពីរសន្លឹក ដើម្បីឱ្យពួកគេមានទំនាក់ទំនង។ សិស្សអាចធ្វើការតែម្នាក់ឯងប្រសិនបើគេចង់ ឬពីរនាក់។ សិស្សបំពេញចម្លើយទាល់តែចប់ ចំណែកអ្នកផ្សេងត្រូវតែពន្យល់ចម្លើយនោះ គឺមិនមែនគ្រាន់តែឆ្លើយថាឯកភាពលើចម្លើយទេ។ គ្រូត្រូវដើរមើលសកម្មភាពសិស្សគ្រប់ក្រុម។

៣. សំណួរខ្លី (Quizzes) ត្រូវធ្វើទៅថ្នាក់ទាំងមូលឱ្យបានញឹកញាប់ ដើម្បីរកមើលថា ពួកគេបាន រៀនអ្វីខ្លះពីក្រុម។ សិស្សត្រូវចូលទៅអង្គុយកន្លែងរៀងៗខ្លួន ដើម្បីឱ្យពួកគេធ្វើ Quizze។ ពិន្ទុរបស់សិស្សត្រូវបានដាក់ជាមធ្យមសម្រាប់ក្រុម ហេតុនេះទើបក្រុមត្រូវជួយគ្នាពេលពិភាក្សា។

៤. ជ័យជម្នះ(ពិន្ទុ)ត្រូវយកមកប្រៀបធៀបជាមួយក្រុមផ្សេងដើម្បីរកក្រុមល្អ និងកែលម្អក្រុមដែលខ្សោយ។ រង្វាន់ត្រូវតែមានសម្រាប់ក្រុមឈ្នះ (បណ្ណសរសើរ សំបុត្រទៅឪពុកម្ដាយ) ។

៥. សមាជិកក្រុម ត្រូវផ្លាស់ប្ដូររាងរាល់ប្រាំ ឬប្រាំមួយសប្ដាហ៍ម្ដង ដើម្បីឱ្យពួកគេមាន បទពិសោធ ឬចំណេះដឹងជាមួយក្រុមថ្មី។

**ឆ. វិធីសាស្ត្របង្រៀនបែបអនុមានញែក អនុមានរួម**

**វិធីបង្រៀនបែបអនុមានញែក** គឺចាប់ផ្ដើមជាមួយនឹងចំណុចជាក់លាក់លម្អិត រូបី និងឧទាហរណ៍ ហើយបញ្ចប់ជាមួយនឹងអរូបី។ វិធីអនុមានញែក ជាដំណើរការនៃការដោះស្រាយបញ្ហាដោយអនុវត្តចំពោះបញ្ហា ឬបញ្ហាទូទៅ ដែលគេបង្កើតរួចហើយ គឺចាប់ផ្ដើមពីគោលការណ៍ទូទៅទៅរកភាពដោយឡែកៗ។ គ្រូប្រាប់ឬ បង្ហាញដោយផ្ទាល់នូវអ្វីដែលគាត់ចង់បង្រៀន។ វាសំដៅលើការបង្រៀនដោយផ្ទាល់។ អ្នករៀនមានការចូលរួមច្រើនក្នុងដំណើរការនៃការរៀន និងបង្រៀន។ វិធីនេះជួយសិស្សក្នុងការគិតពីកម្រិតទាបដល់កម្រិតខ្ពស់ ដើម្បីឈានដល់ការធ្វើទូទៅនីយកម្ម។

តើត្រូវប្រើប្រាស់វិធីអនុមានញែកដូចម្ដេច?

- ត្រូវបង្រៀនសិស្សឱ្យពន្យាការវាយតម្លៃ រហូតដល់ឃើញការពិត។
- ត្រូវតែគ្រប់គ្រងលើបញ្ហាដោយប្រើប្រាស់ការពិត ដែលបានបង្កើតឡើងដោយអ្នកដទៃ។
- ពុះពារទំនោរ ដើម្បីឈានទៅរកការសន្និដ្ឋានភ្លាមៗ។

**វិធីបង្រៀនអនុមានរួម** គឺការធ្វើឱ្យសិស្សកត់ចំណាំ ជាជាងការពន្យល់លើបញ្ញត្តិ និងដើរតាមការពន្យល់ជាមួយនឹងឧទាហរណ៍។ គ្រូត្រូវបង្ហាញសិស្សនូវឧទាហរណ៍ជាច្រើនអំពីរបៀបនៃការប្រើប្រាស់បញ្ញត្តិ។ វិធីអនុមានរួមទាក់ទងជាមួយនឹងអ្នករៀនចាប់បាន ឬចំណាំបានអំពីរបៀបនៃការអនុវត្តគោលការណ៍សម្រាប់ខ្លួនឯង។

**ជ. ការបង្រៀន និងរៀនតាមបែប៥អ៊ី** (5Es)

គំរូនៃការបង្រៀននិងរៀនតាមបែប៥អ៊ី(5Es) ជាឯកសារជំនួយសម្រាប់ថ្នាក់ដឹកនាំសាលា ក៏ដូចជាគ្រូបង្រៀន ដើម្បីជួយបង្កើនការយល់ដឹងរបស់សិស្សឱ្យកាន់តែស៊ីជម្រៅនៅក្នុងការរៀន និងអនុវត្តការបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ ជាពិសេសនៅក្នុងថ្នាក់រៀន។

គំរូនៃការបង្រៀន និងរៀនបែប៥អ៊ី(5Es)រួមមាន៖

- ចូលរួម (Engage)
- រុករក (Explore)
- ពន្យល់ (Explain)
- ពន្យល់លម្អិត ឬឈ្វេងយល់បន្ថែម (Elaborate)
- និងវាយតម្លៃ (Evaluate) ។

### ៥.៣. គុណតម្លៃគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ

គុណភាពអប់រំ គុណភាពសិស្ស អាចសម្រេចទៅបាន គឺត្រូវពឹងផ្អែកលើអ្នករៀបចំផែនការ និងអ្នកអនុវត្តផែនការ ជាពិសេសផ្តោតចម្បងលើគ្រូបង្រៀន។ ស្ថិតក្នុងបរិបទនៃការប្រែប្រួលរបស់ពិភពលោក បរិវត្តកម្មឌីជីថលវិស័យអប់រំបានឈានមកយ៉ាងរហ័ស។ ផែនការក្រសួង គឺជាផែនការរបស់យើងទាំងអស់គ្នា។ ការឈរចាំឯកសារបង្រៀនពីស្ថាប័នរៀបចំ ដោយមិនរួមចំណែកដោះស្រាយបញ្ហាចំពោះមុខ ជាហេតុផលនាំការសម្រេចបានគុណភាពអប់រំនៅតែមានភាពយឺតយ៉ាវ។ មួយវិញទៀត អ្នករៀបចំផែនការ គ្រោងការណ៍ គោលនយោបាយរួចក្តី តែបើអ្នកអនុវត្តមិនយល់ មិនចូលរួម ក្តីសង្ឃឹមប្រទេសជាតិមិនអាចសម្រេចបានឡើយ។ ឈរលើគោលជំហរនៃមនសិការជាគ្រូបង្រៀន ពិតណាស់ ត្រូវតែដឹងពីអ្វីដែលជាតម្រូវការរបស់សង្គម និងឆ្លើយតបឱ្យបានឆាប់រហ័សទើបយើងក្លាយជាចំណែកនៃដំណោះស្រាយ។ គុណតម្លៃគ្រូបង្រៀនក្នុងយុគឌីជីថលនេះ មិនអាចបន្តនៅដើរលើមាគ៌ានៃការបង្រៀនបែបឱ្យតែចប់កម្មវិធីតាមការកំណត់ប៉ុណ្ណោះទេ តែត្រូវអភិវឌ្ឍខ្លួនឱ្យក្លាយជាមនុស្សដែលជាទីពឹងដល់គេបាន។ គ្រូបង្រៀន ត្រូវជាមនុស្សដែលមានបេះដូងជាអ្នកផ្តល់ឱ្យ ជាអ្នកតម្រង់ទិសវិថីជីវិត ជាវិស្វករនៃព្រលឹង។

#### ៥.៣.១. ការអភិវឌ្ឍខ្លឹមសារមេរៀនសៀវភៅសិក្សាគោលអក្សរសាស្ត្រផ្នែកទុតិយភូមិ

ដើម្បីអនុវត្តកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ នៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ទី១១ និងទី១២ ប្រកបដោយគុណភាព និងប្រសិទ្ធភាពនោះ អ្នកពាក់ព័ន្ធគប្បីធ្វើឱ្យសម្រេចនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- **សៀវភៅសិក្សាគោល** : ការតាក់តែងសៀវភៅសិក្សាគោល ត្រូវមានទាំងសៀវភៅសម្រាប់សិស្ស និងសៀវភៅសម្រាប់គ្រូ។ សៀវភៅសិក្សាគោល ត្រូវរៀបចំឱ្យមានភាពគ្របដណ្តប់ខ្លឹមសាររបស់កម្មវិធីសិក្សា និងមានចង្អុលបង្ហាញពីខ្លឹមសារគន្លឹះសំខាន់ៗ វិធីសាស្ត្រ ម៉ោងសិក្សា សម្ភារឧទេស ការវាយតម្លៃ និងផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង។ ការរៀបចំសៀវភៅសិក្សាគោល ត្រូវធានាថា សិស្សគ្រប់តំបន់ ជនជាតិ ជនពិការ អាចយកមកច្នៃប្រឌិតអនុវត្តបានទាំងអស់គ្នា។
- **សៀវភៅសិក្សាគោល** គប្បីអភិវឌ្ឍទៅតាមបណ្តុំមុខវិជ្ជា គឺបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានសៀវភៅសម្រាប់សិស្ស និងសម្រាប់គ្រូ ដោយអភិវឌ្ឍទៅតាមបំណែងចែកម៉ោងសិក្សា និងបំណែងចែកសមាសភាគលទ្ធផលសិក្សា ទៅតាមបណ្តុំមុខវិជ្ជាសិក្សា។ ចំណែកឯកសារជំនួយ និងសម្ភារឧបទេសដទៃទៀត ក៏ត្រូវបានអភិវឌ្ឍ ដើម្បីជួយពង្រឹងការរៀននិងបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។
- **ការអភិវឌ្ឍសៀវភៅសិក្សាគោល** បានទាន់ពេលវេលាគឺត្រូវតែមានការចូលរួមពីបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ពិសេសគ្រូបង្រៀន ដែលជាតួអង្គប្រឈមផ្ទាល់ក្នុងបញ្ហា។ គ្រូបង្រៀនត្រូវតែមានវិធីសាស្ត្រសម្របសម្រួលខ្លឹមសារមេរៀននៃសៀវភៅសិក្សាគោល ទាំងការកែកំហុសអចេតនាមួយចំនួនដូចជាអក្ខរាវិរុទ្ធ ខ្លឹមសារ ជាដើម។ លើសពីនេះ ចំណុចសំខាន់បំផុតគឺការអភិវឌ្ឍខ្លឹមសារនៃការបង្រៀនស្របតាមបរិបទនៃសង្គម និងស្របតាមផែនការនៃកម្មវិធីសិក្សារបស់ក្រសួង ព្រោះការផ្លាស់ប្តូរសៀវភៅគោលតែម្តងវាត្រូវមានដំណើរការតាមដំណាក់កាលច្បាស់លាស់។

#### ៥.៣.២. កំណែទម្រង់កម្មវិធីសិក្សា

ការកែទម្រង់កម្មវិធីសិក្សា ជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ចសង្គម និងវប្បធម៌កម្ពុជាក្នុងសម័យបច្ចុប្បន្ន និងស្របពេលដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ទស្សនវិជ្ជា មានទំនោរកំណត់បញ្ចូលលទ្ធផលសិក្សា ជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សា បានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិតគរុកោសល្យ និងវិធីសាស្ត្របង្រៀន។ ការកែទម្រង់កម្មវិធីសិក្សា ជាផ្នែកមួយនៃកំណែ

ទម្រង់វិស័យអប់រំនៅកម្ពុជា ដែលក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យ កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យក្លាយជាសង្គមរីកចម្រើនលើផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីរចំណុចគឺ(១)ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និង លើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត និង(២)ធានាភាពសក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបាន គឺត្រូវពឹងផ្អែកទៅលើសសរស្តម្ភទាំង៥ រួមមាន (១)ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងវិញកម្មវិធីសិក្សាសៀវភៅសិក្សាគោល និង កែលម្អបរិស្ថាន (៣)ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និង(៥)ការកែទម្រង់ឧត្តមសិក្សា។




ក្រសួងបានរៀបចំរចនាសម្ព័ន្ធដែលមានអនុវិស័យទាំង៧ ក្នុងនោះរួមមាន (១)អនុវិស័យការអប់រំកាយនិងកីឡា (២)អនុវិស័យការអភិវឌ្ឍយុវជន (៣)អនុវិស័យការអប់រំក្រៅប្រព័ន្ធ (៤)អនុវិស័យការអប់រំឧត្តមសិក្សា (៥)អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស (៦)អនុវិស័យការអប់រំបឋមសិក្សា និង(៧)អនុវិស័យការអប់រំកុមារតូច។

ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់ ១៥ចំណុចគឺៈ (១)ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២)ការពង្រាយគ្រូបង្រៀន (៣)កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន (៤)ការលើកកម្ពស់គុណវុឌ្ឍគ្រូបង្រៀន (៥)ការងារអធិការកិច្ច (៦)វង្វាយតម្លៃលទ្ធផលសិក្សា (៧)កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ (៨)កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សា (៩)ការសាងសង់អគារសិក្សានិងការជួសជុល (១០)ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១)ការលើកកម្ពស់វិស័យកីឡា (១២)ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (១៣)ការអប់រំបច្ចេកទេស (១៤)ការបង្កើតសាលារៀនជំនាន់ថ្មី និង(១៥)ការរៀបចំគន្លងអាជីព និងបណ្តុះបណ្តាលនាយកសាលា។

### ៥.៣.៣. ការសិក្សាស្នាដៃអក្សរសិល្ប៍ ជាទុននៃការត្រៀមសរសេរតែងសេចក្ដីបានល្អ

ចាប់ពីឆ្នាំ២០១៤មក ក្រសួងបានរៀបចំកែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំពោះមុខវិជ្ជាអក្សរសាស្ត្រខ្មែរ មកត្រឹមសំណេរតែងសេចក្ដីមួយប៉ុណ្ណោះ។ ត្រង់ចំណុចនេះ តែងសេចក្ដីមិនមែនជាការងាយស្រួលក្នុងការសរសេរនោះឡើយបើពុំមានទុនពុទ្ធិ និងរបៀបនៃការសរសេរច្បាស់លាស់នោះ។

ដើម្បីជាទុនក្នុងការសរសេរតែងសេចក្ដី ដែលស្ថិតក្នុងមុខវិជ្ជាអក្សរសាស្ត្រខ្មែរ នៅក្នុងការប្រឡងប្រជែងនានាពិសេសការប្រឡងមធ្យមសិក្សាទុតិយភូមិ គ្រូបង្រៀនត្រូវបង្ហាញផ្លូវដើរច្បាស់លាស់ និងចេះដកស្រង់យកវិធីសាស្ត្របង្រៀននានាស្របតាមស្ថានភាពជាក់ស្តែងមកបង្រៀន។




### ក. អក្សរសិល្ប៍ខ្មែរ

- ព្រាហ្មណ៍និយម ជារឿងដែលទាក់ទងនឹងព្រាហ្មណ៍សាសនា ដូចជា រឿងរាមកេរ្តិ៍ខ្មែរ។
- ពុទ្ធនិយម ជារឿងដែលទាក់ទងនឹងសាសនាព្រះពុទ្ធ ដូចជា
  - រឿងមួយចំនួនក្នុងទសជាតក(ព្រះវេស្សន្តរ តេមិយ ព្រះមហោសថ សុវណ្ណសាម...)
  - រឿងមួយចំនួនក្នុងបញ្ញាសជាតក(រឿងហង្សយន្ត ចៅស្រទបចេក... )
- ខេមរនិយម៖ គឺគេសំដៅទៅលើស្នាដៃអក្សរសិល្ប៍ណាដែលបានបកស្រាយបង្ហាញពីជីវភាព ប្រពៃណី ទំនៀមទំលាប់របស់ជនជាតិខ្មែរយើងនៅក្នុងសម័យកាលមួយច្បាស់លាស់យកមកបង្ហាញ។ មានដូចជា៖
  - រឿងមួយចំនួនក្នុងប្រជុំរឿងព្រេងខ្មែរ
  - រឿងទុំទាវ(ភិក្ខុសោម)
  - រឿងតេជោយ៉ត(ទី ជីហួត)
  - រឿងតេជោដំឌិន (តាមាស)
  - រឿងសូផាត (រីម គីន)
  - រឿងភូមិតិរច្ឆាន(ឌឹក គាម និងឡៅ អ៊ំ)
  - រឿងគូលីកំណែន(អ៊ឹម ថុក)

- រឿងគ្រូបង្រៀនស្រុកស្រែ (អ៊ឹម ថុក)
- រឿងស៊ីមអ្នកបរឡាន (អ៊ឹម ថុក)
- រឿងថៅកែចិត្តចោរ (ពៅ យូឡេង អ៊ុំ ឈឺន)
- រឿងព្រះអាទិត្យថ្មីរះលើ ផែនដីចាស់(សួន សុរិន្ទ)
- រឿងល្ខោន និងយីកេខ្មែរមួយចំនួនទៀត។

**ខ. អក្សរសិល្ប៍បរទេស**

- អក្សរសិល្ប៍ឥណ្ឌា (រឿងរាមាយណៈ, រឿងមហាភារតយុទ្ធ)
- អក្សរសិល្ប៍អង់គ្លេស (រឿងហាំលែត, រឿងរ៉ូមេអូ និងជូលីយ៉ែត)
- អក្សរសិល្ប៍ក្រិច (រឿងអ៊ីលីយ៉ាត និងអូឌីសេ)
- អក្សរសិល្ប៍បារាំង (រឿងជនកំណាញ់, រឿងទុរគតជន)
- អក្សរសិល្ប៍ចិន (រឿងអាណាចក្របី)
- និងរឿងមួយចំនួនទៀត របស់ប្រទេសនានាក្នុងតំបន់ និងលើពិភពលោក។

**គ. ការសិក្សាអត្ថបទអក្សរសិល្ប៍**

ទាំងបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ត្រូវសិក្សាវិភាគអត្ថបទ[6]៖

- ថ្នាក់ទី១០ : រឿងទុំទាវ និងរឿងតេជោយ៉ត
- ថ្នាក់ទី១១ : រឿងមហាវេស្សន្តរជាតក និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
- ថ្នាក់ទី១២ : រឿងរាមកេរ្តិ៍ និងរឿងថៅកែចិត្តចោរ។




*ប្រភព៖ កម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរ កម្រិតមធ្យមសិក្សាទុតិយភូមិ ២០១៨*

---

[6] កម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរ កម្រិតមធ្យមសិក្សាទុតិយភូមិ ២០១៨

### ៥.៣.៤. គុណតម្លៃខ្លៃប្រឌិតមេរៀនសម្រាប់បង្រៀនឱ្យស្របកម្មវិធី

#### ៥.៣.៤.១. អក្សរសិល្ប៍ក្នុងកម្មវិធីសិក្សា ថ្នាក់ទី១០

វិធីនេះជួយឱ្យសិស្សអាចងាយចាប់បាននូវខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោល និងអាចដកស្រង់ដើម្បីឆ្លើយតបក្នុងការបង្ហាត់បង្រៀនគ្រឹះសំខាន់ៗនៃតែងសេចក្ដី ជាទុនពុទ្ធិស្របតាមការប្រឡងថ្នាក់ជាតិ។

| ល.រ. | ចំណងជើងរឿង | អ្នកនិពន្ធ និងឆ្នាំនិពន្ធ បោះពុម្ព | ទំព័រ |
|---|---|---|---|
| ១ | រឿងក្រពើឈ្មោះអាធន | ប្រជុំរឿងព្រេងខ្មែរភាគ៥ | ទំ.២ |
| ២ | រឿងវត្តវិហារសួគ៌ | ប្រជុំរឿងព្រេងខ្មែរ ភាគ៥ | ទំ.៣ |
| ៣ | រឿងវត្តសំពៅប្រាំ | ប្រជុំរឿងព្រេងខ្មែរភាគ៦ | ទំ.៤ |
| ៤ | រឿងភ្នំបាយ៉ង់កោរ នៅខេត្តតាកែវ | ប្រជុំរឿងព្រេងខ្មែរ ភាគ៥ | ទំ.៥ |
| ៥ | រឿងតាដុងយាយជ័យ | ប្រជុំរឿងព្រេងខ្មែរ ភាគ៥ | ទំ.១៣ |
| ៦ | រឿងភូមិតិរច្ឆាន | ឌឹកគាម ឌឿកអំ (១៩៦៤-៦៥) | ទំ.១៤ |
| ៧ | រឿងកុលាបប៉ៃលិន | ញ៉ុក ថែម គ.ស.១៩៦០ | ទំ.១៦ |
| ៨ | រឿងព្រេងទាក់ទងនឹងបុណ្យភ្ជុំបិណ្ឌ-បណ្ដែតដូនតា | ប្រជុំរឿងព្រេងខ្មែរ ភាគ៩ | ទំ.១៧ |
| ៩ | រឿងប្រាសាទអង្គរវត្ត | ប្រជុំរឿងព្រេងខ្មែរ ភាគ៥ | ទំ.១៩ |
| ១០ | រឿងផ្កាស្រពោន | នូហាច ១៩៤៧ | ទំ.៣៤ |
| ១១ | រឿងទំនៀមចោះត្រចៀកកូនស្រី | ប្រជុំរឿងព្រេងខ្មែរ ភាគ៩ | ទំ.៥៣ |
| ១២ | រឿងរាមាយណៈ | អក្សរសិល្ប៍បរទេសក្រសួងអប់រំ ១៩៨៧ | ទំ.៦០ |
| ១៣ | រឿងរាមកេរ្តិ៍ (ខ្សែទី១) | បោះពុម្ព ព.ស.២៥៣៩ គ.ស.១៩៩៥ | ទំ.៦៤ |
| ១៤ | រឿងសូផាត | រីម គីន ១៩៣៨ បោះពុម្ព១៩៦៦ | ទំ.៦៧ |
| ១៥ | រឿងសិរិធរ | បញ្ញាសជាតក | ទំ.៨០ |
| ១៦ | រឿងចន្ទរាជ | បញ្ញាសជាតក (ញ៉ុក ថែម) | ទំ.៨៨ |
| ១៧ | រឿងព្រះវេស្សន្តរ | ទសជាតក | ទំ.៩៤ |
| ១៨ | រឿងព្រះតេមិយ | ទសជាតក | ទំ.១០៦ |
| ១៩ | រឿងទុំទាវ | ភិក្ខុងួន សោម (១៩១៥) | ទំ.១២០ |
| ២០ | រឿងក្បួនជីវិត(មាគ៌ជីវិតមាលា) | ទី ជីហួត | ទំ.១៣៩ |
| ២១ | គ្រូបង្រៀនស្រុកស្រែ(ពេជ្រនឹងត្បូងថ្នែ) | អ៊ឹម ថុក (១៩៥៧) | ទំ.១៦០ |
| ២២ | រឿងត្រពាំងបិសាច(ជប៉ុន) | បកប្រែដោយ ប៉ែន សេដ្ឋារិន ២០០២ | ទំ.១៨២ |
| ២៣ | រឿងសុបិនកុមារ | បញ្ញាសជាតក | ទំ.២០៣ |
| ២៤ | រឿងបណ្ដែតប្រទីព សំពះព្រះខែ អកអំបុក | ប្រជុំរឿងព្រេងខ្មែរ ភាគ៩ | ទំ.២១៨ |

## ៥.៣.៤.២.ការបង្កើតប្រធានតែងសេចក្ដី ស្រង់ពីក្នុងសៀវភៅសិក្សាគោល ថ្នាក់ទី១០

1. មតិមួយពោលថា«**អត្តសញ្ញាណជាតិ គឺជាគ្រឿងសម្គាល់ ជាទីអាងនូវលក្ខណៈពិសេស និងដោយឡែករបស់ជាតិសាសន៍នីមួយៗ**»។ តើមានន័យដូចម្ដេច? ចូរពន្យល់។ (ទំ.៣៣)
2. សង្គមបរិយាកាស គឺជាដំណើររឿងដែលអ្នកនិពន្ធលើកមកបង្ហាញស្ថិតក្នុងសម័យណាមួយ ហើយមានព្រឹត្តិការណ៍សង្គមអ្វីខ្លះ នៅក្នុងរឿងគួរឱ្យកត់សម្គាល់ក្នុងស្នាដៃរបស់ខ្លួន។ ចូរអ្នកអធិប្បាយពី«**សង្គមបរិយាកាសក្នុងរឿងផ្កាស្រពោន មាលាដួងចិត្ត កុលាបប៉ៃលិន និងរឿងទុំទាវ**» ដោយលើកយកអំណះអំណាងមកបញ្ជាក់ឱ្យបានក្បោះក្បាយ។ (ទំ.៣៧)
3. ឃ្លាកំណាព្យបុរាណមួយពោលថា«**ចំណេះកើតមានពីការរៀន កម្ជិលអៀនប្រៀនកុំសម្ដែង ធ្វើឱ្យគេស្ងើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ**»។ តើឃ្លាកំណាព្យមានន័យដូចម្ដេច? ចូរពន្យល់។
4. ឃ្លាកំណាព្យបុរាណមួយពោលថា«**បុរាណថាថោកអីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើរើ រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះទើបប្រសើរ**»។ តើឃ្លាកំណាព្យមានន័យដូចម្ដេច? ចូរពន្យល់។ (ទំ.៥១)
5. ឃ្លាកំណាព្យបុរាណមួយពោលថា«**ចាស់ថាបើល្ងង់កុំធ្វើចេះ បើមានចំណេះឱ្យជាក់ច្បាស់ បើស្ងើងហើយចង់ឱ្យបានក្រាស់ ត្រូវថែមកម្រាស់ផ្សំសាច់គ្នា**»។ តើឃ្លាកំណាព្យមានន័យដូចម្ដេច? ចូរពន្យល់។(ទំ.៥១)
6. ឃ្លាកំណាព្យបុរាណមួយពោលថា«**ចំណេះកើតមានពីការរៀន កម្ជិលអៀនប្រៀនកុំសម្ដែង ធ្វើឱ្យគេស្ងើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ**»។ តើឃ្លាកំណាព្យមានន័យដូចម្ដេច? ចូរពន្យល់។(ទំ.៥១)
7. ទស្សនៈមួយពោលថា«**អំពើអហិង្សា ជាប្រភពនៃការអភិវឌ្ឍសង្គម**»។ ចូរពន្យល់។ (ទំ.៨២)
8. ទស្សនៈមួយពោលថា«**សប្បុរសធម៌រួមចំណែកកាត់បន្ថយទុរគតភាពក្នុងសង្គម**»។ ចូរពន្យល់។ (ទំ.៨២)
9. គេពោលថា«**ការបំបរបង់ព្រះរាមចេញពីនគររយៈពេលដប់បួនឆ្នាំ គឺដោយសារពាក្យសត្យ**»។ ចូរអ្នកបកស្រាយពំនោលខាងលើនេះ។ (ទំ.៨៣)
10. ចូរពន្យល់ទស្សនៈដែលថា«**សេរីភាព គឺជាបំណងប្រាថ្នារបស់មនុស្ស**»។ (ទំ.៨៥)
11. ទស្សនៈមួយពោលថា«**ការគោរពច្បាប់នាំឱ្យសង្គមជាតិមានការអភិវឌ្ឍ**»។ ចូរពន្យល់។ (ទំ.៨៥)
12. មតិមួយពោលថា«**ជីវិតមានតម្លៃអាស្រ័យការកសាងអំពើសុចរិតទៀងត្រង់**»។ ទំ.៨៧)
13. មតិមួយពោលថា«**គោលដៅជាមូលដ្ឋានរបស់វប្បធម៌ គឺមនុស្ស**»។ ចូរពន្យល់។ (ទំ.១០៤)
14. សំណេរសំយោគស្ដីពី«**បញ្ហាដើមកំណើតខ្មែរ**»។ (ទំ.១៣២)
15. សុភាសិតខ្មែរមួយឃ្លាពោលថា«**ឈើកោងវល្លិព័ទ្ធ មនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត**»។ (ទំ.១៤៦)
16. សុភាសិតខ្មែរ«**សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា**»។ ចូរពន្យល់។ (ទំ.១៤៦)
17. ឃ្លាកំណាព្យចាស់បុរាណពោលថា«**ដឹងធ្វើយត្បិតដង កូនប្រុសវែងឆ្លង ត្បិតតែឪពុក ទ្រព្យគង់ត្បិតស្រី ចេះរៀបដាក់ទុក ផ្ទះធំស្រណុក ត្បិតភរិយាជា**»។ ចូរពន្យល់។ (ទំ.១៤៦)
18. សុភាសិតខ្មែរចែងថា«**ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់ឡើយ**»។ ចូរពន្យល់។ ទំ.១៤៦)
19. សុភាសិតខ្មែរចែងថា«**ដើយស្កុក ឱនដាក់គ្រាប់**»។ ចូរពន្យល់។ (ទំ.១៥១)
20. សុភាសិតខ្មែរចែងថា«**តក់ៗពេញបំពង់**»។ ចូរពន្យល់។ (ទំ.១៥២)
21. សុភាសិតខ្មែរចែងថា«**ត្រីមួយត្រកស្អុយមួយស្អុយទាំងអស់**»។ ចូរពន្យល់។(ទំ.១៥២)
22. សុភាសិតខ្មែរចែងថា«**ចេះពីរៀន មានពីរក**»។ ចូរពន្យល់។(ទំ.១៥៤)
23. សុភាសិតខ្មែរចែងថា«**ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ**»។ ចូរពន្យល់។ (ទំ.១៥៥)

24. សុភាសិតខ្មែរចែងថា«**ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក**»។ ចូរពន្យល់។(ទំ.១៥៦)
25. ច្បាប់កូនចៅ របស់បណ្ឌិតម៉ឺនម៉ៃលើកថា«**លោកថាឆ្គួតបី ឆ្គួតមួយនឹងស្រី ឆ្គួតមួយនឹងស្រា ឆ្គួតមួយនឹងល្បែង អំពើពាលា ឆ្គួតនេះហៅមហា ឆ្គួតក្រៃកន្លង**»។ ចូរពន្យល់។(ទំ.១៧៣)
26. ការយល់ច្រឡំភ្លេងពិណពាទ្យ ជាភ្លេងសៀម។ (ទំ.១៩៤)
27. មានពំនោលមួយឃ្លាចែងថា«**ក្នុងអត្ថបទតថភាពនាសម័យអាណានិគមនិយមបានឆ្លុះឱ្យឃើញពីផ្នត់គំនិតខ្មែរ**»។ ចូរពន្យល់។ (ទំ.២៣១)
28. ទស្សនៈមួយចែង «**ក្នុងរឿងបណ្ដែតប្រទីប សំពះព្រះខែ អកអំបុក បានបង្ហាញពីជំនឿរបស់ជនជាតិខ្មែរ**»។ ចូរពន្យល់ដោយលើកឧទាហរណ៍មកបញ្ជាក់។ (ទំ.២៣៣)
29. គំនិតជាតិនិយមមួយឃ្លាយល់ថា«**តាមរយៈវិស័យជំនឿ នាំគេឱ្យស្គាល់ពីលក្ខណៈជាតិ**»។ ចូរពន្យល់ដោយលើកយកឧទាហរណ៍មកបញ្ជាក់។ (ទំ.២៣៣)
30. តាមទស្សនៈរបស់បុព្វបុរសខ្មែរមួយឃ្លាចែងថា« **ផ្នត់គំនិតជាតិ គឺជាអត្តសញ្ញាណជាតិ**»។ ចូរពន្យល់ដោយរកអំណះអំណាងមកបញ្ជាក់ ។(ទំ.២៣៣)
31. គេថា«**ឱសថជាអាវុធមុខពីរ**»។ ចូរពន្យល់។
32. គេលើកឡើងថា«**ការជ្រើសរើសគូស្រករ ដោយមានការឯកភាពពីសាមីខ្លួន និងឪពុកម្ដាយ ជាវិធីដ៏ល្អប្រពៃសម្រាប់យុវវ័យ**»។ តើហេតុអ្វី គេពោលដូចនេះ? ចូរពន្យល់។

### ៥.៣.៤.៣. អក្សរសិល្ប៍ក្នុងកម្មវិធីសិក្សា ថ្នាក់ទី១១

| ល.រ. | ចំណងជើងរឿង | អ្នកនិពន្ធ និងឆ្នាំនិពន្ធ បោះពុម្ព | ទំព័រ |
|---|---|---|---|
| ១ | រឿងនាងកុលធីតា | ប្រជុំរឿងព្រេងខ្មែរ ភាគ៩ ឆ្នាំ១៩៧៤ | ទំ.១១ |
| ២ | រឿងភ្នំនាងកង្រី | ប្រជុំរឿងព្រេងខ្មែរ ភាគ៥ ព.ស.២៥៤៧ គ.ស.២០០៣ | ទំ.១៥ |
| ៣ | រឿងព្រះពាន់ | ប្រជុំរឿងព្រេងខ្មែរ ភាគ៦ | ទំ.១៨ |
| ៤ | រឿងទុំទាវ | ភិក្ខុ ង៉ួន សោម (១៩១៥) ព.ស.២៤៥៨ | ទំ.២៨ |
| ៥ | រឿងភូមិតិរច្ឆាន | ឌឹក គាម និងឡៅ អំ (១៩៦៤-៦៥) | ទំ.៤៨ |
| ៦ | រឿងអ្នកតាឃ្លាំងមឿង | ប្រជុំរឿងព្រេងខ្មែរ ភាគ៨ | ទំ.៦២ |
| ៧ | រឿងតេជោយ៉ត | ទី ជីហ្វូត (២៨ ធ្នូ ១៩៨៣) | ទំ.៧១ |
| ៨ | រឿងចៅកែចិត្តចោរ | ពៅ យូឡេង និងអ៊ំ ឈឺន (០៩ តុលា ១៩៥៦) | ទំ.៨៧ |
| ៩ | រឿងរាមកេរ្តិ៍ (ខ្សែទី១) | វិជ្ជាធាយាវង្ស (បោះពុម្ព គ.ស.១៩៩៥ , ព.ស.២៥៣៩) | ទំ.១៣៤ |
| ១០ | រឿងសុវណ្ណសាម | ឈឹម ស៊ុមន៍ (បោះពុម្ព ព.ស.២៥១៤, គ.ស.១៩៧១) | ទំ.១៤៧ |
| ១១ | រឿងគូលីកំនែន | អ៊ឹម ថុក (១៩៥៦) | ទំ.១៧៨ |
| ១២ | រឿងព្រះអាទិត្យថ្មីរះ..ផែនដីចាស់(ទុំគីតជន) | សួន សុរិន្ទ (១៩៦០-៦១) | ទំ.១៨៩ |
| ១៣ | រឿងអង់ទីហ្គូនវីរនារីក្រុងថែប | សូហ្វូក្ល (ស.វ.ទី៥ មុនគ.ស.) | ទំ.២០០ |
| ១៤ | រឿងកិត្តិយស ឬស្នេហា | ព្យែគ័រណី (១៦៣៧) | ទំ.២១០ |

| | | | |
|---|---|---|---|
| ១៥ | រឿងជនកំណាញ់ | ម៉ូលីយែរ (១៦៦៨) | ទំ.២១៦ |
| ១៦ | រឿងគ្រូបង្រៀនស្រុកស្រែ | អ៊ឹម ថុក (១៩៥៧) | ទំ.២២៦ |
| ១៧ | រឿងឪពុកក្មេករើសកូនប្រសា | ដកស្រង់ពីអក្សរសិល្ប៍ថ្នាក់ទី៦ បោះពុម្ព១៩៨២ | ទំ.២៣៧ |

### ៥.៣.៤.៤. បង្កើតប្រធានតែងសេចក្តី ស្រង់ពីក្នុងសៀវភៅសិក្សាគោល ថ្នាក់ទី១១

33. ចូរពន្យល់«**កូនគោកាចកៀច និងនំមិនធំជាងនាឡិ**»។ (ទំ.៣២)
34. ចូរពន្យល់«**ក្តៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ**»។ (ទំ.៧៩)
35. ចូរបង្ហាញឱ្យឃើញថា «**អំពើរបស់តួអង្គថៅកែ តួអង្គពូហំ ជាអំពើខុសឆ្គងនឹងផ្លូវពុទ្ធចក្រ អាណាចក្រ និងសីលធម៌**» ដោយរកអំណះអំណាងបញ្ជាក់។ (ទំ.៩៤)
36. តួអង្គហំថា«កុំ**អាងទឹកប្រាក់ហើយមើលងាយមនុស្ស**» ចំណែកថៅកែថា«**កុំអាងទឹកចិត្តមនុស្សធម៌ហើយមើលងាយកម្លាំងប្រាក់**»។ ចូរពិភាក្សា។ (ទំ.៩៤)
37. គេថា«**វត្តអារាមពុទ្ធសាសនាមានតួនាទីសំខាន់ណាស់ចំពោះសង្គមខ្មែរ**»។ (ទំ.១២៥)
38. មុនពេលនេនទុំនិមន្តទៅទេសនានៅផ្ទះម្តាយទាវ នេនពេជ្រទូន្មានថា«**ថាដើរមានប្អូនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ បើដើរទៅក្តីបាសកសោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ**»។ ចូរពន្យល់។ (ទំ.១២៨)
39. ចូរបង្ហាញពី«**តម្លៃអប់រំតាមរយៈការគោរពសាសនាព្រាហ្មណ៍ និងការសាសនាព្រះពុទ្ធ**»។ (ទំ.១៤៥)
40. ចូរធ្វើការប្រៀបធៀបលក្ខណៈសម្បត្តិតួអង្គ«**នាងសីតា**»ក្នុងរឿងបែបព្រាហ្មណ៍និយម និងតួអង្គ«**នាងមទ្រី**»ក្នុងរឿងបែបពុទ្ធនិយម។ (ទំ.១៤៨)
41. ចូរបង្ហាញពីលក្ខណៈខុសគ្នានៃប្រភេទអក្សរសិល្ប៍ និងចលនាអក្សរសិល្ប៍ ។ (ទំ.១៥៩)
42. អ្នកនិពន្ធម្នាក់បានពោលថា «**អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះមើលការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ តែវាជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់អប់រំ ផ្សព្វផ្សាយអរិយធម៌ វប្បធម៌ជាតិ**»។ ចូរពន្យល់។ (ទំ.១៥៩)
43. ចូរពណ៌នាអំពី**លក្ខណៈអក្សរសិល្ប៍**ដោយផ្សារភ្ជាប់ជាមួយឧទាហរណ៍ផង។ (ទំ.១៥៩)
44. តាមការសិក្សាបង្ហាញថា«**អក្សរសិល្ប៍ គឺជាការសិក្សាពីមនុស្សនិងដើម្បីមនុស្ស**»។ ចូរពន្យល់។ (ទំ.១៥៩)
45. ចូរបង្ហាញពី«**វប្បធម៌ជាតិ ដែលឆ្លុះបញ្ចាំងតាមរយៈសិលាចារឹក**»។ (ទំ.១៦៥)
46. មតិមួយពោលថា«**លក្ខណៈតថៈក្នុងអក្សរសិល្ប៍ គឺជាសច្ចភាពរបស់សម័យកាលណាមួយ**» ដែលអ្នកនិពន្ធបានលើកយកមកកែច្នៃជាមួយគំនិតផ្ទាល់ខ្លួន ដើម្បីបង្កើតជាស្នាដៃ និម្មិតកម្មឡើង។ ចូរពន្យល់។ (ទំ.១៧៦)
47. អ្នកនិពន្ធរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ពោលថា«**អ្នករត់ទាំងឡាយ គេរត់ប្រណាំងប្រជែងគ្នាយករង្វាន់ តែសមរត់ប្រណាំងនឹងការដាច់ពោះស្លាប់**»។ ហេតុអ្វីអ្នកនិពន្ធពោលបែបនេះ? ចូរពន្យល់។
48. ចូរបកស្រាយអត្ថន័យសុភាសិត«**សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា**»។ (ទំ.១៩០)
49. ចូរពន្យល់សុភាសិត«**ត្រីកំភ្លាញស្លាប់ព្រោះមាត់ ខ្វែកងាប់ព្រោះអាចម៍**»។ (ទំ.១៩១)
50. ទស្សនៈមួយពោលថា«**ការអប់រំ គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ**»។ ចូរពន្យល់។ (ទំ.១៩១)
51. ចូរពន្យល់សុភាសិត«**ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក**»។ (ទំ.១៩១)
52. ចូរពន្យល់ឃ្លាថា«**ត្រូវដំដែកក្នុងពេលដែកកំពុងក្តៅ**»។ (ទំ.១៩១)

53. មតិមួយពោលថា«**តថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែន គ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំបានផ្តល់តម្លៃអប់រំដល់អ្នកសិក្សានោះទេ**»។ ចូរពិភាក្សា។(ទំ.១៩២)
54. មតិមួយពោលថា«**ហាំ ប្រព្រឹត្តអំពើមនុស្សឃាតដោយសារស្ថានភាពគ្រួសារបង្ខំ**»។ តើអ្នកយល់យ៉ាងណាដែរចំពោះមតិខាងលើនេះ? ចូរពិភាក្សា។ (ទំ.១៥៦)
55. សុភាសិតឃ្លាមួយចែងថា«**ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់**»។ តើអ្នកយល់យ៉ាងណាចំពោះសុភាសិតនេះ? ចូរពិភាក្សាដោយលើកឧទាហរណ៍មកបញ្ជាក់។ (ទំ.១៥៦)
56. ចូរបង្ហាញថា«**រឿងទុំទាវមានលក្ខណៈអន្តរជាតិ**»។ ទំ.២០២)
57. ចូរបកស្រាយវាចាខុងជឺ«**ធ្វើគុណទៅហើយ បើគេតបគុណមកវិញ ចាត់ទុកជាពុំបានធ្វើគុណ**»។ (ទំ.២០៦)
58. ចូរបកស្រាយវាចាខុងជឺ«**ធ្វើគុណទៅហើយ ត្រឡប់បានជាផលអាក្រក់មកវិញ ត្រូវទទួលយកការពិសោធដោយដៃពីរ**»។ (ទំ.២០៦)
59. ចូរបកស្រាយវាចាខុងជឺ«**ធ្វើគុណទៅហើយ បើវាលោយសូន្យទៅ ត្រូវបន្តការធ្វើគុណទៅទៀត ប្រៀបដូចត្រី បើវាចឹកនុយអស់ហើយ គេត្រូវយកសន្ទូចបិទនុយថែមទៀត**»។ (ទំ.២០៦)
60. ចូរបង្ហាញពីលក្ខណៈជាតិ លក្ខណៈមនុស្ស និងលក្ខណៈសង្គម តាមរយៈរឿងគ្រូបង្រៀនស្រុកស្រែ។(ទំ.២៣៤)
61. ចូរបង្ហាញពី«**គំនិតសុទិដ្ឋិនិយម**» តាមរយៈតួអង្គហមក្នុងរឿងគ្រូបង្រៀនស្រុកស្រែ។ (ទំ.២៣៤)

### ៥.៣.៤.៥. អក្សរសិល្ប៍ក្នុងកម្មវិធីសិក្សា ថ្នាក់ទី១២

| ល.រ. | ចំណងជើងរឿង | អ្នកនិពន្ធ និងឆ្នាំនិពន្ធ បោះពុម្ព | ទំព័រ |
|---|---|---|---|
| ១ | **រឿងទុំទាវ** | ភិក្ខុសោម (១៩១៥) | (ទំ.១៣) |
| ២ | **រឿងរាមកេរ្តិ៍** | វឌ្ឍឆាយាវង្ស (បោះពុម្ព គ.ស.១៩៩៥ , ព.ស.២៥៣៩) | (ទំ.៤៦) |
| ៣ | **រឿងព្រះវេស្សន្តរ** | ញ៉ុក ថែម (បោះពុម្ព ១៩៩០) | (ទំ.៧៧) |
| ៤ | រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ | សួន សុរិន្ទ (១៩៦០-៦១) | (ទំ.១០០) |
| ៥ | រឿងតេជោយ៉ត | ទី ជីហួត (២៨ ធ្នូ ១៩៨៣) | (ទំ.១៣១) |
| ៦ | រឿងថៅកែចិត្តចោរ | ពៅ យូឡេង និងអ៊ំ ឈឺន (០៩ តុលា ១៩៥៦) | (ទំ.១៤៥) |
| ៧ | រឿងគូលីកំនែន | អ៊ឹម ថុក (១៩៥៦) | (ទំ.១៧៤) |
| ៨ | រឿងតេជោដំឌិន | តាមាស (១៩២៤) | (ទំ.២០៨) |
| ៩ | រឿងរាមាយណៈឥណ្ឌា | ឥសី**វាល្មិកិ** (ស.វ.ទី៣ មុនគ.ស.) | (ទំ.២២៦) |
| ១០ | រឿងហង្សយន្ត | ចៅយមបុណ្យភក្តិព្រះស្នេហ៍អនុសឹក ឧក (១៦៦៨) | (ទំ.២៣២) |
| ១១ | រឿងហាំលែត | ហ្សាក់ហង្សរី ប៊ែរណាដាំង ដឺសាំងព្យែរ (១៧៨៧) | (ទំ.២៤៨) |
| ១២ | រឿងប៉ូលវីរហ្សីនី | វីល្លីយ៉ាម សេកស្ពៀរ (១៦០១) | (ទំ.២៦១) |

### ៥.៣.៤.៦. បង្កើតប្រធានតែងសេចក្ដី ស្រង់ពីក្នុងសៀវភៅសិក្សាគោល ថ្នាក់ទី១២

<u>មេរៀនទី១៖ អក្សរសិល្ប៍ខេមរនិយម</u>

1. ខ្មែរយើងទទួលឥទ្ធិពលពីសាសនាធំៗពីរ គឺ«**ព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា**»។ ចូរអ្នកបំភ្លឺ។ (ទំ.១)
2. អ្នកសិក្សាអក្សរសិល្ប៍ពោលថា«**អក្សរសិល្ប៍ខេមរនិយម ជាស្នាដៃបង្ហាញពីផ្នត់គំនិត វប្បធម៌ នៃប្រជាជនខ្មែរនាសម័យកាលនីមួយៗ**»។ ចូរអធិប្បាយបំភ្លឺ។(ទំ.១)
3. គេថា«**អក្សរសិល្ប៍មានលក្ខណៈជាតិ គឺជាស្នាដៃដែលទ្រទ្រង់ព្រលឹងជាតិឱ្យស្ថិតស្ថេរជាអមតៈ**»។ តើការលើកឡើងនេះមានន័យដូចម្ដេច? ចូរពន្យល់។ (ទំ.៨)
4. មតិមួយពោលថា«**លក្ខណៈជាតិនៃអក្សរសិល្ប៍ គឺជាលក្ខណៈពិសេសរបស់ជាតិមួយ លេចធ្លោខុសពីជាតិដទៃដែលស្ដែងចេញតាមរយៈអក្សរសិល្ប៍**»។ ចូរអធិប្បាយបំភ្លឺ។ (ទំ.១០)
5. មតិមួយពោលថា«**អក្សរសិល្ប៍ខេមរនិយម គឺជាការនិយមយកហេតុការណ៍ ដែលគេធ្លាប់ឃើញពិតក្នុងសង្គមជាតិខ្មែរមកឆ្លុះបញ្ចាំងតាមរយៈស្នាដៃអក្សរសិល្ប៍**»។ ចូរពន្យល់។ (ទំ.១០)
6. គេថា«**គោលបំណងសំខាន់បំផុតនៃអក្សរសិល្ប៍បែបខេមរនិយម បង្ហាញបញ្ហាជីវភាពជាក់ស្ដែងរបស់មនុស្សក្នុងសង្គមស្របទៅតាមវប្បធម៌អរិយធម៌ខ្មែរយើង**»។ ចូរពន្យល់។ (ទំ.១១)
7. មតិមួយពោលថា«**ការដោះស្រាយបញ្ហានៅក្នុងអក្សរសិល្ប៍បែបខេមរនិយម គឺតួអង្គពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ដើម្បីផ្ចាញ់ឧបសគ្គក្នុងសង្គម ឬធម្មជាតិ**»។ ចូរពន្យល់។ (ទំ.១១)
8. មតិមួយពោលថា«**ខ្លឹមសារអក្សរសិល្ប៍ខេមរនិយម គឺជាបញ្ហាចោទចំពោះមនុស្សលោកិយបច្ចុប្បន្ន ហើយយកការអប់រំឱ្យបុគ្គលខ្លួនឯងខិតខំត្រិះរិះដោះស្រាយបញ្ហាក្នុងសង្គមមនុស្ស**»។ ចូរពន្យល់។ (ទំ.១១)
9. មតិមួយពោលថា«**តម្លៃនៃអក្សរសិល្ប៍ខេមរនិយម ស្ដែងចេញពីការឆ្លុះបញ្ចាំងនូវតថភាពជាក់ស្ដែង ការអប់រំសីលធម៌ និងស្មារតីជាតិនិយមពិតៗ តាមរយៈភាពប៉ិនប្រសប់របស់អ្នកនិពន្ធ**»។ ចូរពន្យល់។ (ទំ.១១)
10. សុភាសិតខ្មែរចែងថា«**កុំខ្ញើកតាមខ្យល់ កុំខ្វល់តាមរលក**»។ ចូរពន្យល់។ (ទំ.២៤)
11. សុភាសិតខ្មែរចែងថា«**តក់ៗពេញបំពង់ ធុងៗកំពប់អស់**»។ ចូរពន្យល់ (ទំ.២៤)
12. ពាក្យរៀលខ្មែរពោលថា«**ចេះមិនឈ្នះចង់ ត្រង់មិនឈ្នះទាល់ កលមិនឈ្នះគិត រិទ្ធិមិនឈ្នះពោគ**»។ (ទំ.២៤)
13. មតិខ្លះថា«**ខ្មែរជាឥណ្ឌាទី២**»។ តើជាការពិតដែរឬទេ? ចូរវែកញែក។ (ទំ.២៥)
14. មតិទី១៖«**ចង់ក្លាយជាអរិយប្រទេសត្រូវអភិរក្សវប្បធម៌**»។ មតិទី២៖ «**ចង់ក្លាយជាអរិយប្រទេសពិតប្រាកដត្រូវអភិវឌ្ឍវប្បធម៌ជាតិ**»។ ចូរពិភាក្សា។ (ទំ.៣០)

<u>មេរៀនទី២៖ អក្សរសិល្ប៍ព្រាហ្មណ៍និយម</u>

15. គេថា«**អក្សរសិល្ប៍ព្រាហ្មណ៍និយម គឺទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍**»។ ចូរបំភ្លឺ។ (ទំ.៣៥)
16. មតិមួយពោលថា«**រឿងក្នុងគោលព្រាហ្មណ៍និយម ជារឿងមានលក្ខណៈអច្ឆរិយៈហួសពីសមត្ថភាពសមត្ថភាពមនុស្ស**»។ ចូរពន្យល់។ (ទំ.៣៥)
17. មានមតិមួយថា«**គោលគំនិតចម្បង ឬមូលបញ្ហារឿងបែបព្រាហ្មណ៍និយម គឺបង្ហាញពីមហិទ្ធិឫទ្ធិអំណាចរបស់តួអង្គដ៏ខ្លាំងពូកែ ដែលតំណាងអាទិទេព**»។ ចូរបំភ្លឺ។ (ទំ.៣៥)
18. ការសិក្សាពីលក្ខណៈអក្សរសិល្ប៍នាំឱ្យគេឃើញថា«**លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ គឺលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយ ទៅតាមសកម្មភាពធម្មតារបស់មនុស្ស**»។ ចូរពន្យល់។ (ទំ.៥៨)
19. គេថា «**លក្ខណៈសង្គមរបស់អក្សរសិល្ប៍ ស្ថិតនៅលើការលើកយកបញ្ហាមនុស្សក្នុងសង្គមណាមួយមកចោទ និងដោះស្រាយ**»។ ចូរពន្យល់។ (ទំ.៥៨)

20. ទស្សនៈមួយពោលថា«**អក្សរសិល្ប៍ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនូវតថភាពសង្គម**»។ ចូរពន្យល់។ (ទំ.៥៨)
21. ពេលសិក្សាពីលក្ខណៈវណ្ណៈក្នុងអក្សរសិល្ប៍នាំឱ្យមានការលើកឡើងមួយថា«**អក្សរសិល្ប៍ គឺជាការឆ្លុះបញ្ចាំងនូវរូបភាពមនសិការសង្គម**»។ តើមានន័យយ៉ាងណា? ចូរបំភ្លឺ។ (ទំ.៥៨)
22. គេថា«**លក្ខណៈវណ្ណៈនៃអក្សរសិល្ប៍ស្តែងឡើងតាមរយៈវិធីនិម្មិតកម្មរបស់អ្នកនិពន្ធ**»។ ចូរពន្យល់។ (ទំ.៥៩)
23. មតិមួយពោលថា«**ស្នាដៃអក្សរសិល្ប៍ ដែលមានលក្ខណៈប្រជាជន ជាស្នាដៃយកចិត្តទុកដាក់លើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន**»។ ចូរពន្យល់។ (ទំ.៥៩)
24. គេថា«**លក្ខណៈបក្សក្នុងអក្សរសិល្ប៍គឺផ្តើមចេញពីលក្ខណៈវណ្ណៈ នាំឱ្យមនុស្សមានការបែងចែកជាពួកៗ ទៅតាមទស្សនៈ គោលការណ៍ លទ្ធិ មនោគមវិជ្ជា ឬនិន្នាការណាមួយ**»។ ចូរពន្យល់។ (ទំ.៦០)
25. ស្នាដៃអក្សរសិល្ប៍ក្នុងលក្ខណៈតែងទាក់ទងទៅនឹងសម័យកាល ឬព្រឹត្តិការណ៍ខ្លះៗ ដែលកើតមានឡើងក្នុងប្រវត្តិសាស្ត្រ។ ទំ.៦០
26. លក្ខណៈជាតិក្នុងអក្សរសិល្ប៍ឆ្លុះបញ្ចាំងតាមរយៈការលើកយកប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ភាសា វប្បធម៌ ទិដ្ឋភាពធម្មជាតិ សោកនាដកម្មរបស់ប្រទេសជាតិមកធ្វើជាកម្មវត្ថុ។ (ទំ.៦១)
27. មតិមួយបានពោលថា«**លក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍ ជាស្នាដៃបម្រើនូវឧត្តមគតិ ផលប្រយោជន៍មនុស្សជាតិទូទៅ**»។ ចូរពន្យល់ ដោយលើកឧទាហរណ៍ក្នុង**រឿងទុំទាវ**មកបញ្ជាក់ឱ្យបានក្បោះក្បាយ។ (ទំ.៦២)

**<u>មេរៀនទី៣៖ អក្សរសិល្ប៍ពុទ្ធនិយម</u>**

28. គេថា«**អក្សរសិល្ប៍ពុទ្ធនិយម គឺជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា**»។ ចូរពន្យល់។ (ទំ.៦៥)
29. អ្នកអក្សរសិល្ប៍លើកឡើងថា«**គោលគំនិតធំ ឬមូលបញ្ហានៃរឿងពុទ្ធនិយម គឺការសាងបារមីរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ជាព្រះពុទ្ធ**»។ ចូរពន្យល់។(ទំ.៦៥)
30. មតិមួយពោលថា«**ដំណោះស្រាយបញ្ហាក្នុងរឿងពុទ្ធនិយម គឺអហិង្សា ឬសន្តិភាព**»។ ចូរពន្យល់។ (ទំ.៦៥)
31. ទស្សនៈមួយពោលថា«**ព្រះពុទ្ធសាសនា គឺជាសាសនាមនុស្សនិយម**»។ ចូរពន្យល់។ (ទំ.៦៦)
32. មតិមួយពោលថា«**អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គម**»។ ចូរបកស្រាយ។ (ទំ.៧០)
33. គេថា«**ស្នាដៃអក្សរសិល្ប៍ អាចឆ្លុះឱ្យឃើញការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗ**»។ តើឆ្លុះបញ្ចាំងយ៉ាងដូចម្តេចខ្លះ? ចូរបំភ្លឺដោយលើកអំណះអំណាងបញ្ជាក់។ (ទំ.៧០)
34. គេថា«**អក្សរសិល្ប៍ គឺជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់ផ្សាយវប្បធម៌ជាតិ**»។ ចូរពន្យល់។ (ទំ.៧៦)
35. រឿងព្រះវេស្សន្តរគឺជាជាតិដែលបំពេញទានបារមី។ ចូរអ្នកបំភ្លឺឱ្យបានច្បាស់លាស់ពី«**ទានដែលព្រះវេស្សន្តរបានបំពេញតាមរយៈសាច់រឿង**» ដោយលើកខ្លឹមសាររឿងនេះមកបញ្ជាក់ឱ្យបានក្បោះក្បាយ។ (ទំ.៨៥)
36. ពុទ្ធភាសិតចែងថា«**អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ**»។ ចូរពន្យល់។ (ទំ.៨៧)
37. ព្រះពុទ្ធសម្តែងថា ដើម្បីបានសេចក្តីសុខ គឺត្រូវលះបង់តណ្ហា កម្ចាត់អវិជ្ជា មិនប្រមាថធ្វេសប្រហែស តម្កល់ចិត្តជាកណ្តាលតាមផ្លូវ«**អដ្ឋង្គិកមគ្គ**»(សីល សមាធិ បញ្ញា)។ តើអដ្ឋង្គិកមគ្គមានន័យយ៉ាងណា? (ទំ.៨៧)

**<u>មេរៀនទី៤៖ សិល្បៈ</u>**

38. ទស្សនៈមួយពោលថា«**សិល្បៈជាអត្តសញ្ញាណជាតិ**»។ ចូរពន្យល់។ (ទំ.៩១)
39. ចូរអ្នកបង្ហាញនិងបកស្រាយអំពី«**សុន្ទររស និងវិហាសរូបរស**»ក្នុងស្នាដៃអក្សរសិល្ប៍ដែលអ្នកបានសិក្សារួចមកហើយឱ្យបានបីរឿងយ៉ាងតិច។ (ទំ.៩២-៩៣)
40. ចូរអ្នកបង្ហាញនិងបកស្រាយអំពី«**វិសិដ្ឋរស និងវីររស**»ក្នុងស្នាដៃអក្សរសិល្ប៍ដែលអ្នកបានសិក្សារួចមកហើយឱ្យបានបីរឿងយ៉ាងតិច។ (ទំ.៩៣)

41. ចូរអ្នកបង្ហាញនិងបកស្រាយអំពី«**ទារុណរស និងនាដ្យរស**» ក្នុងស្នាដៃអក្សរសិល្ប៍ដែលអ្នកបានសិក្សារួចមក ហើយឱ្យបានបីរឿងយ៉ាងតិច។ (ទំ.៩៣)
42. អ្នកសិក្សាអក្សរសិល្ប៍លើកឡើងថា«**សព្វរស ជាតម្លៃទូទៅនៃរឿងដែលកវីនិពន្ធតែងតែយកមកប្រើក្នុងអត្ថបទឬស្នាដៃ**»។ ចូរអ្នកធ្វើការពន្យល់ឱ្យបានក្បោះក្បាយ។ (ទំ.៩៤)
43. គេថា«**បញ្ហាចោទក្នុងរឿងបែបព្រាហ្មណ៍និយមគឺទំនាស់រវាងសភាវៈល្អ និងសភាវៈអាក្រក់**»។ (ទំ.៩៥)
44. ចូរអ្នកធ្វើការអធិប្បាយពី«**ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម**» ដោយលើកឧទាហរណ៍មកបញ្ជាក់។
45. បញ្ហាចោទក្នុងរឿងបែបពុទ្ធនិយមគឺ «**ទំនាស់រវាងព្រះពោធិសត្វ និងសង្គមមនុស្ស**»។ ចូរបង្ហាញបញ្ហាចោទតាមរយៈរឿងតេមិយ រឿងសុវណ្ណសាម និងរឿងព្រះវេស្សន្តរ។ (ទំ.៩៦)
46. ចូរអ្នកធ្វើការអធិប្បាយពី«**ចលនាអក្សរសិល្ប៍ពុទ្ធនិយម**» ដោយលើកឧទាហរណ៍មកបញ្ជាក់។
47. ទស្សនៈមួយថា«**អក្សរសិល្ប៍ពុទ្ធនិយមក្លាយពុំមានតម្លៃសម្រាប់សិក្សាឡើយ**»។ចូរពិភាក្សា។(ទំ.៩៧)
48. ចូរអ្នកធ្វើការអធិប្បាយពី«**ចលនាអក្សរសិល្ប៍ខេមរនិយម**» ដោយលើកឧទាហរណ៍មកបញ្ជាក់។
49. អក្សរសិល្ប៍បែបខេមរនិយមស្តែងចេញពី«**ការឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង ការអប់រំសីលធម៌ និងស្មារតីជាតិនិយមពិតៗ**»។ ចូរអធិប្បាយពន្យល់។(ទំ.៩៩)
50. អក្សរសិល្ប៍បែបខេមរនិយមគឺជា«**រឿងបែបមនុស្សលោកិយ ជារឿងរបស់ជាតិខ្មែរ ដែលយកសង្គមារម្មណ៍ មកចោទ និងដោះស្រាយ ទៅតាមប្រយោជន៍នៃសង្គមជាតិ**»។ ចូរពន្យល់។ (ទំ.៩៩)
51. សមលើកដៃសំពះលោករដ្ឋមន្ត្រីដោយសេចក្តីគោរព ហើយនិយាយតិចៗថា«**ព្រះតេជគុណមេត្តាខ្ញុំបាទ សុំព្រះតេជគុណកុំឱ្យប្រាក់ខ្ញុំបាទធ្វើអីទានប្រោស សុំព្រះតេជគុណជួយរកការងារឱ្យខ្ញុំបាទធ្វើវិញទៅល្អជាជាង**»។ តើសម្តីដែលសមដែលលើកឡើងបង្កប់ខ្លឹមសារដូចម្តេច? ចូរពន្យល់។ (ទំ.១០៤)
52. សមពោលថា«**ការងារខ្ញុំបាទធ្វើបានទាំងអស់ សុំឱ្យតែការងារនោះជាការងារសុចរិត**»។ ចូរពន្យល់សម្តីសមនេះដោយលើកខ្លឹមសាររឿងមកជាអំណះអំណាង។ (ទំ.១០៥)
53. លោករដ្ឋមន្ត្រីពោលថា«**មនុស្សយើងត្រូវពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក**»។ ចូរពន្យល់។ (ទំ.១០៥)
54. សមពោលថា«**មនុស្សយើងត្រូវមានសិទ្ធិសេរីភាពស្មើគ្នា តែសិទ្ធិសេរីភាពនោះត្រូវតែមានព្រំដែន**»។ ចូរពន្យល់ឱ្យបានក្បោះក្បាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។(ទំ.១០៥)
55. សម័យសង្គមរាស្ត្រនិយម គឺជាសម័យកាលដែលរាជរដ្ឋាភិបាលបានជួយជ្រោមជ្រែងកសិករក្នុងការធ្វើស្រែចម្ការ ហើយលើកតម្កើងកសិករឱ្យក្លាយជាពលរដ្ឋមានតម្លៃ។ ចូរលើកយក«**គុណតម្លៃនៃរបបសង្គមរាស្ត្រនិយម**» និងលើកយកស្នាដៃរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់មកបង្ហាញ។ (ទំ.១០៨)
56. ចូរបង្ហាញឱ្យឃើញថា«**រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់**»ស្ថិតក្នុងចលនាអក្សរសិល្ប៍ខេមរនិយម។(ទំ.១០៩)
57. ចូរស្រាយបំភ្លឺឃ្លាថា«**ព្រះអាទិត្យថ្មីបានរះលើផែនដីចាស់ ហើយរះនៅលើផែនដីនៃអាណានិគមបារាំង**» ដោយរកអំណះអំណាងក្នុងរឿងនេះមកបញ្ជាក់។(ទំ.១០៥)
58. ទស្សនៈមួយពោលថា«**ភ្លេង ជាសិល្បៈមួយប្រភេទសម្រាប់ប្រគុំក្នុងពិធីបុណ្យទាន និងពិធីទំនៀមផ្សេងៗ**»។ ចូរអ្នកពន្យល់ដោយលើកយកប្រភេទភ្លេងមកអធិប្បាយបំភ្លឺ។ (ទំ.១១១)
59. ទស្សនៈមួយចែងថា«**សិល្បៈរបាំបង្កប់នូវអត្តសញ្ញាណជាតិ**»។ (ទំ.១១៨)
60. មតិមួយពោលថា«**ការនិពន្ធស្នាដៃអក្សរសិល្ប៍ ជាការធ្វើទូទៅកម្មទៅលើតថភាព(វត្ថុវិស័យភាព និងប្រធាន វិស័យភាព) ដោយបញ្ចូលធាតុសិល្បៈ**»។ ចូរអធិប្បាយពន្យល់។ (ទំ.១១៩)
61. នៅក្នុងទស្សនវិជ្ជាពោលថា«**បើយើងមិនទៅមុខមិនមែនមានន័យថា យើងនៅមួយកន្លែងទេ ប៉ុន្តែយើងដើរថយក្រោយ**»។ តើទស្សនៈនេះមានអត្ថន័យដូចម្តេច? ចូរពន្យល់។ (ទំ.១២០)

62. ចូរបង្ហាញនិងបកស្រាយពី«**វឌ្ឍមានវិធី និងឧបកថាវិធី**» ក្នុងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍ ដោយរកអំណះអំណាងមកបញ្ជាក់។ (ទំ.១២៣)
63. ទារុណវិធី គឺជាវិធីដែលអ្នកនិពន្ធធ្វើឱ្យដំណើររឿងមានភាពកម្សត់ព្រាត់ប្រាស និងធ្វើទុក្ខទោសតួអង្គ។ ចូរពន្យល់ដោយលើកយក**ការបញ្ចប់រឿងក្នុងចលនាអក្សរសិល្ប៍បែបពុទ្ធនិយម ព្រាហ្មណ៍និយម និងខេមរនិយម** តាមរយៈស្នាដៃដែលអ្នកបានសិក្សារួច មកបង្ហាញ។ (ទំ.១២៤)

**<u>មេរៀនទី៥៖ ល្ខោន</u>**

64. ល្ខោនគឺជាសិល្បៈមួយប្រភេទ ដែលបញ្ជាក់ពីអត្តសញ្ញាណជាតិ។ (ទំ.១២៧)
65. ចូរអ្នកបកស្រាយពី«**វិធីបង្ហាញតួអង្គក្នុងរឿងល្ខោន**» ដោយលើកឧទាហរណ៍ក្នុងរឿងល្ខោននិយាយ និងល្ខោនបាសាក់ដែលមានក្នុងកម្មវិធីសិក្សា។ (ទំ.១៣០)
66. មតិមួយពោលថា«**ស្ថានភាពជាកត្តាកំណត់វីរជន**»។ ចូរពន្យល់ដោយលើកឧទាហរណ៍។(ទំ.១៤០)
67. ពូហ៊ុំក្នុងរឿងថៅកែចិត្តចោរបានពោលទៅកាន់ផានិតថា នៅក្មេងណាស់ «**គ្មានទាន់បានដឹងរឿងកន្លុកកន្លៀតជីវិតបន្តិចសោះ**»។ តើសម្ដីនេះមានខ្លឹមសារដូចម្ដេច? ចូរពន្យល់។(ទំ.១៤៨)
68. ថៅកែក្នុងរឿងថៅកែចិត្តចោរពោលថា«**កើតជាមនុស្សក្នុងសង្គមវាតែងមានឋានៈខ្ពស់ទាបជាធម្មតា តាមចង្វាក់តាក់តែងមក**»។ តើពំនោលនេះជាការពិតដែរឬទេ? ចូរពិភាក្សា។ (ទំ.១៤៩)
69. ផានីតពោលថា ខ្ញុំចោទថៅកែឯងពេញទីថា«**ជាចោរជាន់ខ្ពស់**»។ តើពំនោលនេះមានខ្លឹមសារដូចម្ដេច? ចូរអ្នកធ្វើការអធិប្បាយស្រាយបំភ្លឺ ដោយលើករឿងនេះមកបញ្ជាក់។ (ទំ.១៤៩)
70. ពូហ៊ុំពោលថា«**សេចក្ដីយុត្តិធម៌ទៀងត្រង់ បើយើងយកមកដាក់ក្នុងខ្លួនហើយមិនចេះសាបសូន្យទេ**»។ តើពំនោលនេះមានអត្ថន័យដូចម្ដេចខ្លះ? ចូរពន្យល់។(ទំ.១៥០)
71. ថៅកពោលថា«**មានតែលុយទេ ដែលអាចធ្វើជាអាជ្ញាកណ្ដាលកាត់សេចក្ដីជជែកនៅលើសេចក្ដីយុត្តិធម៌ ឬអយុត្តិធម៌**»។ តើការលើកឡើងនេះជាការពិតដែរឬទេ? ចូរវែកញែក។(ទំ.១៥០)
72. ផានិតពោលថា «**កុំធ្វើជាមនុស្សសម្បក**»។ តើមានន័យដូចម្ដេច? ចូរពន្យល់។ (ទំ.១៥០)
73. ហ៊ុំពោលថា«**អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះ ដើម្បីសេចក្ដីពិតផ្ទុះឡើង**»។ ចូរពន្យល់។ (ទំ.១៥១)
74. អំពើរបស់ថៅកែ និងពូហ៊ុំ គឺខុសទៅនឹង«**ផ្លូវច្បាប់ ផ្លូវសីលធម៌ និងផ្លូវសាសនា**»។ ចូរពន្យល់។(ទំ.១៥៤)
75. ចូរបង្ហាញ«**សច្ចរស សង្គមរស តថរស**» តាមរយៈរឿងថៅកែចិត្តចោរ ដោយលើកអំណះអំណាងពីក្នុងស្នាដៃលើកពៅយូឡេង និងអ៊ុំ ឈឺន នេះមកបញ្ជាក់។ (ទំ.១៥៤)

**<u>មេរៀនទី៦៖ សិលាចារឹក និងរបាំ</u>**

76. មតិមួយពោលថា«**សិលាចារឹកបង្កប់នូវវប្បធម៌អរិយធម៌សម្បូរបែប**»។ ចូរពន្យល់។(ទំ.១៦១)
77. មតិមួយលើកឡើងថា«**របាំបុរាណខ្មែរ គឺជាសិល្បៈគំនិតដែលប្រើនិមិត្តរូបនិយម**»។ ចូរពន្យល់។(ទំ.១៦៣)
78. **ពិធីចូលម្លប់ឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិខ្មែរ**។ ចូរពន្យល់។ (ទំ.១៧០)

**<u>មេរៀនទី៧៖ ប្រពៃណីទំនៀមទម្លាប់</u>**

79. ចូរបង្ហាញឱ្យឃើញថា«**រឿងគូលីកំនែនជាអក្សរសិល្ប៍ទំនើបបែបតថនិយមជឿនលឿន**»។ (ទំ.១៨២)
80. តាមរយៈការសិក្សារឿងគូលីកំនែន «**អ្នកនិពន្ធបានបង្ហាញឱ្យឃើញពីផ្លូវអាណាចក្រ និងពុទ្ធចក្រ**»។ ចូរអ្នកបកស្រាយឱ្យបានក្បោះក្បាយ។ (ទំ.១៨២)
81. ចូរបង្ហាញពី«**លក្ខណៈជាតិ លក្ខណៈមនុស្ស និងលក្ខណៈសង្គម**»តាមរយៈរឿងគូលីកំនែន។ (ទំ.១៨២)
82. ចូរអ្នកសិក្សាពី«**សង្គមបរិយាកាស និងគំនិតអ្នកនិពន្ធរឿងគូលីកំនែន**» ក្នុងការលើកយកតថភាពនាសម័យអាណានិគមមកឆ្លុះបញ្ចាំង។ (ទំ.១៨២)

83. នៅពេលដង្ហែសពទៅបូជា ឬបញ្ចុះ គេតែងឃើញមានពាក្យនៅបដាកំណាត់ពណ៌ខ្មៅសរសេរថា«**រូបំ អនិច្ចំ ទុក្ខំ អនត្តា**»។ តើពាក្យទាំងនេះមានអត្ថន័យយ៉ាងណាចូរស្រាយបំភ្លឺ។
84. ចូរបង្ហាញពី«**លក្ខណៈជាតិតាមរយៈប្រពៃណីនៅពេលស្លាប់**» ដោយលើកយកអំណះអំណាងក្នុងសង្គម ប្រវត្តិ និងអក្សរសិល្ប៍**រឿងរាមកេរ្តិ៍ រឿងសូផាត និងរឿងផ្កាស្រពោន**មកបញ្ជាក់។(ទំ.១៩១)
85. ពិធីចម្រើនអាយុឆ្លុះបញ្ចាំងអត្តសញ្ញាណជាតិខ្មែរ។ (ទំ.១៩២)
86. ចូរអ្នកបង្ហាញពី«**ប្រពៃណីទំនៀមទម្លាប់ខ្មែរតាមរយៈរឿងទុំទាវ**»។ (ទំ.១៩៤)
87. អ្នកបានសិក្សាពីវប្បធម៌ខ្មែរបានពោលថា«**កំណាព្យជាកេរដំណែលវប្បធម៌ប្រកបដោយអត្ថន័យបង្កប់លក្ខណៈជាតិពិតៗ**»។ ចូរពន្យល់។(ទំ.១៩៩)
88. គេថា«**ការសន្តោសប្រណីជាគុណធម៌ដ៏ប្រសើរ**»។ ចូរពន្យល់។ (ទំ.២០៨)
89. ក្នុងវប្បធម៌ប្រពៃណីជាតិខ្មែរ គេថា«**អាពាហ៍ពិពាហ៍ បង្កប់នូវគុណតម្លៃនៃការបង្កើតគ្រួសារ និងរក្សាបានអត្តសញ្ញាណជាតិ**»។ ចូរពន្យល់។(ទំ.២១២)

**<u>មេរៀនទី៩៖ ទំនាក់ទំនងរវាងអក្សរសិល្ប៍ខ្មែរ និងបរទេស</u>**

90. ចូរបង្ហាញពី«**ទំនាក់ទំនងនិងឥទ្ធិពលលើគ្នាទៅវិញទៅមកនៃរឿងរាមកេរ្តិ៍ និងរឿងរាមាយណៈ**»។(ទំ.២៣១)
91. គេពោលថា«**រឿងហង្សយន្តបង្កប់នូវតម្លៃវប្បធម៌ខ្មែរ**»។ ចូរពន្យល់។ (ទំ.២៣២)
92. សុភាសិតខ្មែរចែងថា«**ចេះពីរៀន មានពីរក**»។ ចូរលើកយកអក្សរសិល្ប៍ប្រជាប្រិយមកបញ្ជាក់។ (ទំ.២៣៩)
93. សុភាសិតខ្មែរចែងថា«**ឈើកោងវល្លិព័ទ្ធ មនុស្សខ្ជាត់ព្រាត់កុំយកខ្លួនបៀត**»។ ចូរពន្យល់។ (ទំ.២៣៩)
94. សុភាសិតខ្មែរចែងថា«**អ្នកមានរក្សាខ្សត់ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅពឹងសំប៉ាន**»។ តើសុភាសិតនេះបង្កប់ខ្លឹមសារបែបណាខ្លះ? ចូរពន្យល់។ (ទំ.២៣៩)
95. ពាក្យចាស់ពោលថា«**ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូឱ្យយក**»។ តើមានន័យដូចម្ដេច? ចូរពន្យល់។ (ទំ.២៣៩)
96. សុភាសិតខ្មែរចែងថា«**អួសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក**»។ ចូរពន្យល់។ (ទំ.២៣៩)
97. សុភាសិតខ្មែរចែងថា«**ដើយស្អក ឱនដាក់គ្រាប់**»។ ចូរពន្យល់។ (ទំ.២៣៩)
98. សុភាសិតខ្មែរចែងថា«**សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា**»។ ចូរពន្យល់។ (ទំ.២៣៩)
99. សុភាសិតខ្មែរចែងថា«**ចង់ធ្លាញ់រកអន្លក់ ចង់ស្រណុកឱ្យនឿយពីក្មេង**»។ ចូរពន្យល់។ (ទំ.២៣៩)
100. សុភាសិតខ្មែរចែងថា«**ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ**»។ ចូរពន្យល់។ (ទំ.២៣៩)
101. សុភាសិតខ្មែរចែងថា«**ស្រឡាញ់កុំទៅញឹក រលឹកសឹមទៅម្ដង**»។ ចូរពន្យល់។ (ទំ.២៣៩)
102. ចូរបង្ហាញលក្ខណៈខុសគ្នារវាង**តួអង្គរាមា**ក្នុងរឿងរាមាយណៈ និង**ព្រះរាម**ក្នុងរឿងរាមកេរ្តិ៍។ (ទំ.២៤៥)
103. ការសិក្សាអក្សរសិល្ប៍ជាតិធ្វើឱ្យយើងស្វែងយល់ពី«**តថភាពសង្គមរបស់ខ្លួន ដែលមានតាំងពីអតីតកាលមកដល់បច្ចុប្បន្ន**»។ តើអក្សរសិល្ប៍បង្ហាញតថភាពសង្គមដូចម្ដេចខ្លះ? ចូរពន្យល់។ (ទំ.២៤៥)

**<u>មេរៀនទី១០៖ អក្សរសិល្ប៍បរទេស</u>**

104. មតិខ្លះថា«**ការសិក្សាស្នាដៃអក្សរសិល្ប៍អន្តរជាតិ ឬអក្សរសិល្ប៍បរទេស អាចឱ្យយើងបានដឹងពីសង្គមខាងក្រៅជាពិសេសបណ្ដាប្រទេសដែលមានវប្បធម៌ចំណាស់**» តែមតិខ្លះទៀតថា«**អក្សរសិល្ប៍បរទេសពុំមានតម្លៃសម្រាប់សិក្សាឡើយ**»។ តើមតិទាំងពីរមួយណាសមហេតុផលជាង? ចូរពិភាក្សា។(ទំ.២៤៥)
105. គេថា«**មរណភាពរបស់ហាំលែតឆ្លុះពីឧត្តមគតិ**»។ តើឆ្លុះបញ្ចាំងដូចម្ដេចខ្លះ? ចូរពន្យល់។ (ទំ.២៥៥)
106. មតិខ្លះថា«**ការហូរចូលនៃវប្បធម៌បរទេសអាចបំបាត់ព្រលឹងជាតិខ្មែរ**»។ តើជាការពិតដែរឬទេ? (ទំ.២៦៤)
107. គេពោលថា«**អរិយធម៌ខ្មែរមានទំនាក់ទំនងជាមួយអរិយធម៌បរទេស**»។ ចូរពន្យល់។ (ទំ.២៦៦)

## ៥.៣.៥. គុណតម្លៃគ្រូបង្រៀនក្នុងការផ្លាស់ប្ដូរវិធីសាស្ត្របង្រៀនស្របតាមស្ថានភាព

**"ចំណេះដឹងមានអត្ថប្រយោជន៍ លុះត្រាតែគ្រូបង្រៀនចេះប្រើប្រាស់ចំណេះដឹងនេះ ដើម្បីបង្កើនគុណភាពបង្រៀន បង្កើតបរិយាកាសអំណោយផលសម្រាប់ការសិក្សា ប្រើវិធីសាស្ត្របង្រៀនសមស្របដើម្បីកែលម្អលទ្ធផលសិក្សាសិស្សប្រសើរជាងមុន និងលើកកម្ពស់គុណភាពនៃប្រព័ន្ធអប់រំ ដើម្បីមនុស្សជាតិទាំងមូល"។**[7] ការញែកស្នាដៃអក្សរសិល្ប៍ ដែលមានក្នុងសៀវភៅសិក្សាគោល មកបង្កើតជាប្រធានសំណេរតែងសេចក្ដី មិនមែនន័យថា យើងបោះបង់មិនសិក្សាពីសៀវភៅគោលនោះឡើយ។ សៀវភៅគោលជាគ្រឹះដ៏សំខាន់ដើម្បីបំបែកខ្លឹមសារ មេរៀនឱ្យសមស្របតាមកាលៈទេសៈ។ ការចេះច្នៃប្រឌិតបង្កើតថ្មីជាមូលដ្ឋានកសាងសមត្ថភាពស្របតាមទ្រឹស្ដីប្លូម ដែលជាគោលដៅចង់បានក្នុងវិស័យអប់រំ។

ផ្ដើមពី(១)**ចងចាំ** (២)**យល់** (៣)**អនុវត្ត** (៤)**វិភាគ** (៥)**វាយតម្លៃ** និង(៦)**បង្កើតថ្មី**[8] គឺជាជំហាននៃការអភិវឌ្ឍសមត្ថភាពឱ្យទាន់យុគសម័យនៃការប្រកួតប្រជែង។ ពាក្យថាគ្រូបង្រៀន គឺរៀនគ្រប់ពេល ពង្រឹងសមត្ថភាពគ្រប់ពេល អភិវឌ្ឍគំនិតច្នៃប្រឌិតគ្រប់ពេល ទើបអាចមានលទ្ធភាពបង្កើតថ្មី ចងក្រង ស្នាដៃជួយសិស្សបាន។ គ្រូបង្រៀនមិនរៀនបន្ថែម ប្រៀបបានរុក្ខជាតិដែលឥតស្រោចទឹកដូច្នោះដែរ។ គ្មានអ្វីដែលបានមកស្រាប់ដូចពាក្យចាស់ពោលថា«ម្រឹគទាំងឡាយ មិនដែលបោលចូលមាត់សីហៈដែលដេកលក់នោះឡើយ»។ ត្រូវតែបន្តធ្វើខ្លួនជាមនុស្សដែលទឹកមិនពេញកែវ ត្រូវតែចាក់បន្ថែមជានិច្ច រៀនហើយរៀនទៀត រៀនពេញមួយជីវិត។ ការសាកល្បងម្ដងហើយម្ដងទៀត ជាដំណើរដ៏ប្រសើរក្នុងការស្វែងរកសច្ចភាពនៃគំនិត។

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ (២០១៩-២០២៣) រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យក «**មនុស្ស**» ជាអាទិភាពទីមួយ មុនផ្លូវ ភ្លើង ទឹក ដែលការអភិវឌ្ឍធនធានមនុស្ស ប្រាកដណាស់ចេញពីតួនាទីដ៏សំខាន់របស់លោកគ្រូ អ្នកគ្រូ។ គុណតម្លៃនៃវិជ្ជាជីវៈគ្រូបង្រៀនគឺ«**ការយល់ច្បាស់ពីចក្ខុវិស័យរបស់ សង្គមជាតិ ការសម្លឹងមើលឲ្យឆ្ងាយ និងយល់ច្បាស់ពីតួនាទីដ៏មានតម្លៃរបស់លោកគ្រូ អ្នកគ្រូម្នាក់ៗចំពោះការអភិវឌ្ឍជាតិ គឺជាកត្តាសំខាន់បំផុត**»[9]។

វិធីសាស្ត្រញែកតែងសេចក្ដីចេញពីសៀវភៅគោល យើងអាចប្រើប្រាស់វិធីបង្រៀបបែបរិះរក ដោយអនុញ្ញាតឱ្យសិស្សបង្កើតជាសំណួរ ដើរតួជាអ្នកស្វែងរកនូវប្រធានបទពីសៀវភៅសិក្សាគោលដោយខ្លួនគេផ្ទាល់។

## ៥.៣.៦. ការបង្កើតឯកសារបង្រៀនដើម្បីពង្រឹងពុទ្ធិ

ការរៀបរៀងសៀវភៅ ជាទុនសំខាន់ក្នុងការបង្រៀន មានភាពច្បាស់លាស់ និងជួយសិស្សបានទូលំទូលាយ។ ភាពច្បាស់លាស់លើអ្វីដែលយើងបង្រៀន ជះឥទ្ធិពលយ៉ាងសំខាន់លើសិស្សានុសិស្ស ដូចពាក្យមួយឃ្លាបានចែងថា «**សូវមិនបង្រៀន ប្រសើរជាងបង្រៀនខុស**»។



*សៀវភៅដែលបានរៀបរៀងសម្រាប់បោះពុម្ពផ្សាយ និងបម្រើសម្រាប់ការបង្រៀនផ្ទាល់។*

---

[7] ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា

[8] ទ្រឹស្ដីBloom ថ្មី ឆ្នាំ២០២១

[9] ឯកឧត្តម ហ៊ុន ម៉ានី ថ្លែងក្នុងពិធីសំណេះសំណាលជាមួយគណៈគ្រប់គ្រង សាស្ត្រាចារ្យ និងគរុសិស្សនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពត នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ។

### ៥.៣.៧. ការចងក្រងមេរៀនជាស្លាយដើម្បីបំពេញតម្រូវការការសិក្សាបែបឌីជីថល

ការបង្រៀន គឺច្នៃប្រឌិតទៅតាមកម្រិតសមត្ថភាពសិស្ស និងកាលៈទេសៈ ជៀសវាងការប្រកាន់នូវគំនិត បែបណាមួយ ឬវិធីណាមួយដាច់ណាត់នោះទេ។ សិល្បៈនៃការបង្រៀន ត្រូវតែមើលលើស្ថានភាពទឹកចិត្តសិស្ស ស្ថានភាពសង្គម និងស្ថានភាពវិទ្យាសាស្ត្រ។ ការរៀបចំជាបណ្តុំមេរៀនក្នុងការបង្រៀនតាមរយៈLCD ជាគុណតម្លៃមួយជួយដល់វិស័យអប់រំឌីជីថលឆាប់សម្រេចគោលដៅ។

























*(គ្រប់ស្លាយសម្រាប់សិក្សារឿងនីមួយៗ អាចផ្ញើជាឯកសារភ្ជាប់ជូនបាន )*

## ៥.៣.៨. ការសាកល្បងប្រើវិធីបង្រៀនបែបផែនទីគំនិតក្នុងមុខវិជ្ជាអក្សរសាស្ត្រខ្មែរ

១.*ការធ្វើផែនទីគំនិតបង្ហាញពីនគរ និងតួអង្គក្នុងរឿងព្រះវេស្សន្តរ (អាចជូនជាឯកសារភ្ជាប់)*




២. *ការធ្វើផែនទីគំនិតបង្ហាញពីនគរ និងតួអង្គក្នុងរឿងរាមកេរ្តិ៍ (អាចជូនជាឯកសារភ្ជាប់បាន)*


















## ៦. សេចក្ដីសន្និដ្ឋាន

ជារួមមក គុណតម្លៃមនុស្សក្នុងសង្គមឌីជីថល គេមិនអាចកាត់ផ្ដាច់បានពីសីលធម៌ ដែលជាតម្លៃមិនអាចកាត់ថ្លៃបានរបស់មនុស្សឡើយ។ វិទ្យាសាស្ត្រ បច្ចេកវិទ្យាកាន់តែរីកចម្រើនយ៉ាងណាក៏ដោយ បើវិទ្យាសាស្ត្រខ្វះនូវសីលធម៌ គឺពិតណាស់នឹងនាំមកនូវមហន្តរាយដល់មនុស្សជាតិជាប្រាកដ។ តម្លៃមនុស្សពិតប្រាកដគឺនៅលើការលះបង់នូវសេចក្ដីអាក្រក់ ធ្វើតែសេចក្ដីល្អ និងសម្អាតចិត្តឱ្យបានស្អាតជ្រះស្រឡះ ដូចព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សម្ដែងថ្លែងទុកថា មេរៀនរបស់ព្រះអង្គសង្ខេបដោយខ្លីមានអត្ថន័យបីយ៉ាង (១)សព្វបាបស្សអករណំ (២)កុសលស្សូបសម្បទា (៣)សចិត្តបរិយោទបនំ ដូច្នោះដែរ។

សង្គមឌីជីថល អភិវឌ្ឍជឿនលឿនទៅបាន ក៏ដោយសារគុណតម្លៃនៃសន្តិភាព ដែលជាមូលដ្ឋានចម្បងអនុញ្ញាតឱ្យអ្វីសព្វយ៉ាងអាចដំណើរការទៅដោយរលូនបាន។ បើគ្មានសន្តិភាព តម្លៃអ្វីផ្សេងទៀតក៏គ្មានដែរ។ ដូច្នេះសន្តិភាពពិតជាមានតម្លៃណាស់ក្នុងសង្គមណាក៏ដោយ ពិសេសសង្គមបច្ចុប្បន្ននេះ។ គុណតម្លៃមនុស្សក្នុងយុគឌីជីថលនេះ មិនអាចខ្វះបាននូវកិច្ចខិតខំប្រឹងប្រែងរួមគ្នារក្សានូវសន្តិភាព ដើម្បីដឹកនាំកម្ពុជាឆ្ពោះទៅប្រទេសអភិវឌ្ឍនាពេលខាងមុខ។ រួមគ្នារក្សាសន្តិភាព ទើបយើងមានឱកាសអភិវឌ្ឍបាន។

**សន្តិភាព គឺជាធាតុស្នូលដ៏សំខាន់ដែលអាចឱ្យកម្ពុជាធ្វើការអភិវឌ្ឍឆ្ពោះទៅរកអនាគត ដ៏ត្រចះត្រចង់មួយប្រកបដោយសុទិដ្ឋិនិយម។** ការអភិវឌ្ឍឆ្ពោះទៅរកការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ គឺអាស្រ័យកិច្ចប្រឹងប្រែង និងការចូលរួមយ៉ាងសស្រាក់ សស្រាំរបស់យើងទាំងអស់គ្នា ទាំងក្នុងការបង្កើនជីវភាពគ្រួសារ រក្សាសន្តិសុខសុវត្ថិភាព មូលដ្ឋាន កសាងធនធានមនុស្ស និងការអប់រំជាប្រចាំដល់អ្នកនៅជុំវិញខ្លួនឱ្យយល់ ពីគុណតម្លៃ នៃសន្តិភាព និងចូលរួម ជាប្រចាំ ក្នុងការថែរក្សាសន្តិភាពឱ្យបានជានិច្ចនិរន្តន៍។ នៅពេលប្រទេសជាតិមានសុខសន្តិភាពដូចជាសព្វថ្ងៃនេះ គឺកម្ពុជាមានឱកាស ធ្វើអ្វីៗបានទាំងអស់ ក្នុងនោះគឺលទ្ធភាពកសាងអភិវឌ្ឍន៍ប្រទេសជាតិលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឱ្យកាន់តែរីកចម្រើនបានយ៉ាងឆាប់រហ័ស។ មានសន្តិភាព ទើបមានការអភិវឌ្ឍ មានការអភិវឌ្ឍទើបមានសង្គមឌីជីថល ការរក្សាសន្តិភាពគឺជាគុណតម្លៃមនុស្សក្នុងសង្គមឌីជីថលនេះ។

ចំណែកគុណតម្លៃគ្រូបង្រៀនវិញ គឺបេះដូងគ្រូបង្រៀន ជាបេះដូងនៃមាតាបិតាទីពីរ។ តើធ្វើដូចម្ដេច ទើបសក្ដិសមនឹងប្រយោគនៃមាតាបិតាទី២នោះ? ពិតណាស់គ្រូបង្រៀន ត្រូវតែមានបេះដូងជាអ្នកផ្ដល់ឱ្យ ជាអ្នកពោរពេញដោយព្រហ្មវិហារធម៌ មេត្តា ករុណា មុទិតា និងឧបេក្ខា។ ការងារជាគ្រូបង្រៀនពិតជាហត់ណាស់ ព្រោះជាតួអង្គប្រឈមមុខផ្ទាល់ក្នុងការអនុវត្តផែនការរបស់ជាតិដើម្បីបណ្ដុះបណ្ដាលធនធានមនុស្ស។ **"គ្រូបង្រៀនគឺជាឪពុកម្ដាយទីពីររបស់សិស្ស ប្រយោគមួយនេះវាពិតជាមានន័យជ្រាលជ្រៅដោយសំដៅទៅដល់គ្រូបង្រៀនគឺជាមគ្គុទេសក៍ដ៏ចំណាន ជាអ្នកបំភ្លឺផ្លូវដែលស្មោះត្រង់ និងមានគុណធម៌ខ្ពស់"**[10]។ គ្រូបង្រៀនជាបុគ្គលសំខាន់បំផុតដែលដើរតួនាទីជាអ្នកលុបបំបាត់បញ្ហាអនក្ខរកម្ម និងលើកកម្ពស់គុណភាពអប់រំនៅក្នុងសង្គម។ គ្រូបង្រៀនជាអ្នកបង្ហាញផ្លូវ និងចែករំលែកចំណេះដឹងជាច្រើនដល់សិស្សានុសិស្ស ឬយុវជនជំនាន់ក្រោយឱ្យមានគុណភាពជីវិតកាន់ប្រសើរឡើង។ គ្រូបង្រៀនគឺជាឆ្អឹងខ្នងនៃគុណភាពអប់រំ និងជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្ស។ ការអប់រំប្រកបដោយគុណភាពត្រូវផ្ដើមពីគ្រូបង្រៀនល្អ។

បេះដូងគ្រូបង្រៀន ជាបេះដូងដែលលោតក្នុងចង្វាក់តែមួយជាមួយរដ្ឋាភិបាល និងផែនការដែលក្រសួងរៀបចំ ទើបអាចជួយជ្រោងសង្គមជាតិឱ្យអភិវឌ្ឍបាន ស្របតាមយុគសម័យឌីជីថល។ នេះហើយជា**គុណតម្លៃមនុស្សក្នុងសង្គមឌីជីថល**។

---

[10] ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា

## គ្រូបង្រៀនសតវត្សរ៍ទី២១
### (បទកាកគតិ)

១. សតវត្សរ៍ថ្មី ចរន្តលោកីយ៍ ធ្វើអ្វីរហ័ស
យុគគេទំនើប ជួបពើប[11]មិនខ្វះ ក្បួនវិទ្យាសាស្ត្រ
ប្តូរផ្លាស់បញ្ញា។

២. ប្រព័ន្ធអប់រំ កែប្រែសង្គម និយមសិក្សា
អ្នកចេះគឺជាប់ ទើបទ័ពខ្លាំងក្លា តួឯកផែនការ
ពិតថាជាគ្រូ។

៣. គ្រូបង្រៀនល្អ សិស្សរៀនបវរ ស្មោះសរគិតគូរ
ទ្រឹស្តីប្រសើរ មិនស្មើគំរូ វិចិត្រករគូរ
គំនូរជីវិត។

៤. គ្រូពេទ្យព្រលឹង ធនធានមាំរឹង ទីពឹងគំនិត
គ្រូឌីជីថល ហ្វូហ្គលជួយគិត ស្វ័យស្វែងពិនិត្យ
ចំណេះថ្មីចាស់។

៥. គ្រិស្តសតវត្សរ៍ ម្តៃមួយត្រូវស្ទាត់ ថ្វីមាត់ល្អល្អះ
ឧបករណ៍សិក្សា ត្រូវការមិនខ្វះ អ្វីត្រូវចាំច្បាស់
គឺជាស់ស្មាក្តី[12]។

៦. បច្ចេកវិទ្យា គ្រូត្រូវស្ទុះស្ទា ម្ចីម្នាឃ្មាតខ្មី
ប្រឹងរកប្រឹងរៀន របៀនថ្មីៗ លះមច្ឆរី[13]
សក្ខីចេះដឹង។

៧. គ្រូខ្លាំងសិស្សខ្លាំង ចេញប្រយុទ្ធច្បាំង កម្លាំងថ្លៃងថ្លឹង
វិន័យសីលធម៌ បវរតឹងរ៉ឹង ប្រៀបប្រុងប្រែងប្រឹង
សម្លឹងវិជ្ជា។

៨. គឺគុណភាពគ្រូ គុណភាពគំរូ តស៊ូពុះពារ
ពង្រឹងខ្លួនឯង ជាក់ស្តែងគ្រប់គ្រា ចាំគ្រប់វេលា
បោលសៀ[14]តណ្ហា។

៩. ចាំជាប់រងំ គ្រូស្នូលអប់រំ សង្គមថ្លៃថ្លា
អភិវឌ្ឍខ្លួន មាំមួនខ្លាំងក្លា ប្រឹងប្រែងជួយស្តារ
សង្ខារជាតិខ្មែរ។

១០. ជាតិរីកជាតិរស់ រុងរឿងកេរ្តិ៍ឈ្មោះ ក៏ព្រោះពលដែរ
ធនធានគំរូ គឺគ្រូពុកម៉ែ តាមទាន់ថ្ងៃខែ
យុគឌីជីថល។

---

[11] ពើប : ប្រទះ

[12] ស្មាក្តី : អ្នកកាន់ក្តីយុត្តិធម៌

[13] មច្ឆរី : ក្តីកំណាញ់ អ្នកកំណាញ់

[14] បោលសៀ : គឺលះបង់

# គ្រូបង្រៀនឌីជីថល

(បទពាក្យប្រាំពីរ)

១. ចរន្តសកលដល់យុគថ្មី    ក្មេងចាស់ប្រុសស្រីច្នៃវិវឌ្ឍ
យុគចាស់កន្លងឆ្លងសតវត្សរ៍    យុគថ្មីត្រូវស្ទាត់វិទ្យាសាស្ត្រ។
២. ប្រព័ន្ធអប់រំផ្ដុំសិក្សា    គិតគូររចនាឱ្យរហ័ស
ផ្លាស់ប្ដូរយកថ្មីច្នៃផ្ទត់ចាស់    ឯតួឯកច្បាស់គឺជាគ្រូ។
៣. គ្រូបង្រៀនល្អសិស្សប្រសើរ    ទ្រឹស្ដីមិនស្មើភាពគំរូ
គ្រូជាព្រលឹងអ្នកឆ្លាក់គូរ    គំនូសគំនូរឱ្យបែបណា។
៤. គ្រូជាគ្រូពេទ្យផ្នែកអប់រំ    កែប្រែសង្គមឱ្យថ្លៃថ្លា
បណ្ដុះធនធានឈានបញ្ញា    គ្រូជាអាចារ្យផ្ដល់គំនិត។
៥. គ្រូសម័យឌីជីថលថ្មី    គួរគិតគប្បីរៀនពិនិត្យ
ធ្វើស្វ័យសិក្សាមួយជីវិត    កុំតាយបើគិត[15]ថាគ្រប់គ្រាន់។
៦. ចំណេះបង្កើនតាមសម័យ    កុំនៅវិស័យចេះដាប់វណ្ឌ
ជីវិតជាគ្រូត្រូវរួសរាន់    ប្រឹងតាមឱ្យទាន់ទើបផ្ងាលា[16]។
៧. គ្រូសតវត្សរ៍ទីម្ភៃមួយ    ត្រូវតែលើកស្ទួយច្រើនវិជ្ជា
ពង្រឹងស្មារតីលះខ្ជីខ្ជា    ប្រាជ្ញាវាំងជា[17]បង្រៀនល្អ។
៨. គ្រូសម័យថ្មីលៃសំភី    តាក់សូណូមីក្បួនបវរ
ឱ្យសិស្សចេះចាំយល់ត្រេកអរ    ប្រតិបត្តិតវាយតម្លៃ។
៩. គ្រូត្រូវជួយសិស្សគិតបង្កើត    ដូចជាចន្ទខ្នើតជួយកែច្នៃ
ដើរទាន់ពិភពលោកសព្វថ្ងៃ    ធ្វើក្ដីស្រមៃឱ្យសម្រេច។
១០. គ្រូខ្លាំងសិស្សខ្លាំងច្បាំងមិនចាញ់    នាំក្ដីស្រឡាញ់មិនចេះដាច់
ខ្លាំងទាំងចំណេះ ចិត្តប្ដូរផ្ដាច់    គ្រូសិស្សចងបាច់សាមគ្គីភាព។
១១. គ្រូល្អមានបែបផែនស្គង់ដារ    មានកិច្ចតែងការតាមរបៀប
សិក្សាស្រាវជ្រាវគ្រប់រូបភាព    ចេះលៃស្ទង់ស្ទាបពីទឹកចិត្ត។
១២. យល់ស្ថានភាពសិស្សក្នុងថ្នាក់រៀន    ផ្ដល់ដំបូន្មានក្ដីអាណិត
រៀបក្បួនបង្រៀនមានកម្រិត    វិន័យក្រមក្រឹត្យត្រូវច្បាស់ការ។
១៣. ឯកទេសជំនាញប្រសប់ប៉ិន    វិជ្ជា បំណិន ចរិយា
បេះដូងសុចរិតក្ដាប់កិច្ចការ    ស្វែងយល់សារតាគ្រប់ជាតិសាសន៍។
១៤. សង្គមពុទ្ធិពឹងចំណេះ    សិស្សអាចរៀនចេះពឹងគ្រូច្បាស់
គ្រូចេះរៀនបែបវិទ្យាសាស្ត្រ    លេខអក្ខរសាស្ត្រស្វ័យសិក្ខា។

---

[15] តាយបើគិត : ស្លាប់គំនិត តាយគំនិត។

[16] ផ្ងាលា : សេចក្ដីរុងរឿង, ពន្លឺដែលភ្លឺព្រោងព្រាត។

[17] វាំងជា : ដែលរឹងមាំ រឹងប៉ឹង រហ័សរហួន។

១៥. គុណភាពគ្រូគុណភាពអប់រំ គុណភាពសង្គមពលថ្លៃថ្លា
ពលរដ្ឋសកលពេញបញ្ញា ពឹងសម្រេចការលើចិត្តគ្រូ។

១៦. ក្នុងនាមជាគ្រូត្រូវប្ដេជ្ញា មនសិការជាគំរូ
លះបង់ចិត្តកាយមិនរអ៊ូ ប្រឹងប្រែងតស៊ូដើម្បីជាតិ។

១៧. ចិត្តគ្រូចិត្តធ្ងន់ធន់កិច្ចការ ចាំជាប់ចិន្តាមិនរវាត
គិតសិស្សចេះដឹងកុំឱ្យឃ្លាត ខិតខំខ្មីឃ្មាតកុំបណ្ដោយ។

១៨. ជាតិរស់ជាតិរីកជាតិឧត្ដម ព្រោះមានគ្រឿងផ្សំជាល្បាយល្បោយ
ទោះបីសិស្សមានក្រក៏ដោយ គ្រូត្រូវផ្ដល់ឱ្យស្មើភាពគ្នា។

១៩. គ្រូជាកម្លាំងស្នូលអប់រំ គ្រូជាទ្រនំប្រាប់មាគ៌ា
ត្រួសត្រាយចំណេះចេះការងារ ឈ្មោះគ្រូជាងារអ្នកចេះដឹង។

២០. ដូច្នេះហើយគ្រូយុគទំនើប ត្រូវតែស្ទុះងើបស្វែងប្រែងប្រឹង
ពិនិត្យសង្កេតតាមសម្លឹង ពេលគ្រូរឹងប៉ឹងសិស្សជោគជ័យ។

# ឯកសារយោង


- ក្រសួងអប់រំ, ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ២០៣០, ខែឧសភា ២០២១
- ក្រសួងអប់រំ, កម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរ កម្រិតមធ្យមសិក្សាទុតិយភូមិ, ២០១៨
- ក្រសួងអប់រំ, គោលនយោបាយស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ, ២០១៦
- ខៀវ វិជ្ជានន្ទ និងបណ្ឌិតឃួន វិច្ឆិកា, សិក្សាបញ្ញត្តិដើម្បីអភិវឌ្ឍគុណសម្បទាសតវត្សរ៍ទី២១,២០២១
- គេហទំព័រ«ក្រុមប្រឹក្សាជាតិភាសាខ្មែរ» https://nckl.rac.gov.kh/
- គេហទំព័រ«ទីស្ដីការគណៈរដ្ឋមន្ត្រី» https://www.ocm.gov.kh/
- គេហទំព័រ«សារព័ត៌មានអេឡិចត្រូនិចថ្មីៗ» https://thmeythmey.com/
- គេហទំព័រ«រាជបណ្ឌិត្យសភាកម្ពុជា» https://rac.gov.kh/
- ឃិន វណ្ណី, ការគ្រប់គ្រងថ្នាក់រៀន, ២០២០
- ឃិន វណ្ណី, យុទ្ធសាស្ត្របង្រៀន, ២០២២
- ឌុច សុន, សីលធម៌, ២០០៥
- បណ្ឌិត ហង់ជួន ណារ៉ុន, បរិវត្តកម្មឌីជីថលនៃការអប់រំ, ២០២១
- បណ្ឌិត ហង់ជួន ណារ៉ុន, គុណភាពគ្រូជាគុណភាពមូលធនមនុស្សសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព, ២០១៨
- បណ្ឌិត ហង់ជួន ណារ៉ុន, សិក្សាសង្ខេបទស្សនវិជ្ជា, ២០១៨
- បណ្ឌិត ហង់ជួន ណារ៉ុន, វិភាគទាននៃការសិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ, ២០១៩
- បណ្ឌិត ហង់ជួន ណារ៉ុន, កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន, ២០២០
- បណ្ឌិត ហង់ជួន ណារ៉ុន, បាឋកថាទិវាគ្រូបង្រៀន បរិវត្តកម្មឌីជីថលនៃការអប់រំ ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី ផ្នែកទី២ ,២០២១
- ប៉ូ ប៊ុន្នួន ឡុចចាន់ថន ឃិន វណ្ណី, វិធីសាស្ត្របង្រៀន , ២០១៩
- រាជរដ្ឋាភិបាល, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥, ខែមករា ២០២២
- រាជរដ្ឋាភិបាល, គោលនយោបាយជាតិស្ដីពីការសិក្សាពេញមួយជីវិត, ២០១៩
- រាជរដ្ឋាភិបាល, គោលនយោបាយជាតិស្ដីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០២០-២០៣០, ២០១៩
- សុខ សត្ថាល, ទស្សនវិជ្ជា សំណួរចម្លើយអត្ថាធិប្បាយ ថ្នាក់បញ្ចប់
- សុខ សត្ថាល, មហាត្មៈគន្ធី ទស្សនវិជ្ជាអហិង្សា, ១៩៩៦
- សេចក្ដីប្រកាសទីក្រុងអ៊ីនឈុន, វិស័យអប់រំឆ្នាំ២០៣០, ២០១៥
- សៀវភៅសិក្សាគោល អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ , ២០២២
- សៀវភៅសិក្សាគោល អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១ , ២០២១
- សៀវភៅសិក្សាគោល ភាសាខ្មែរ ថ្នាក់ទី១០ , ២០១៦
- ឡុញចាន់ថន-ឃិន វណ្ណី, ទស្សនវិជ្ជាអប់រំ , ២០២១
- អនុក្រឹតស្ដីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, ២០០៨